# ជំនឿ និង សេចក្ដីបង្រៀន

# នៃ

# ពួកជំនុំសញ្ញាថ្មី

# *Beliefs and Doctrines of the New Testament Church*

ដោយ ប៊ូ ឈុំ

# ព្រះបន្ទូលព្រះ

«ទូលបង្គំបានកំណត់ចាំព្រះបន្ទូលទ្រង់ទុកនៅក្នុងចិត្ត ប្រយោជន៍កុំឲ្យទូលបង្គំ

ធ្វើបាបនឹងទ្រង់ឡើយ» (ទំនុកដំកើង១១៩:១១)

«...ឯសេចក្តីពិត គឺជាព្រះបន្ទូលរបស់ទ្រង់»

(យ៉ូហាន១៧:១៧)

«អ្នករាល់គ្នានឹងស្គាល់សេចក្តីពិត ហើយសេចក្តីពិតនោះ នឹងប្រោស

ឲ្យអ្នករាល់គ្នាបានរួច» (យ៉ូហាន៨:៣២)

***ខ្មែរស្ទូនគ្នាហៅសំរាប់ព្រះ***

*Khmer Brethren Called for God*


www.sabbathreflections.org

chumbou2020@gmail.com

016 509 779/ 097 990 6244/ 011 435 441

«គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញវិញ្ញាណបរិសុទ្ធរបស់ទ្រង់ បណ្ដាលឲ្យតែងទេ ក៏មាន ប្រយោជន៍សំរាប់ការបង្រៀន ការរំលឹកឲ្យដឹងខ្លួន ការប្រដៅដំរង់ នឹងការបង្ហាត់ខាងឯសេចក្ដីសុចរិត ដើម្បីឲ្យអ្នកសំណប់របស់ព្រះបានគ្រប់លក្ខណ៍ ហើយមានគ្រប់ទាំងចំណេះ សំរាប់នឹងធ្វើការល្អគ្រប់មុខ»
(២ធីម៉ូថេ៣:១៦-១៧)

«ឯក្រឹត្យវិន័យរបស់ព្រះយេហូវ៉ានោះគ្រប់លក្ខណ៍ ក៏តែព្រលឹងឡើងវិញ សេចក្ដីបន្ទាល់នៃព្រះយេហូវ៉ាជាពិត ក៏ធ្វើឲ្យមនុស្សខ្លៅល្ងង់មានប្រាជ្ញា សេចក្ដីបញ្ញត្តិរបស់ព្រះយេហូវ៉ាសុទ្ធតែទៀងត្រង់ ក៏បណ្ដាលឲ្យចិត្តរីករាយ សប្បាយ ក្រឹត្យក្រមនៃព្រះយេហូវ៉ាជាសុទ្ធសាធ ក៏បំភ្លឺភ្នែក សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាបរិសុទ្ធ ក៏នៅជាប់ជាដរាបដរាប អស់ទាំងខច្បាប់របស់ព្រះយេហូវ៉ាសុទ្ធតែពិតត្រង់ ហើយសុចរិតគ្រប់ជំពូក សេចក្ដី ទាំងនោះគួរចង់បានលើសជាងមាស អើ ជាជាងមាសសុទ្ធជាច្រើនដង ក៏ផ្អែមជាងទឹកឃ្មុំ ហើយជាងដំណក់ ស្រក់ពីសំណុំះផង មួយទៀត ទូលបង្គំ ជាអ្នកបំរើទ្រង់ ក៏ចេះប្រយ័ត ដោយសារសេចក្ដីទាំងនោះដែរ ហើយ ដែលកាន់តាម នោះក៏មានរង្វាន់យ៉ាងធំ» (ទំនុកដំកើង១៩:៧-១១)

ព្រះយេស៊ូវទ្រង់មានបន្ទូលថា «គឺជាវិញ្ញាណដែលឲ្យមានជីវិត រូបសាច់គ្មានប្រយោជន៍អ្វីទេ ឯពាក្យ...[ព្រះបន្ទូល] ...ដែលខ្ញុំនិយាយនឹងអ្នករាល់គ្នា នោះត្រូវខាងវិញ្ញាណនឹងជីវិតវិញ» (យ៉ូហាន៦:៦៣)

«ឯសេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាដើមចមនៃប្រាជ្ញា អស់អ្នកដែលកាន់តាមបញ្ញត្តិ នោះមានយោបល់ល្អ សេចក្ដីសរសើរនៃទ្រង់ជាប់នៅអស់កល្បជានិច្ច» (ទំនុកដំកើង១១១:១០)

# តារាងមាតិកា

ចំណងជើង ទំព័រ


អារម្ភកថា . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១

១. លក្ខណៈរបស់ព្រះ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៣

១.ក គ្រួសារព្រះអម្ចាស់ . . . . . . . . . . . . . . . . . . . . . . . . . . . . . ៣

១.ខ ព្រះអម្ចាស់ ជាព្រះវរបិតា . . . . . . . . . . . . . . . . . . . . . . . . . ៤

១.គ ព្រះអម្ចាស់ជាព្រះរាជបុត្រា គឺព្រះយេស៊ូវគ្រីស្ទ នៃភូមិណាសារ៉ែត . . . . . . ៥

២. លក្ខណៈរបស់មនុស្សជាតិ . . . . . . . . . . . . . . . . . . . . . . . . . . . ៦

៣. សេចក្ដីស្រឡាញ់របស់ព្រះ . . . . . . . . . . . . . . . . . . . . . . . . . . ៨

៣ក. សេចក្ដីស្រឡាញ់របស់ព្រះអម្ចាស់ ចំពោះយើង . . . . . . . . . . . . . . ៨

៣ខ. សេចក្ដីស្រឡាញ់របស់យើងទៅកាន់ព្រះអម្ចាស់ . . . . . . . . . . . . . . ៩

៣គ. សេចក្ដីស្រឡាញ់របស់យើងទៅកាន់បងប្អូនស្និទ្ធភ្ជា . . . . . . . . . . . . . ១០

៤. ព្រះគម្ពីរបរិសុទ្ធ . . . . . . . . . . . . . . . . . . . . . . . . . . . . . ១០

៥. ច្បាប់ នឹងបញ្ញត្តរបស់ព្រះ . . . . . . . . . . . . . . . . . . . . . . . . . ១២

៥ក. លក្ខណៈនៃច្បាប់របស់ព្រះ . . . . . . . . . . . . . . . . . . . . . . . ១២

៥ខ. បញ្ញត្តដប់ប្រការ . . . . . . . . . . . . . . . . . . . . . . . . . . . . ១៤

៥គ. ថ្ងៃសប្ប័ទប្រចាំសប្ដាហ៍ . . . . . . . . . . . . . . . . . . . . . . . . ១៤

៥ឃ. ពិធីបុណ្យបរិសុទ្ធ នឹង ថ្ងៃបរិសុទ្ធប្រចាំឆ្នាំ . . . . . . . . . . . . . . . ១៦

៦. អំពើបាប . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៧

៥. វិញ្ញាណបរិសុទ្ធ . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៨

៨. ព្រះគុណរបស់ព្រះ . . . . . . . . . . . . . . . . . . . . . . . . . . . . . ២០

៩. ការប្រែចិត្ត . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ២១

១០. ពិធីជ្រមុជទឹក . . . . . . . . . . . . . . . . . . . . . . . . . . . . . . ២៣

១១. ការរាប់ជាសុចរិត . . . . . . . . . . . . . . . . . . . . . . . . . . . . ២៣

១២. ភាពសុចរិត . . . . . . . . . . . . . . . . . . . . . . . . . . . . . . ២៣
១២ក. ភាពសុចរិតនៃច្បាប់ . . . . . . . . . . . . . . . . . . . . . . . . ២៣
១២ខ. ភាពសុចរិតនៃជំនឿ . . . . . . . . . . . . . . . . . . . . . . . . ២៥
១៣. ការញែកចេញជាបរិសុទ្ធ . . . . . . . . . . . . . . . . . . . . . . . ២៦
១៤. ការជ្រមុជទឹកដោយវិញ្ញាណ . . . . . . . . . . . . . . . . . . . . . ២៧
១៥. សេចក្ដីជំនឿ . . . . . . . . . . . . . . . . . . . . . . . . . . . . . ២៧
១៦. សេចក្ដីសង្គ្រោះ . . . . . . . . . . . . . . . . . . . . . . . . . . . ២៩
១៧. ការអធិស្ឋានដាក់ដៃលើ . . . . . . . . . . . . . . . . . . . . . . . ៣០
១៨. ការប្រោសឲ្យជា . . . . . . . . . . . . . . . . . . . . . . . . . . . ៣១
១៩. ពួកជំនុំរបស់ព្រះអម្ចាស់ . . . . . . . . . . . . . . . . . . . . . . ៣២
១៩ក. រូបអង្គជាវិញ្ញាណរបស់ព្រះយេស៊ូវគ្រីស្ទ . . . . . . . . . . . . . ៣២
១៩ខ. ព័ន្ធកិច្ចរបស់ពួកជំនុំសញ្ញាថ្មី . . . . . . . . . . . . . . . . . . . ៣២
២០. គ្រីស្ទានទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ . . . . . . . . . . . . . . . ៣៤
២០ក. ទទួលខុសត្រូវចំពោះគ្រួសារ . . . . . . . . . . . . . . . . . . . ៣៤
២០ខ. ទទួលខុសត្រូវចំពោះជនក្រីក្រ . . . . . . . . . . . . . . . . . . ៣៥
២០គ. ទទួលខុសត្រូវចំពោះពួកជំនុំ . . . . . . . . . . . . . . . . . . . ៣៦
២០ឃ. គោលការនៃការថ្វាយដង្វាយ ១ភាគក្នុង១០តាមបទគម្ពីរ . . . . . . . . ៣៧
២១. ដំណឹងល្អ . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៣៩
២២. នគរព្រះអម្ចាស់ . . . . . . . . . . . . . . . . . . . . . . . . . . . ៤០
២៣. សេចក្ដីរស់ឡើងវិញ . . . . . . . . . . . . . . . . . . . . . . . . . ៤១
២៤. ការជំនុំជំរះអស់កល្ប . . . . . . . . . . . . . . . . . . . . . . . . ៤២
២៥. ការជ្រមុជដោយភ្លើង . . . . . . . . . . . . . . . . . . . . . . . . . ៤៤
២៦. សត្វស្អាត (សាច់) នឹងសត្វមិនស្អាត . . . . . . . . . . . . . . . . . ៤៥

# អារម្ភកថា

ពួកជំនុំខាងព្រះគម្ពីរបរិសុទ្ធរបស់ព្រះ តែងតែអនុវត្តន៍តាមព្រះបន្ទូល សេចក្តីបង្រៀនពិត និងគោលលទ្ធិរបស់ព្រះយេស៊ូវគ្រីស្ទ ហើយនិងពួកសាវករបស់ទ្រង់ ដូចដែលបានចែងទុកនៅក្នុងកូនសៀវភៅនេះ។ ពួកសាវក និងពួកជំនុំសញ្ញាថ្មី បានរក្សាទុកនៅព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី។ ពួកជំនុំនៃព្រះគម្ពីរសញ្ញាថ្មី មិនដែលបាត់បង់វត្តមានម្តងណាឡើយ ទោះបីមានការបែកខ្ញែកគ្នាជាក្រុមតូចៗ ព្រមទាំងមានការប្រមាថមើលងាយ បៀតបៀន រងការសម្លប់ពីលោកីយ ហើយនិងពីអង្គការសាសនាធំៗ ហើយព្រះគម្ពីរបានកត់ត្រានូវការបៀតបៀនយ៉ាងខ្លាំងពីពួកយូដា និងពួករ៉ូម៉ាំងកាតូលិកក្រោយពីការស្លាប់របស់សាវកយ៉ូហាន នៅឆ្នាំ១០០ គ.ស. មានអ្នកចាប់ផ្តើមបោះបង់ចោលសេចក្តីជំនឿ ហើយពួកជំនុំគ្រីស្ទានក្លែងក្លាយ ក៏ចាប់

ផ្តើមកើតឡើងពីឆ្នាំ១០០ គ. ស. រហូតដល់ឆ្នាំ៣២៥ គ.ស.។ បងប្អូនស្ងួនភ្ងានៃពួកជំនុំពិតផងព្រះអម្ចាស់ ត្រូវបានបន្តរងការបៀតបៀន។ នៅជំនាន់សម័យចក្រភពរ៉ូម៉ាំង ក្រោមបញ្ជាអធិរាជ កុងស្តង់ទីន (Constantine) និងពួកអ្នកដឹកនាំដែលបោះបង់ចោលសេចក្តីជំនឿ មានពួកសង្ឃរាជ និងសម្តេចប៉ាប កាតូលិក តៗមក ហើយរដ្ឋាភិបាលស៊ីវិលនៃចក្រភពរ៉ូម៉ាំងកាតូលិក ក៏មានការបៀតបៀន ព្រមទាំងកាប់សំឡាប់ និងបណ្តេញគ្រីស្ទានពិតចេញពីចក្រភពរ៉ូមផង។ ប្រវត្តិសាស្ត្របានកត់ត្រាអំពីការបែកខ្ញែកគ្នារវាងពួកជំនុំនៃព្រះពិត ដែលបានទទួលការពារដោយពួករ៉ូម៉ាំងកាតូលិក និងពួកជំនុំអ័តូដុក (Orthodox Church) បើយោងទៅតាមពួកអ្នកដែលមិនមែនជាអ្នកកាន់សាសនា ពីព្រោះពួកគេបានបដិសេធយ៉ាងខ្លាំងទៅនឹងការដណ្តើមអំណាចខាងសាសនារបស់ពួករ៉ូម៉ាំង ហើយក៏បានបដិសេធនូវសេចក្តីជំនឿខុសឆ្គង និងគោលលទ្ធិខុសឆ្គងរបស់ពួករ៉ូម៉ាំងកាតូលិកផងដែរ។

ពួកអ្នកជឿពិត តែងតែចុះចូលទៅនឹងអំណាចរបស់ព្រះដ៏ជាព្រះវរបិតា និងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយនិងព្រះបន្ទូលរបស់ព្រះអង្គ ដោយជឿ ហើយនិងអនុវត្តិតាមគោលលទ្ធិពិត និងសេចក្តីបង្រៀនក្នុងព្រះគម្ពីរបរិសុទ្ធទាំងសញ្ញាចាស់ និងសញ្ញាថ្មី។ សេចក្តីដែលបានរៀបរាប់ពីគោលលទ្ធិ ខាងក្រោម គឺជាសេចក្តីបង្រៀនពិតនៅក្នុងព្រះគម្ពីរបរិសុទ្ធ។ សព្វថ្ងៃនេះ ពួកជំនុំពិតរបស់ព្រះអម្ចាស់បានទាញ

យកសេចក្តីបង្រៀនពិតពីក្នុងព្រះគម្ពីរ នឹងគោលលទ្ធិដែលពួកជំនុំដំបូងៗបានបង្រៀនរួចមកហើយ។ សេចក្តីរៀបរាប់ទាំងអស់នេះ ត្រូវបានរៀបចំឡើង ដើម្បីផ្តល់នូវសេចក្តីសង្ខេបយ៉ាងខ្លីនៃសេចក្តីជំនឿ នៃគោលលទ្ធិ និមួយៗ ហើយក៏មិនមានបំណងធ្វើឲ្យនឿយណាយនោះទេ។ ព្រះគម្ពីរយោងនៃអត្ថបទនិមួយៗ ដែលបានរៀបរាប់ មិនមែនមានន័យថា ការលើកឡើងបទគម្ពីរជាច្រើន ដើម្បីគាំទ្រនូវគោលលទ្ធិទាំងនោះ មានន័យពេញលេញទាំងស្រុងនោះទេ។

# ជំនឿ នឹង សេចក្តីបង្រៀននៃពួកជំនុំសញ្ញាថ្មី

*សេចក្តីបង្រៀនពិត នឹងគោលលទ្ធិរបស់ព្រះយេស៊ូវគ្រីស្ទ នឹងពួកសាវក ត្រូវបានលើកសម្តែងនៅក្នុងព្រះគម្ពីរបរិសុទ្ធ*

## ១. លក្ខណៈរបស់ព្រះអម្ចាស់

### ១ក. គ្រួសាររបស់ព្រះអម្ចាស់

ព្រះអម្ចាស់ ជាភាសាហេព្រើរ គឺអេឡូហ៊ីម ជានាមពហុវចនៈ មានន័យច្រើនជាងមួយ គឺជាគ្រួសារដ៏បរិសុទ្ធមួយ ដែលពេញដោយព្រះចេស្តា នឹងភាពវៃឆ្លាត។ ជាគ្រួសារព្រះអម្ចាស់ដែលស្ថិតនៅអស់កល្បជានិច្ច មានគ្រប់អំណាច នឹងព្រះចេស្តា។ គ្រួសាររបស់ព្រះអម្ចាស់ គឺល្អឥតខ្ចោះ គ្រប់លក្ខណ៍ ពេញដោយសេចក្តីស្រឡាញ់ មានគោលបំណង នឹងលក្ខណៈល្អ។ គ្រួសាររបស់ព្រះអម្ចាស់ គឺជាអង្គបង្កើតច្បាប់ បង្កើតរបស់សព្វសារពើ ជាអង្គទ្រទ្រង់នូវសារៈជាតុ នឹងគ្រប់ជីវិតទាំងអស់ ជាអង្គការពារ នឹងគ្រប់គ្រងសាកលលោកទាំងមូល។ ព្រះគម្ពីរបានសម្តែងថា ព្រះអម្ចាស់ទ្រង់បានបង្កើតមនុស្ស «ទ្រង់ក៏បង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ គឺបានបង្កើតគេឲ្យចំនឹងរូបអង្គទ្រង់នោះឯង...» ហេតុដូច្នេះហើយ ព្រះអម្ចាស់ទ្រង់ជាសេចក្តីពិត មានកាយ នឹងលក្ខណៈដូចមនុស្សដែលទ្រង់បានបង្កើតឡើង។ គ្រួសាររបស់ព្រះអម្ចាស់មានពីរ (២) អង្គ គឺព្រះដ៏ជាព្រះវរបិតា នឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រាទ្រង់។ សមាជិកគ្រួសារទាំងពីរអង្គនេះ មានលក្ខណៈតែមួយ ឬ«ភាពតំណាង នឹងលក្ខណៈដូច» ដែលព្រះទ្រង់បានប្រទានដល់មនុស្សជាតិ យ៉ាងដូច្នោះ

ដែរ។ គោលបំណងមួយ នៃគោលបំណងជាច្រើនរបស់ព្រះអម្ចាស់ គឺពង្រីកគ្រួសាររបស់ព្រះអង្គ ទៅតាមផែនការ នឹង តាមគោលបំណងព្រះហឫទ័យរបស់ព្រះអង្គ ដែលទ្រង់សព្វព្រះហឫទ័យនឹងប្រទានវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ ដល់អស់អ្នកដែលប្រែចិត្តពីអំពើបាប ជឿព្រះយេស៊ូវគ្រីស្ទ រស់នៅតាមគ្រប់ព្រះបន្ទូលដែលចេញពីព្រះឱស្ឋព្រះមក។ នៅក្នុងគ្រួសាររបស់ព្រះអម្ចាស់ អស់អ្នកដែលត្រូវបានប្រោសឲ្យរស់ពីស្លាប់ឡើងវិញ នៅពេលព្រះអម្ចាស់យេស៊ូវគ្រីស្ទយាងត្រឡប់មកផែនដីនេះវិញ។ អស់អ្នកនៅក្នុងគ្រួសាររបស់ព្រះអម្ចាស់ នឹងទទួលបានសេចក្តីស្រឡាញ់ដ៏ធំធេង សិរីរុងរឿង នឹងអំណាច ជាកូនប្រុស កូនស្រីរបស់ព្រះអម្ចាស់រស់នៅអស់

កល្បជានិច្ច ក្នុងនគរទ្រង់។

គម្ពីរយោង:

១. លោកុប្បត្តិ ១:២៦
២. ១យ៉ូហាន៤:៨
៣. អេភេសូរ៣:៩-២១
៤. កូល៉ុស១:១២-២៧
៥. ទំនុកដំកើង១៩:១-៧
៦. អេសាយ៤០:១២-២៨
៧. អេសាយ៥៧:១៥
៨. អេភេសូរ ៣:១-៥, ៩-១១
៩. ដានីយ៉ែល៧:៩-១០
១០ វិវរណៈ១:១៤-១៦
១១. យ៉ូហាន៤:២៤
១២. ទំនុកដំកើង៨:១-៦

## ១ខ. ព្រះអម្ចាស់ជាព្រះវរបិតា

ព្រះអម្ចាស់ជាព្រះវរបិតា គឺជាតួអង្គដ៏ខ្ពង់ខ្ពស់បំផុត ដែលពោរពេញដោយសិរីរុងរឿង គឺជាព្រះដ៏បរិសុទ្ធ គ្រប់លក្ខណ៍ ល្អក្រៃលែង គឺជាអង្គគ្រប់គ្រងនៃសាកលលោកទាំងមូល។ ព្រះអម្ចាស់ដ៏ជាព្រះវរបិតា ទ្រង់បានសំដែងចេញនូវព្រះហឫទ័យទ្រង់ តាមរយៈអំណាចនៃវិញ្ញាណបរិសុទ្ធរបស់ទ្រង់។ ព្រះអម្ចាស់ដ៏ជាព្រះវរបិតា ទ្រង់មានគ្រប់ព្រះចេស្តា អំណាច ព្រះគុណ នឹងសេចក្តីស្រឡាញ់ដ៏ពោរពេញ ទ្រង់គ្រប់លក្ខណ៍ល្អឥតខ្ចោះ ព្រះទ្រង់បរិសុទ្ធ នឹងមានសេចក្តីមេត្តាករុណា ដ៏លើសលុប។ ព្រះអម្ចាស់ជាព្រះវរបិតាទ្រង់ធំជាងព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រារបស់ទ្រង់។ ព្រះវរបិតាបានចាត់ព្រះយេស៊ូវគ្រីស្ទមកផែនដីនេះ ដើម្បីបង្ហាញពីសេចក្តីស្រឡាញ់ ព្រះគុណ នឹងផែនការនៃសេចក្តីសង្គ្រោះដ៏អស្ចារ្យរបស់ព្រះអង្គ សំរាប់មនុស្សគ្រប់រូប។ ព្រះអម្ចាស់ដ៏ជាព្រះវរបិតា ទ្រង់ត្រាស់ហៅមនុស្សម្នាក់ៗ ផ្ទាល់អង្គទ្រង់ ដើម្បីឲ្យពួកគេអាចទទួលបានសេចក្តីសង្គ្រោះ ប្រទានឲ្យអាចប្រែចិត្តពីអំពើបាប ហើយប្រទានវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ មកក្នុងជីវិតរបស់អ្នកនោះផង ដូច្នេះ ទើបមនុស្សម្នាក់ៗ អាចត្រឡប់ជាកូនប្រុស កូនស្រីរបស់ព្រះអម្ចាស់ដ៏ជាព្រះវរបិតាបាន។ ព្រះអម្ចាស់ដ៏ជាព្រះវរបិតា ទ្រង់ស្រឡាញ់អស់អ្នកដែលទទួលការត្រាស់ហៅរបស់ទ្រង់ ហើយក៏បានស្ថិតនៅក្នុងជីវិតអ្នកទាំងអស់នោះ ដោយវិញ្ញាណបរិសុទ្ធរបស់ទ្រង់។ ព្រះអង្គទ្រង់បន្តផ្តល់នូវសេចក្តីស្រឡាញ់ ព្រះគុណ សេចក្តីមេត្តាករុណា នឹងព្រះពរ ដើម្បីឲ្យកូនប្រុស កូនស្រីរបស់ព្រះអង្គ អាចរីកចំរើនក្នុង

សេចក្តីស្រឡាញ់នៃព្រះ ភាពគ្រប់លក្ខណ៍ នឹងលក្ខណៈសុចរិតរបស់ទ្រង់កាន់តែច្រើនឡើងថែមទៀត។ ព្រះអម្ចាស់ជាព្រះវរបិតា ទ្រង់តែងស្តាប់គ្រប់សេចក្តីអធិស្ឋាន ហើយនឹងឆ្លើយតាមទៅកូនរបស់ព្រះអង្គ ទៅតាមព្រះហឫទ័យទ្រង់។

គម្ពីរយោង:

១. ១យ៉ូហាន៤:៨-១៦
២. យ៉ូហាន៨:១៦-១៨
៣. យ៉ូហាន១៤:២៨
៤. យ៉ូហាន១៦:២៧
៥. ហេព្រើរ២:៣-៩
៦. ម៉ាថាយ១១:២៧
៧. វិវរណៈ ២១:២២
៨. យ៉ូហាន៦:២២
៩. យ៉ូហាន១:១-២, ១៧-១៨
១០. អេភេសូរ៣:១៤-១៩
១១. ហេព្រើរ១:១-២
១២. អេភេសូរ៤:៤-៦
១៣. ១កូរិនថូស១៥:២៤-២៨

## ១គ. ព្រះអម្ចាស់ជាព្រះរាជបុត្រា គឺព្រះយេស៊ូវគ្រីស្ទ នៃភូមិណាសារ៉ែត

យោងទៅតាមការចាប់ផ្តើមយកនិស្ស័យជាមនុស្សរបស់ព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃព្រះ គឺអេឡូហ៊ីមនៃគ្រួសាររបស់ព្រះអម្ចាស់ ដែលមានវត្តមានទៅអស់កល្បជានិច្ច គឺព្រះដ៏ជាព្រះវរបិតា ដែលទ្រង់បង្កើតរបស់សព្វសារពើទាំងអស់ តាមរយៈព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រាទ្រង់។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ព្រះយេស៊ូវគ្រីស្ទ នាមទ្រង់«ជាព្រះអម្ចាស់» ជាអង្គ ដែលបង្កើតច្បាប់ ហើយនៅក្នុងគម្ពីរសញ្ញាថ្មី ទ្រង់មាននាមជា«ព្រះបន្ទូល»។ ដើម្បីធ្វើជាព្រះអង្គសង្គ្រោះសំរាប់មនុស្សគ្រប់ៗគ្នា ព្រះយេស៊ូវគ្រីស្ទទ្រង់បានលះបង់ឋានៈរបស់ទ្រង់នៅក្នុងគ្រួសារនៃព្រះអម្ចាស់ ទ្រង់លះបង់ព្រះចេស្តា សិរីរុងរឿង នឹងអំណាច មកយកនិស្ស័យជាមនុស្ស ប្រសូត្រដោយនាងព្រហ្មចារីម៉ារី ហើយថ្វាយព្រះនាមទ្រង់ថា «យេស៊ូវ» ព្រះនាមពេញរបស់ទ្រង់នៅក្នុងព្រះគម្ពីរសញ្ញាថ្មី «គឺព្រះយេស៊ូវគ្រីស្ទនៃភូមិណាសារ៉ែត»។ ក្នុងសាច់ឈាមព្រះយេស៊ូវគ្រីស្ទទ្រង់ជាកូនមនុស្ស ដែលឥតមានអំពើបាបសោះ តែទ្រង់ក៏ត្រូវទទួលនូវសេចក្តីល្បួងដូចមនុស្សឯទៀតដែរ ប៉ុន្តែ ទ្រង់មិនដែលប្រព្រឹត្តអំពើបាបទាល់តែសោះ។ ព្រះយេស៊ូវគ្រីស្ទ ទ្រង់ជាកូនចៀមដ៏ល្អឥតខ្ចោះរបស់ព្រះអម្ចាស់ ដោយបានថ្វាយអង្គទ្រង់ជាដង្វាយបរិសុទ្ធដល់ព្រះ គឺជាការលះបង់ដ៏ធំអស្ចារ្យ ដោយសុគតនៅលើឈើឆ្កាង ខ្វាយ

ព្រះលោហិត ដើម្បីលោះបាបមនុស្សទាំងអស់។ ពួកសិស្សក៏បញ្ចុះសពទ្រង់នៅក្នុងផ្នូររបស់អ្នកមានម្នាក់ អស់បីយប់ បីថ្ងៃ លុះដល់ពេលកំណត់ ព្រះដ៏ជាព្រះវរបិតាទ្រង់បានប្រោសព្រះយេស៊ូវ ឲ្យមានព្រះជន្មរស់ពីសុគតឡើងវិញ។ ព្រះយេស៊ូវគ្រីស្ទទ្រង់ជាបងច្បង ដែលរស់ពីស្លាប់ឡើងវិញមុនគេបង្អស់ ក្នុងចំណោមពួកអ្នកស្លាប់ទាំងអស់។

ម្ដងទៀត ព្រះយេស៊ូវគ្រីស្ទ ទ្រង់បរិសុទ្ធ គ្រប់លក្ខណ៍ នឹងមានអំណាចដ៏អស្ចារ្យនៅក្នុងគ្រួសារនៃព្រះអម្ចាស់។ បន្ទាប់ពីមានព្រះជន្មរស់ពីសុគតឡើងវិញ ព្រះយេស៊ូវគ្រីស្ទទ្រង់បានយាងត្រឡប់ទៅស្ថានសួគ៌វិញ គង់នៅខាងព្រះហស្តស្ដាំនៃព្រះវរបិតា។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទទ្រង់ក៏ជាសម្ដេចសង្ឃដ៏ខ្ពស់នៃមនុស្សលោក ជាអង្គការពារ ជាអង្គសម្របសម្រួល នឹងជាអង្គដឹកនាំនៃពួកជំនុំរបស់ទ្រង់។ ព្រះយេស៊ូវគ្រីស្ទទ្រង់នឹងយាងត្រឡប់មកផែនដីនេះវិញ ពេញដោយអំណាច នឹងសិរីរុងរឿងនៃព្រះវរបិតាទ្រង់ ដើម្បីនឹងសោយរាជ្យ ហើយនឹងបង្កើតរដ្ឋាភិបាលនៃព្រះអម្ចាស់នៅលើផែនដីនេះ ក្នុងនាមទ្រង់ «ជាស្ដេចលើអស់ទាំងស្ដេច ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់» ទ្រង់នឹងគ្រប់គ្រងផែនដី ជាមួយបងប្អូនប្រុស ស្រីរបស់ទ្រង់ ជារៀងរហូត ក្នុងនគរនៃព្រះវរបិតាទ្រង់។

គម្ពីរយោង:

១. យ៉ូហាន១:១-៣
២. អេភេសូរ១:៦-២៣
៣. ហេព្រើរ៤:១៤-១៦
៤. រ៉ូម៨:៣, ២៩
៥. រ៉ូម៥:៨
៦. យ៉ូហាន១៧:១-២៦
៧. វិវរណៈ១៣:៨
៨. ភីលីព២:៦-១១
៩. ហេព្រើរ២:៩-១៤
១០. ហេព្រើរ៥:៧-៩
១១. វិវរណៈ៥:៩-១០
១២. យ៉ូហាន៣:១៦
១៣. ១យ៉ូហាន២:១-២
១៤. កូល៉ុស១:១៤-២០

## ២. លក្ខណៈនៃមនុស្សជាតិ

អេឡូហ៊ីម នៃគ្រួសារព្រះអម្ចាស់ ក្រោយមកបានត្រឡប់ជាព្រះយេស៊ូវគ្រីស្ទ ទ្រង់បានបង្កើតអ័ដាម នឹងអេវ៉ា ដោយព្រះហស្តទ្រង់ផ្ទាល់។ ព្រះអម្ចាស់ទ្រង់បង្កើតមនុស្សឡើង ឲ្យមានលក្ខណៈដូចរូបអង្គទ្រង់ ឬក៏ជា

អេឡូហ៊ីម ប៉ុន្តែ នៅក្រោមព្រះអម្ចាស់។ មនុស្សត្រូវបានបង្កើតឡើងជាសាច់ឈាម មិនមានអមតៈភាពទេ ទោះបីជាយ៉ាងណាក៏ដោយ ព្រះអម្ចាស់ទ្រង់បានប្រទានវិញ្ញាណដ៏សំខាន់មកក្នុងខួរក្បាលរបស់មនុស្ស ដែលហៅថា «វិញ្ញាណរបស់មនុស្ស» វិញ្ញាណរបស់មនុស្ស បង្កើតអំណាច ចេះដឹងហេតុផល ភាពឆ្លាតវៃ នឹងផ្តល់ឲ្យមនុស្សមានសមត្ថភាព ដើម្បីគិត និយាយ រៀនសូត្រ សរសេរ ធ្វើផែនការ ច្នៃប្រឌិត បង្កើត កសាង គ្រប់គ្រង បង្រៀន ជ្រើសរើស ថ្វាយបង្គំ អត្តចារិក នឹងមានបទពិសោធន៍ជាមួយអារម្មណ៍ផ្សេងៗ ព្រះអម្ចាស់ទ្រង់បង្កើតមនុស្សប្រុស នឹងមនុស្សស្រី ជាមួយនឹងសមត្ថភាពដែលបង្ហាញភាពស្និតស្នាលរវាងមនុស្សនឹងមនុស្សផងគ្នា ដើម្បីបង្ហាញពីសេចក្តីស្រឡាញ់ផ្ទាល់ខ្លួន សំរាប់គ្នាទៅវិញ ទៅមក ក្នុងនាមជាប្តី នឹងជាប្រពន្ធ ហើយតាមរយៈការរួបរួមរូបកាយនេះ ដើម្បីបង្កើតកូនចៅឲ្យមានជាបន្ត បង្កើតក្រុមគ្រួសារ បក្សពួក កុលសម្ព័ន្ធ នឹងប្រជាជាតិ។ អ័ដាម នឹងអេវ៉ា បានបង្កើតឡើង ដោយគ្មានអំពើបាប ប៉ុន្តែ អាចត្រូវទទួលសេចក្តីល្បួងៗ ព្រះអម្ចាស់បានប្រទានសិរីភាពដល់អ័ដាម នឹងអេវ៉ា ដើម្បីធ្វើការជ្រើសរើស ពួកគេអាចជ្រើសរើសយកការស្តាប់

បង្គាប់ នឹងជីវិត ឬយកការមិនស្តាប់បង្គាប់ នឹងសេចក្តីស្លាប់។ អ័ដាម នឹងអេវ៉ា បានធ្វើបាបដោយប្រព្រឹត្តរំលងបញ្ញត្ត ដែលព្រះអង្គហាមប្រាមគេមិនឲ្យបរិភោគផ្លែឈើដឹងខុស ត្រូវ ប៉ុន្តែ អ័ដាម នឹងអេវ៉ា មិនព្រមស្តាប់តាម ក៏ប្រព្រឹត្តរំលងការហាមឃាត់ ហេតុនោះហើយ ព្រះអម្ចាស់ក៏ប្រទានឲ្យអ័ដាម នឹងអេវ៉ានឹងពូជគេ ទទួលរងការឈឺចាប់ នឹងទុក្ខព្រួយ រស់នៅជាមួយនឹងអំពើបាប រហូតដល់ថ្ងៃស្លាប់។ សេចក្តីស្លាប់បានរាលដាលដល់មនុស្សគ្រប់រូប គឺមនុស្សគ្រប់រូបបានទទួលមរដក អំពើបាប គឺសេចក្តីស្លាប់ តពីអ័ដាម នឹងអេវ៉ាមក។ ហេតុនេះហើយ លក្ខណៈធម្មជាតិរបស់មមនុស្ស គឺជាសត្រូវនឹងព្រះ ដោយប្រព្រឹត្តរំលងបញ្ញត្ត មិនស្តាប់បង្គាប់តាមព្រះ តាំងតែពីដើមកំណើតរបស់មនុស្សមកម្ល៉េះ។ ដោយសារតែស៊ីផ្លែឈើដឹងខុស ត្រូវ ហេតុនេះហើយ ការប្រព្រឹត្តរបស់មនុស្សលាយឡំ ការល្អ នឹងការអាក្រក់។ ពេលមនុស្សស្លាប់ សតិស្មារតី ត្រូវបាត់បង់ រូបកាយក៏ត្រឡប់ទៅធូលី ហើយវិញ្ញាណរបស់មនុស្សក៏ត្រឡប់ទៅឯព្រះវិញ។ ដោយសារព្រះគុណរបស់ព្រះដ៏ជាព្រះវរបិតា នឹងផែនការនៃសេចក្តីសង្រ្គោះរបស់ទ្រង់ តាមរយៈយញ្ញបូជា នឹងលោហិតរបស់ព្រះយេស៊ូវគ្រីស្ទសំរាប់លោះបាបរបស់មនុស្ស ទើបអាចទទួលសេចក្តីសង្រ្គោះបាន។ គោលបំណងចម្បងរបស់ព្រះគឺផ្សះផ្សាមនុស្សជាមួយនឹងព្រះដ៏ជាព្រះវរបិតាឡើងវិញ តាមរយៈព្រះយេស៊ូវគ្រីស្ទ ដូច្នេះ អស់អ្នកណាដែលប្រែចិត្តពីអំពើបាប ជឿព្រះយេស៊ូវគ្រីស្ទ ទទួលបុណ្យជ្រមុជទឹក ហើយទទួលវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ មក

បញ្ចាំក្នុងចិត្តអ្នកទាំងអស់នោះ ពេលព្រះដ៏ជាព្រះវរបិតាទ្រង់ចាត់ឲ្យព្រះយេស៊ូវគ្រីស្ទ យាងមកកាន់ផែនដីនេះជាលើកទី២ ទ្រង់នឹងប្រោសឲ្យអ្នកទាំងអស់នោះរស់ពីស្លាប់ឡើងវិញ រស់ជាវិញ្ញាណ ហើយនឹងចូលទៅក្នុងនគរព្រះ ជាកូនប្រុស កូនស្រីរបស់ព្រះអម្ចាស់ រស់នៅអស់កល្បជានិច្ច។

គម្ពីរយោង:

១. លោកុប្បត្តិ១:២៦-២៧
២. សាការី១២:១
៣. លោកុប្បត្តិ៣:១-១៩
៤. អេសេគាល១៨:៤, ២០
៥. ម៉ាកុស៧:២១-២២
៦. សាស្តា៣:១៩-២១
៧. ១កូរិនថូស១៥:៤៤-៥៦
៨. ១យ៉ូហាន៣:១-៣
៩. ទំនុកដំកើង៨:៣-៦
១០. លោកុប្បត្តិ២:៧-២៥
១១. ១កូរិនថូស២:១១
១២. រ៉ូម៨:៧-៨
១៣. ហេព្រើរ៩:២៧
១៤. ១កូរិនថូស១៥:២១-២២
១៥. វិវរណៈ២១:៧
១៦. កិលីព៣:២១

## ៣. សេចក្តីស្រឡាញ់របស់ព្រះអម្ចាស់

### ៣ក. សេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ចំពោះយើង

សេចក្តីស្រឡាញ់បានបើកសំដែងនៅក្នុងគ្រួសាររបស់ព្រះអម្ចាស់ ដោយទ្រង់បានបង្កើតមនុស្សឲ្យមានភាព នឹងលក្ខណៈដូចទ្រង់ ប្រទានឲ្យមានអំណាចលើផែនដីទាំងមូល ដែលត្រូវបានបង្កើតឡើងសម្រាប់ពួកគេ។សេចក្តីស្រឡាញ់យ៉ាងជ្រាលជ្រៅរបស់ព្រះអម្ចាស់បានបង្ហាញយ៉ាងច្បាស់ទៅដល់មនុស្សតាមរយៈផែនការទាំងមូលរបស់ទ្រង់ ដូចបានបើកសម្តែងនៅក្នុងព្រះគម្ពីរសញ្ញាថ្មី អំពីជីវិត សេចក្តីស្លាប់ នឹង ការរស់ឡើងវិញរបស់ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ។ នៅក្នុងសេចក្តីស្រឡាញ់ដ៏ខ្ពស់បំផុតរបស់ព្រះអម្ចាស់ជាព្រះវរបិតា ទ្រង់បានផ្តល់ឱកាសដល់មនុស្សគ្រប់រូប ដើម្បីឲ្យបានកើតនៅក្នុងគ្រួសាររបស់ព្រះអម្ចាស់ តាមរយៈការប្រោសឲ្យរស់ពីស្លាប់ឡើង បានជាកូនរបស់ព្រះដ៏ជាព្រះវរបិតា មានរូបកាយជាវិញ្ញាណ ដូចជាព្រះវរបិតា

នឹងព្រះយេស៊ូវគ្រីស្ទដែរ។ ព្រះអម្ចាស់ទ្រង់ប្រទានសេចក្តីស្រឡាញ់ នឹងការផ្សះផ្សាដល់អស់អ្នកដែលទ្រង់ត្រាស់ហៅ តាមផែនការនៃសេចក្តីសង្គ្រោះរបស់ទ្រង់។ សេចក្តីស្រឡាញ់របស់ព្រះវរបិតា បានត្រូវបង្ហាញយ៉ាងច្បាស់ ដោយចាត់ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ មកផែនដីនេះ ដោយព្រះគុណ នឹងសេចក្តីមេត្តាករុណាដល់មនុស្សគ្រប់គ្នា អស់អ្នកដែលទទួលការត្រាស់ហៅរបស់ទ្រង់ នោះទ្រង់ក៏តែងតែយកព្រះហទ័យទុកដាក់ ជាមួយនឹងអស់អ្នកដែលទ្រង់ត្រាស់ហៅ។

គម្ពីរយោង

| | |
|---|---|
| ១. រ៉ូម៥:៦-៨ | ៦. យ៉ូហាន៣:១៦ |
| ២. ទំនុកដំកើង១៤:៥-៨ | ៧. ១យ៉ូហាន៣:១ |
| ៣. ហេព្រើរ១២:៦ | ៨. ១យ៉ូហាន៤:៨-១០, ១៦ |
| ៤. យ៉ូហាន១៦:១៤-២១ | ៩. យ៉ូហាន១៦:៧ |

## ៣២. សេចក្តីស្រឡាញ់របស់យើងទៅកាន់ព្រះអម្ចាស់

យើងស្រឡាញ់ព្រះអម្ចាស់ ពីព្រោះព្រះអម្ចាស់ទ្រង់បានស្រឡាញ់យើងរាល់គ្នាជាមុន។ សេចក្តីស្រឡាញ់របស់យើងចំពោះព្រះអម្ចាស់ គឺជាលទ្ធផលនៃការត្រាស់ហៅរបស់ព្រះវរបិតា តាមរយៈអំណាចនៃវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដែលបានបើកចិត្តយើងរាល់គ្នាឲ្យយល់ពីភាពអស្ចារ្យ ពីសេចក្តីមេត្តាករុណា នឹងសេចក្តីស្រឡាញ់របស់ព្រះអង្គ នឹងឲ្យយើងរាល់គ្នាស្គាល់ពីអំពើបាប នឹងពីកំណើតរបស់មនុស្ស។

ដោយសេចក្តីសប្បុរសនៃព្រះវរបិតា បានទាញនាំឲ្យយើងប្រែចិត្ត នឹងទទួលយញ្ញបូជារបស់ព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់ខ្ចាយព្រះលោហិតនៅលើឈើឆ្កាង សំរាប់អត់ទោសអំពើបាបរបស់យើង។ យើងបង្ហាញពីការប្រែចិត្ត នឹងជឿព្រះយេស៊ូវគ្រីស្ទ ទទួលជ្រមុជទឹក ជានិមិត្តរូបនៃការកប់ជីវិតចាស់របស់យើង ជាមួយនឹងសេចក្តីសុគតរបស់ព្រះយេស៊ូវ កាលណាយើងងើបពីទឹកមកវិញ នោះជានិមិត្តរូបពីសេចក្តីរស់ពីស្លាប់ឡើងវិញរបស់យើងម្នាក់ៗ ដើម្បីឲ្យយើងបានដើរក្នុងជីវិតបែបថ្មី។ តាមរយៈការដាក់ដៃលើអធិស្ឋាន ឲ្យបានទទួលអំណោយទានជាវិញ្ញាណបរិសុទ្ធរបស់ព្រះវរបិតា ដែលទ្រង់ប្រទានមកក្នុងជីវិតយើងរាល់គ្នា ដើម្បីឲ្យយើងបានស្រឡាញ់ដល់ព្រះដ៏ជាព្រះវរបិតា នឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង អស់អំពីគំនិត ហើយអស់អំពីកំឡាំងនៃយើង។ ព្រះអម្ចាស់យេស៊ូវទ្រង់មានបន្ទូលថា អស់អ្នកណាដែលមិនស្រឡាញ់ដល់

ព្រះអម្ចាស់ច្រើនជាងអ្វីៗទាំងអស់ នោះមិនមានតម្លៃចំពោះទ្រង់ទេ។ សេចក្ដីស្រឡាញ់ នឹងភាពស្មោះត្រង់របស់យើងចំពោះព្រះដ៏ជាព្រះវរបិតា នឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ត្រូវបានបង្ហាញឲ្យដឹងតាមរយៈការរស់នៅ ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមក នឹងរក្សាអស់ទាំងបញ្ញត្ត នឹងច្បាប់របស់ព្រះអង្គ។

គម្ពីរយោង:

១. ១យ៉ូហាន៤:១៦-១៩
២. ម៉ាថាយ២២:៣៧-៣៨
៣. រ៉ូម៥:៥
៥. ទំនុកដំកើង៩៧:១០
៦. ហេព្រើរ១៣:៣
៧. យ៉ូហាន៥:២-៣
៨. អេភេសូ៥:១-២
៩. ១យ៉ូហាន២:៥, ១៥
១១. ហេព្រើរ៦:៥
១២. ម៉ាថាយ១០:៣៧-៣៨

## ៣គ. សេចក្ដីស្រឡាញ់របស់យើងទៅកាន់បងប្អូនស្ងួនភ្ងា

គ្រីស្ទានពិតប្រាកដ ត្រូវមានសេចក្ដីស្រឡាញ់ដល់គ្នា ទៅវិញទៅមក ពីព្រោះព្រះវរបិតា នឹងព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានត្រាស់ហៅយើងម្នាក់ៗ ហើយទ្រង់ក៏បានស្រឡាញ់មនុស្សយើងគ្រប់គ្នាដែរ។ ក្នុងនាមជាកូនរបស់ព្រះអម្ចាស់ ដែលបានទទួលវិញ្ញាណបរិសុទ្ធរបស់ទ្រង់មកក្នុងចិត្ត ត្រូវមានសេចក្ដីប្រកបដ៏អស្ចារ្យជាមួយនឹងព្រះដ៏ជាព្រះវរបិតា នឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ការប្រកបនេះ គឺជាមូលដ្ឋានគ្រឹះ សំរាប់បទបញ្ញត្តថ្មី ដែលព្រះយេស៊ូវគ្រីស្ទប្រទានមកពួកសាវករបស់ទ្រង់ «គឺឲ្យស្រឡាញ់គ្នាទៅវិញទៅមក ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ» សេចក្ដីស្រឡាញ់របស់គ្រីស្ទានពិត ជាសញ្ញាបង្ហាញឲ្យមនុស្សទាំងអស់អាចស្គាល់ថា យើងជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទពិត។

គម្ពីរយោង:

១. យ៉ូហាន១៣:៣៤-៣៥
២. យ៉ូហាន៣:១៦-១៧
៥. យ៉ូហាន១៥:៩-១០
៦. ១យ៉ូហាន២:៦-១១

៣. យ៉ូហាន៥:១-២១ ៧. យ៉ូហាន៤:១៩-២១

៤. ២យ៉ូហាន ១៤-៦

## ៤. ព្រះគម្ពីរបរិសុទ្ធ

ព្រះគម្ពីរបរិសុទ្ធ គឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់។ ព្រះអម្ចាស់ទ្រង់បានបណ្តាលឲ្យអ្នកបំរើរបស់ទ្រង់ ដែលទ្រង់បានជ្រើសរើសគេ តាមរយៈអំណាចនៃវិញ្ញាណរបស់ទ្រង់ ដើម្បីឲ្យសរសេរព្រះគម្ពីរបរិសុទ្ធនេះឡើង ទាំង សញ្ញាចាស់ នឹងសញ្ញាថ្មី សំរាប់ឲ្យមនុស្សស្គាល់ព្រះអង្គពិត។ ព្រះគម្ពីរសញ្ញាចាស់ត្រូវបានសរសេរឡើង ជាភាសាហេព្រើរ នឹងត្រូវបានការពារ នឹងរក្សាទុកដោយពួក Massoretes គឺជាពួកលេវី ដែលត្រូវបានតាំងឡើងដោយអែសរ៉ា ឲ្យធ្វើជាអ្នកមើល ហើយថែរក្សាព្រះគម្ពីរសញ្ញាចាស់។ ព្រះគម្ពីរសញ្ញាថ្មី ត្រូវបានសរសេរឡើង ជាភាសាក្រិក ដោយពួកអ្នកបំរើ នឹងពួកសាវករបស់ព្រះយេស៊ូវគ្រីស្ទ។ សាវកយ៉ូហានបានបញ្ចប់ព្រះគម្ពីរសញ្ញាថ្មី ដោយសរសេរគម្ពីរវិវរណៈ មុនដែលលោកស្លាប់។ ព្រះគម្ពីរវិវរណៈ ជាព្រះគម្ពីរចុងក្រោយនៃព្រះ ព្រះគម្ពីរទាំងមូល។ ព្រះអម្ចាស់បានរក្សាទុកព្រះគម្ពីរសញ្ញាថ្មីតាមរយៈពួកជំនុំនិយាយភាសាក្រិក មានឈ្មោះថា Byzatine គឺជាឯកសារដើមរបស់ពួកជំនុំដែលនិយាយភាសាក្រិក បន្ទាប់ពីសម័យពួកសាវក ពីឆ្នាំ៣១២ គ.ស. ដល់ឆ្នាំ ១៤៥៣ គ. ស.។ ឯកសារនេះក៏ត្រូវបានគេស្គាល់ថាជាឯកសារដើមរបស់ Stephens នៃឆ្នាំ ១៥៥០ គ.ស.ឯកសារនេះ ក៏ត្រូវបានគេយកមកបកប្រែគម្ពីរសញ្ញាថ្មី ជាភាសាអង់គ្លេស គឺគម្ពីរ ឃីងចេម វើស្សិន King James Version នៅឆ្នាំ១៦១១ គ.ស. ព្រះគម្ពីរបរិសុទ្ធមានចំណេះដឹង ផ្នែកខាងវិញ្ញាណដ៏សំខាន់ ដែលព្រះអម្ចាស់បើកសំដែងដោយសារវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដើម្បីឲ្យមនុស្សអាចស្វែងរកព្រះអង្គឃើញ ពីព្រោះមនុស្សមិនអាចរកព្រះឃើញដោយប្រាជ្ញារបស់ខ្លួនឡើយ។ ព្រះគម្ពីរក៏បានសរសេរយ៉ាងសំខាន់ពីប្រវត្តិសាស្ត្រចាប់តាំងពីដើមដំបូងនៃការបង្កបង្កើតរបស់សព្វសារពើ រហូតដល់លោកអ័ប្រាហាំ ពីលោកអ័ប្រាហាំ រហូតដល់កំណើតរបស់ព្រះយេស៊ូវគ្រីស្ទ ពីកំណើតរបស់ព្រះយេស៊ូវគ្រីស្ទ រហូតដល់ចុងបញ្ចប់នៃសម័យពួកសាវកក្នុងកំឡុងឆ្នាំ១០០ គ. ស.។ ព្រះគម្ពីរវិវរណៈ បានបើកសំដែងពីព្រឹត្តិការណ៍សំខាន់ៗ ដែលបានទាយទុក ហើយនឹងត្រូវកើតឡើង នៅចុងបញ្ចប់នៃសម័យពួកសាវក រហូតដល់ការយាងត្រឡប់មកផែនដីនេះវិញរបស់ព្រះយេស៊ូវគ្រីស្ទ នឹង ការបង្កើតនគររបស់ព្រះវរបិតា នៅផែនដីនេះឡើងវិញ។

ព្រះគម្ពីរសញ្ញាចាស់ នឹងសញ្ញាថ្មី គឺជាគ្រឹះនៃចំណេះដឹង។ ព្រះគម្ពីរបង្រៀនឲ្យយល់ពីសេចក្តីសង្គ្រោះ

តាមរយៈព្រះយេស៊ូវគ្រីស្ទ នឹងបង្រៀនឲ្យមនុស្សយល់ពីរបៀបរស់នៅក្នុងផ្លូវនៃជីវិតរបស់ព្រះអម្ចាស់។ គ្រីស្ទានពិតម្នាក់ៗ ត្រូវរស់នៅដោយពឹងអាងលើព្រះបន្ទូលរបស់ព្រះទាំងស្រុង ក៏ដូចពួកជំនុំពិតរបស់ព្រះអង្គដែរ។

គម្ពីរយោង:

១. ២ធីម៉ូថេ៣:១៦-១៧
២. ចោទិយកថា៨:៣
៣. ទំនុកដំកើង១១៩
៤. ទំនុកដំកើង១២:៦
៥. ទំនុកដំកើង១៩:៧-៩
៦. ម៉ាថាយ១:១-១៧
៧. អេភេសូរ២:១៩-២០
៨. យ៉ូហាន៦:៦៣
៩. ១កូរិនថូស១៤:៣៧
១០. វិវរណៈ១:១-៣
១១. វិវរណៈ២២:១៨-១៩
១២. ២ពេត្រុស១:២-២១
១៣. ទំនុកដំកើង១១១:៧-១០
១៤. ម៉ាថាយ៤:៤
១៥. សុភាសិត៣០:៥
១៦. កាឡាទី១:៨-១២
១៧. លូកា៤:៤
១៨. ២ធីម៉ូថេ១:៩-១៤

# ៥. ច្បាប់ នឹង បញ្ញត្តិរបស់ព្រះ

## ៥ក. លក្ខណៈនៃច្បាប់របស់ព្រះ

ច្បាប់ នឹង បញ្ញត្តិរបស់ព្រះ ត្រូវបានសរសេរទុកនៅក្នុងគម្ពីរសញ្ញាចាស់ នឹង ក្នុងគម្ពីរសញ្ញាថ្មី គឺជាគោលការដ៏បរិសុទ្ធ នឹងគ្រប់លក្ខណ៍ ល្អឥតខ្ចោះ ដោយសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់។ ច្បាប់ នឹង បញ្ញត្តិរបស់ព្រះអម្ចាស់បានបង្កើតឡើង ដើម្បីបង្រៀនមនុស្សពីរបៀបស្រឡាញ់ ការថ្វាយបង្គំព្រះ នឹងបង្រៀនពីរបៀបស្រឡាញ់ដល់អ្នកជិតខាងខ្លួន។ ព្រះអម្ចាស់បានសំដែងឲ្យពិភពលោកស្គាល់ច្បាប់ នឹងបញ្ញត្តិរបស់ទ្រង់ចាប់តាំងពីដើមដំបូង ហើយតម្រូវឲ្យមនុស្សទាំងអស់រក្សានូវច្បាប់ នឹងបញ្ញត្តិទាំងអស់នោះ។ ច្បាប់ នឹង បញ្ញត្តិរបស់ព្រះសំដែងថា អំពើបាបជាអ្វី ហើយកន្លែងណាដែលគ្មានក្រិតវិន័យ នោះក៏ឥតមានអំពើបាបដែរ។ ប្រសិនបើព្រះអម្ចាស់មិនតម្រូវឲ្យមនុស្សទាំងអស់នៅលើពិភពលោកនេះ រក្សាច្បាប់ នឹង បញ្ញត្តិរបស់ទ្រង់ទេ នោះ

មនុស្សគ្មានបាបសោះ។ ព្រះគម្ពីរបានសំដែងថា ព្រះអម្ចាស់ទ្រង់នឹងជំនុំជំរះមនុស្សទាំងអស់ នៅលើពិភពលោកនេះ ទៅតាមការស្តាប់បង្គាប់ ឬមិនស្តាប់បង្គាប់ តាមបញ្ញត្តិ ច្បាប់របស់ទ្រង់។ ការស្តាប់បង្គាប់នាំមកនូវព្រះពរ នឹងការមិនស្តាប់បង្គាប់នាំមកនូវបណ្តាសា។ ដោយសារអំពើបាប នឹងអំពើអាក្រក់ នៅជំនាន់លោកណូអេ ព្រះបានបំផ្លាញផែនដី មនុស្ស នឹងរបស់សព្វសារពើដោយទឹកជំនន់ ប្រជាជនក្រុងសូដុំម នឹង កូម៉ូរ៉ាត្រូវបានបំផ្លាញដោយសារភ្លើង ពីព្រោះពួកគេបានធ្វើបាបយ៉ាងធ្ងន់ធ្ងរនៅចំពោះព្រះអម្ចាស់។ ប្រជាជននៅក្រុងនីនីវេ ជាសាសន៍ដទៃ ឥតមានទំនាក់ទំនងជាមួយនឹងព្រះអម្ចាស់ទេ ប៉ុន្តែព្រះអម្ចាស់ព្រមានពួកគេតាមរយៈហោរាយ៉ូណាសថា ការជំនុំជំរះទោសពីអំពើបាប កំពុងរង់ចាំគេ។ ប្រជាជនកាណានត្រូវបានបណ្តេញចេញពីទឹកដីរបស់ខ្លួន ដោយព្រោះអំពើបាបខាងសាសនា នឹងសេចក្តីកំផិតរបស់ពួកគេ។ ប្រជារាស្ត្រសាសន៍អ៊ីស្រាអែល ជាសាសន៍ដែលព្រះអម្ចាស់បានជ្រើសរើស ក៏បានធ្វើបាបយ៉ាងធ្ងន់ទាស់នឹងព្រះអម្ចាស់ខ្លាំងណាស់ដែរ ហើយក៏ត្រូវបាននិរទេសទៅជាឈ្លើយនៅប្រទេសដទៃដែរ ដោយព្រោះអំពើបាប នឹងការមិនស្តាប់បង្គាប់តាមច្បាប់នឹងបញ្ញត្តិរបស់ព្រះអម្ចាស់។ លោកីយទាំងមូលជាប់មានទោសនៅចំពោះព្រះអម្ចាស់ ពីជំនាន់មួយទៅជំនាន់ មួយទៀត បានធ្លាក់ទៅក្នុងអំពើបាប ដែលជាមរដករបស់មនុស្ស នឹងបរាជ័យទាំងស្រុងក្នុងការបំពេញតាមបញ្ញត្តិ ច្បាប់ ដែលព្រះអម្ចាស់បញ្ជាឲ្យមនុស្សទាំងអស់ប្រព្រឹត្តិតាមច្បាប់ នឹងបញ្ញត្តិក្នុងលិខិតនៃច្បាប់ [ច្បាប់ នឹង បញ្ញត្តិខាងសាច់ឈាម] ព្រះអង្គទ្រង់សព្វព្រះហឫទ័យឲ្យមនុស្សម្នាក់ៗ រៀនថ្វាយបង្គំទ្រង់ដោយវិញ្ញាណនៃច្បាប់។ គោលបំណងនៃច្បាប់ខាងវិញ្ញាណរបស់ព្រះអម្ចាស់ គឺឲ្យមនុស្សម្នាក់ៗ ស្រឡាញ់ដល់ព្រះអម្ចាស់ ជាព្រះនៃឯង ឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង អត់អំពីគំនិត ហើយអស់អំពីកំឡាំងនៃឯង ហើយត្រូវស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង។ ព្រះគម្ពីរបានសំដែងថា ការស្តាប់បង្គាប់តាមច្បាប់ នឹងបញ្ញត្តិរបស់ព្រះដោយវិញ្ញាណ គឺជាលក្ខណៈមួយសំរាប់ទទួលបានជីវិតអស់កល្ប។

ការស្តាប់បង្គាប់តាមរយៈអំណោយទាននៃវិញ្ញាណបរិសុទ្ធរបស់ព្រះ ទើបអាចស្តាប់បង្គាប់តាមច្បាប់ នឹងបញ្ញត្តិរបស់ព្រះអម្ចាស់បាន ដោយព្រោះព្រះអម្ចាស់បានដាក់ក្រិត្យវិន័យនៅក្នុងចិត្ត ហើយនឹងកត់ទុកនៅក្នុងគំនិតគេផង ដែលគេអាចនឹងរៀនស្តាប់បង្គាប់ នឹងដើរដោយវិញ្ញាណ តាមរយៈអំណាចនៃវិញ្ញាណបរិសុទ្ធរបស់ព្រះ។ ច្បាប់ នឹង បញ្ញត្តិរបស់ព្រះអម្ចាស់មិនជំនាស់ទៅនឹងព្រះគុណ នឹងសេចក្តីជំនឿទេ ប៉ុន្តែ នឹងជួយបង្កើតសេចក្តីជំនឿពិតវិញ។

គម្ពីរយោង:

១. លោកុប្បត្តិ៣:១-១៣ ១៨. រ៉ូម៤:១៣-១៦

២. លោកុប្បត្តិ២:៧-១១
៣. យេរេមា១៨:៧-១០
៤. ចោទិយកថា២៨:១-១៣
៥. រ៉ូម១០:៥
៦. ម៉ាថាយ២២:៣០-៤០
៧. យ៉ូហាន១៤:១៥-២៤
៨. ម៉ាថាយ៤:៤
៩. ម៉ាថាយ៥:១៧-២០
១០. ហេព្រើរ៨:១០-១២
១១. ហេព្រើរ១០:១៦-២២
១២. លោកុប្បត្តិ៦:៥-១៣
១៣. លោកុប្បត្តិ១៥:១៦
១៤. អេសេគាល២០:១១, ១៣, ២១
១៥. ចោទិយកថា៤:១-១៣
១៦. ចោទិយកថា៦:១-៤
១៧. រ៉ូម៣៩:២២
១៩. ទំនុកដំកើង១៩:១-៧
២០. ទំនុកដំកើង១១៩:១០
២១. អេសាយ៤២:២-១១
២២. ១យ៉ូហាន៥:២-៣
២៣. វិវរណៈ២២:១-៤
២៤. លេវីវិន័យ១៨:៥
២៥. សុភាសិត៤:៤
២៦. កាឡាទី៣:១១
២៧. រ៉ូម២:១១-១៣
២៨. ១យ៉ូហាន២:៤-៦
២៩. ១យ៉ូហាន៣:៤
៣០. ២ធីម៉ូថេ៣:១៦
៣១. វិវរណៈ១២:១៧
៣២. វិវរណៈ១៤:១២

## ៥១. បញ្ញត្តិដប់ប្រការ

ព្រះអម្ចាស់បានមានបន្ទូលពីបញ្ញត្តិ១០ប្រការទៅកាន់កូនចៅសាសន៍អ៊ីស្រាអែល។ បញ្ញត្តិ១០ប្រការ គឺជាមូលដ្ឋានគ្រឹះនៃគ្រប់ទាំងច្បាប់របស់ព្រះអម្ចាស់។ គ្រប់ច្បាប់ទាំងអស់ មានឥទ្ធិពលតាំងដើមដំបូងបង្អស់ នៃការបង្កើតមនុស្ស។ ប្រហែលជា៣០០០ឆ្នាំ មុនការប្រកាសប្រាប់ពីភ្នំស៊ីណាយ។ គោលបំណងនៃការសរសេរច្បាប់នេះ ក៏ជាច្បាប់សំរាប់ខាងវិញ្ញាណ ដែលមានអំណាចគ្រប់ពេលវេលាទាំងអស់ មិនថាមនុស្សដឹង ឬមិនដឹងនោះទេ។ ការស្ដាប់បង្គាប់តាមបញ្ញត្តិ នឹងច្បាប់ នាំមកនូវព្រះពរ ហើយការមិនស្ដាប់បង្គាប់តាម នាំមកនូវបណ្ដាសា។ បញ្ញត្តិ១០ប្រការបង្រៀនយើងពីរបៀបនៃសេចក្ដីស្រឡាញ់ទៅកាន់ព្រះអម្ចាស់ នឹងទៅកាន់មិត្តភ័ក្រនឹងអ្នកជិតខាង។ យើងត្រូវតែស្ដាប់តាមបញ្ញត្តិ១០ប្រការ គឺជាច្បាប់សំរាប់ទទួលជីវិតអស់កល្ប។

គម្ពីរយោង:

១. និក្ខមនំ២០:១-១៧
២. ម៉ាថាយ១៩:១៦-២២
៣. ១យ៉ូហាន៣:២២-២៤
៤. ហេព្រើរ ៨:៦-២១
៥. រ៉ូម៧:៧-១៤
៦. រ៉ូម១៣:៨-១០
៧. ហេព្រើរ៣០:១៥-២០
៨. ម៉ាថាយ២២:៣៦-៤០
៩. ២យ៉ូហាន ១៦-១០

## ៥គ. ថ្ងៃសប្ប័ទប្រចាំសប្តាហ៍

ថ្ងៃសប្ប័ទប្រចាំសប្តាហ៍ គឺជាថ្ងៃទី៧ បច្ចុប្បន្ននេះ ត្រូវបានគេស្គាល់ថា ជាថ្ងៃសៅរ៍ៗ កាលដើមដំបូងឡើយ ថ្ងៃសប្ប័ទត្រូវបានបង្កើតឡើងដោយព្រះអម្ចាស់ ទ្រង់បានប្រទានពរ និងញែកថ្ងៃទី៧ចេញជាបរិសុទ្ធ ទុកជាថ្ងៃដ៏ពិសេសសំរាប់សំរាក និងប្រកបជាមួយនឹងទ្រង់ៗ ថ្ងៃសប្ប័ទ គឺជាការចងចាំនៃការបង្កបង្កើត ផ្ទៃមេឃ ផែនដី សមុទ្រ និងរបស់សព្វសារពើសំរាប់មនុស្សៗ បញ្ញត្តនៃថ្ងៃឈប់សំរាក ឬ ថ្ងៃសប្ប័ទសំរាប់ថ្វាយបង្គំព្រះ បានតាំងឡើងជាង៣០០០ឆ្នាំ មុនដែលព្រះអម្ចាស់បានប្រទានបញ្ញត្តិ១០ប្រការ នៅឯភ្នំស៊ីណាយដល់កូនចៅសាសន៍អ៊ីស្រាអែលៗ បញ្ញត្តទី៤បានរំលឹកថា «ចូរឲ្យនឹកចាំពីថ្ងៃឈប់សំរាក... (ថ្ងៃសប្ប័ទ) ... ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ...»

ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាព្រះនៃគម្ពីរសញ្ញាចាស់ ទ្រង់បង្កើតថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទឡើង ហើយទ្រង់ក៏ឈប់សំរាកនៅថ្ងៃទី៧នោះ ទាំងប្រទានពរ និងញែកចេញទុកជាថ្ងៃបរិសុទ្ធៗ នៅក្នុងគម្ពីរសញ្ញាថ្មី ព្រះយេស៊ូវមានបន្ទូលថា ទ្រង់ជាម្ចាស់នៃថ្ងៃឈប់សំរាក ឬជាម្ចាស់នៃសប្ប័ទៗ ក្នុងកំឡុងពេលទ្រង់ធ្វើព័ន្ធកិច្ចនៅលើផែនដីនេះ ទ្រង់បានញែកថ្ងៃសប្ប័ទចេញជាថ្ងៃបរិសុទ្ធ ហើយបានបង្រៀនពីការប្រតិបត្តិតាមដ៏ត្រឹមត្រូវនៃថ្ងៃសប្ប័ទៗ ព្រះយេស៊ូវគ្រីស្ទផ្ទាល់អង្គទ្រង់បានបង្ហាញពីការប្រព្រឹត្តិត្រឹមត្រូវ និងធ្វើអំពើល្អនៅថ្ងៃសប្ប័ទ ថែមជាងនេះទៅទៀត ត្រូវឈប់ពីការងារគ្រប់ផ្នែក និងឈប់ការលក់ដូរគ្រប់ប្រភេទៗ សាវករបស់ព្រះយេស៊ូវ និងពួកជំនុំដំបូងៗ បានរក្សាថ្ងៃសប្ប័ទ និងបានបង្រៀនពួកជំនុំសាសន៍ដទៃឲ្យរក្សាថ្ងៃសប្ប័ទ យ៉ាងខ្ជាប់ខ្ជួនផងដែរៗ ការរក្សាថ្ងៃទី៧ ជាថ្ងៃសប្ប័ទ ជានិមិត្តសញ្ញានៃសេចក្តីស្រឡាញ់ដល់ព្រះអម្ចាស់ និងជាពស្ត្ររបស់ទ្រង់ៗ ព្រះអម្ចាស់ទ្រង់មានបន្ទូលថា ថ្ងៃសប្ប័ទចាប់ផ្តើមពីថ្ងៃលិចថ្ងៃសុក្រ រហូតដល់ថ្ងៃលិចថ្ងៃសៅរ៍ៗ នៅថ្ងៃបរិសុទ្ធ

អ្នកគ្រីស្ទានត្រូវបានបញ្ជាឲ្យឈប់សំរាកពីការងាររបស់ខ្លួន ដើម្បីថ្វាយបង្គំព្រះ នឹងទទួលសេចក្តីបង្រៀនរបស់ព្រះអម្ចាស់។ ការរក្សាថ្ងៃបរិសុទ្ធ ជាថ្ងៃទី៧ គឺជាការចំបាច់សំរាប់សេចក្តីសង្គ្រោះ នឹងការប្រកបពិតជាមួយនឹងព្រះដ៏ជាព្រះវរបិតា នឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

គម្ពីរយោង:

១. លោកុប្បត្តិ២:១-៣
២. និក្ខមនំ២០:៨-១១
៣. អេសាយ៥៨:១៣-១៤
៤. អេសាយ៦៦:២៣
៥. លេវីវិល័យ២៣:១-៣
៦. កិច្ចការ១៣:៤២-៤៤
៧. កិច្ចការ១៨:៤, ១១
៨. ហេព្រើរ៤:៤-១០
៩. ម៉ាកុស២:២៧-២៨
១០. និក្ខមនំ៣១:១៣-១៧
១១. អេសាយ៥៦:១-៧
១២. អេសេគាល២០:១២, ២០
១៣. លូកា៤:៤
១៤. កិច្ចការ១៧:២
១៥. កិច្ចការ១៩:៨-១០

## ៥ឃ. ថ្ងៃបុណ្យបរិសុទ្ធ នឹង ថ្ងៃបរិសុទ្ធប្រចាំឆ្នាំ

ព្រះគម្ពីរបង្រៀនថា មានបុណ្យបរិសុទ្ធ នឹងថ្ងៃបរិសុទ្ធប្រចាំឆ្នាំ ចំនួនប្រាំពីរ(៧) ដែលបានរៀបចំឡើងដោយព្រះអម្ចាស់ ជាបញ្ញត្តិមួយដ៏ពិសេសដែលបង្ហាញពីផែនការនៃសេចក្តីសង្គ្រោះរបស់ព្រះអម្ចាស់សំរាប់មនុស្ស ការប្រារព្វធ្វើបុណ្យទាំងអស់នោះ គឺជាទីសំគាល់រវាងព្រះអម្ចាស់នឹងរាស្ត្ររបស់ទ្រង់។ បុណ្យបរិសុទ្ធ នឹង ថ្ងៃបរិសុទ្ធប្រចាំឆ្នាំរបស់ព្រះអម្ចាស់ ត្រូវបានប្រារព្វធ្វើដោយរាស្ត្ររបស់ទ្រង់នៅជំនាន់គម្ពីរសញ្ញាចាស់។ នៅគម្ពីរសញ្ញាថ្មី ព្រះយេស៊ូវគ្រីស្ទ បានបង្រៀនពីបុណ្យបរិសុទ្ធទាំងអស់នោះ ជាវិញ្ញាណវិញ។ ពួកជំនុំនៅជំនាន់ពួកសាវកបានប្រារព្វធ្វើបុណ្យបរិសុទ្ធទាំងអស់នោះ យ៉ាងស្មោះត្រង់ទាំងអស់គ្នា។ ព្រះគម្ពីរបានចែងយ៉ាងច្បាស់ពីបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះ ពេលព្រះយេស៊ូវគ្រីស្ទយាងត្រឡប់មកផែនដីនេះវិញ មនុស្សទាំងអស់គ្នានឹងត្រូវប្រារព្វធ្វើបុណ្យរបស់ព្រះអម្ចាស់ទាំងអស់គ្នា។ ថ្ងៃបុណ្យបរិសុទ្ធទាំងអស់នោះ ជាថ្ងៃសប្ប័ទប្រចាំឆ្នាំ អាចត្រូវចំលើថ្ងៃណាមួយក្នុងសប្តាហ៍ ក៏បាន (លើកលែងតែថ្ងៃបុណ្យទី៥០ ដែលតែងតែប្រារព្វធ្វើនៅថ្ងៃអាទិត្យ) ថ្ងៃបុណ្យបរិសុទ្ធប្រចាំឆ្នាំ ពេលខ្លះត្រូវចំថ្ងៃសប្ប័ទប្រចាំសប្តាហ៍ បុណ្យនោះត្រូវតែប្រារព្វធ្វើ

ទៅតាមពេលកំណត់ៗ រាល់ថ្ងៃបុណ្យ គឺជាថ្ងៃបរិសុទ្ធរបស់ព្រះអម្ចាស់ ត្រូវចាប់តាំងកាន់ពីថ្ងៃលិចមួយ រហូតដល់ថ្ងៃលិចមួយទៀត គឺធ្វើតាមប្រតិទិនរបស់សាសន៍ហេព្រើរ ដែលបានរក្សាទុកដោយពួកលេវី នឹងពួកយូដា។

ខាងក្រោមនេះ ជាពិធីបុណ្យ នឹងថ្ងៃបរិសុទ្ធប្រចាំឆ្នាំទាំងប្រាំពីរ(៧) តាមកាលបរិច្ឆេទ នឹងតាមបញ្ញត្តិ ក្នុងព្រះគម្ពីរ។

១. បុណ្យរំលង. . . . . . . . . . . . . . . .ថ្ងៃទី១៤ ខែ១* (ថ្ងៃ ខែ ព្រះបានផ្ញើទុកនឹងពួកកូនចៅលេវី)

២. បុណ្យនំបុ័ងឥតដំបែ (៧ថ្ងៃ) . . . . . . .ថ្ងៃទី១៥ រហូត ដល់ថ្ងៃ២១ ខែទី១ (ថ្ងៃទី១៥ និង ថ្ងៃទី២១ , គឺជាថ្ងៃបរិសុទ្ធ)

៣. បុណ្យថ្ងៃទី៥០ ប្រារព្ធធ្វើជារៀងរាល់ឆ្នាំ**

៤. បុណ្យផ្លុំត្រែ .......... ថ្ងៃទី១ ខែ៧ .........(ថ្ងៃ ខែ ព្រះបានផ្ញើទុកនឹងពួកកូនចៅលេវី)

៥. ថ្ងៃឡធួននឹងបាប ថ្ងៃទី១០ ខែ៧ ..........(ថ្ងៃ ខែ ព្រះបានផ្ញើទុកនឹងពួកកូនចៅលេវី)

៦. បុណ្យបារាំ/ព្រះពន្លា (៧ថ្ងៃ) ថ្ងៃទី១៥ ដល់ ថ្ងៃទី២១ នៃខែ៧ .....(ថ្ងៃ ខែ ព្រះបានផ្ញើទុកនឹងពួកកូនចៅលេវី) (ថ្ងៃទី១៥ ជាថ្ងៃបរិសុទ្ធ)

៧. បុណ្យធំអស្ចារ្យ ថ្ងៃចុងក្រោយបំផុត ថ្ងៃទី២២ ខែ៧.... (ថ្ងៃ ខែ ព្រះផ្ញើទុកនឹងពួកកូនចៅលេវី) (ថ្ងៃទី២២ ជាថ្ងៃបរិសុទ្ធ)

*មិនមែនជាថ្ងៃបរិសុទ្ធ

**ថ្ងៃទី១៥ ថ្ងៃបុណ្យនំបុ័ងឥតដំបែ ថ្ងៃទី១ (ថ្ងៃ ខែ ព្រះបានផ្ញើទុកនឹងពួកកូនចៅលេវី) បុណ្យថ្ងៃទី៥០ ចាប់រាប់ពីថ្ងៃសប្បូទ នៃថ្ងៃបុណ្យនំបុ័ង សប្ដាហ៍ថ្ងៃទី១ រហូតដល់សប្ដាហ៍ទី៧ ៧x៧=៤៩ថ្ងៃ បូកនឹងថ្ងៃអាទិត្យ១ថ្ងៃទៀត ត្រូវជា៥០ថ្ងៃ (៤៩+១=៥០ថ្ងៃ)

គម្ពីរយោង:

១. លេវីវិន័យ២៣
២. និក្ខមនំ៣១:១៣
៣. យ៉ូហាន៧:៣៧
៤. ១កូរិនថូស៥:៧-៨
៨. និក្ខមនំ២៣:១៤-១៧
៩. និក្ខមនំ១២:១-២០
១០. ម៉ាថាយ២៦:១៧-១៨
១១. កិច្ចការ២:១

៥. កិច្ចការ១៨:២១ ១២. កិច្ចការ២០:១៦

៦. ១កូរិនថូស១៦:៨ ១៣. សាការី១៤:១៦-១៩

៧. អេសាយ៦៦:២៣

## ៦. អំពើបាប

អំពើបាបគឺជាការរំលងច្បាប់ នឹងបញ្ញត្តិដ៏បរិសុទ្ធរបស់ព្រះអម្ចាស់ មិនថាជាលិខិតនៃច្បាប់ ឬក៏ជាវិញ្ញាណនៃច្បាប់នោះទេ។ ដូច្នេះ អំពើបាបគឺជាការប្រព្រឹត្តិទទឹងច្បាប់ ឬប្រព្រឹត្តិរំលងច្បាប់។ អំពើបាបជាការសៅហ្មងដល់ចិត្ត នឹងគំនិតរបស់មនុស្សផងដែរ ពេលនរណាម្នាក់ដឹងពីការធ្វើអំពើល្អ ប៉ុន្តែ មិនធ្វើវា នោះថាជាអំពើបាបហើយ។ ការទទួលទោសរបស់អំពើបាប គឺជាសេចក្ដីស្លាប់ តែការប្រែចិត្តយ៉ាងជ្រាល ជ្រៅ ដោយស្មោះត្រង់ទៅឯព្រះអម្ចាស់ នោះទ្រង់នឹងអត់ទោសបាបឲ្យ ដោយសារសេចក្ដីជំនឿ ជឿដល់ព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ សំរាប់បងថ្លៃលោះបាបរបស់មនុស្សទាំងអស់ តាមរយៈសេចក្ដីមេត្តាករុណារបស់ព្រះដ៏ជាព្រះវរបិតា។ អំពើបាបដែលមិនអាចអត់ទោសឲ្យបាន គឺជាអំពើបាបដែលបដិសេធ ដោយចេតនា មិនព្រមទទួលសេចក្ដីសង្គ្រោះ នឹងប្រមាថដល់វិញ្ញាណបរិសុទ្ធរបស់ព្រះវរបិតា ហើយមើលងាយដល់ដង្វាយលោះបាបដ៏បរិសុទ្ធរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ទុកជារបស់មិនបរិសុទ្ធ។ អំពើបាប គឺការបដិសេធ ដោយចេតនា នឹងប្រមាថដល់វិញ្ញាណបរិសុទ្ធរបស់ព្រះវរបិតា នឹងថ្កោលទោសដល់ព័ន្ធកិច្ចរបស់ទ្រង់ ដែលទ្រង់បានបំពេញដោយអំណាយនៃវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដើម្បីនឹងបំផ្លាញការរបស់អារក្សសាតាំង នឹងលទ្ធផលនៃអំពើបាប។ ពេលអ្នកណាម្នាក់បានតាំងចិត្តធ្វើបាប ដែលមិនអាចអត់ទោសឲ្យបាន ចិត្តរបស់អ្នកនោះនឹងរឹងស្ងួតដូចជាផ្ទាំងអ៊ុតដ៏ក្ដៅ ហើយវិញ្ញាណបរិសុទ្ធរបស់ព្រះអម្ចាស់មិនអាច ក៏មិនអាចនាំចិត្តឲ្យអ្នកនោះប្រែចិត្តពីអំពើបាបបានទេ។ ការជំនុំជំរះសំរាប់អំពើបាប ដែលមិនអាចអត់ទោសឲ្យបាន នោះគឺសេចក្ដីស្លាប់ទីពីរ ឬក៏ជាសេចក្ដីស្លាប់អស់កល្ប ជាសេចក្ដីស្លាប់ដែលគ្មានសេចក្ដីរស់ឡើងវិញបានទេ។

គម្ពីរយោង:

១. ១យ៉ូហាន៣:៤ ១១. កិច្ចការ២:៣៨

២. ១យ៉ូហាន១:៥-២២ ១២. អេភេសូរ២:១-១០

៣. អេភេសូរ១:៧ ១៣.យ៉ាកុប២:១០-១១

៤. ១យ៉ូហាន៥:១៧
៥. កាឡាទី៥:១៩-២១
៦. រ៉ូម១៤:២៣
៧. ម៉ាថាយ១២:៣១-៣២
៨. កាឡាទី១:៨-៩
៩. វិវរណៈ២០:១៤-១៥
១០. រ៉ូម៧:១២-១៤
១៤. យ៉ាកុប៤:១២
១៥. រ៉ូម៦:២៣
១៦. កិច្ចការ៣:១៩
១៧. ហេព្រើរ៦:៤-៦
១៨. ហេព្រើរ១០:២៦-២៧
១៩. វិវរណៈ២១:៨

## ៧. វិញ្ញាណបរិសុទ្ធ

វិញ្ញាណបរិសុទ្ធមិនមែនជាតួអង្គព្រះទេ ក៏មិនមែនជាសមាជិកទីបីនៃព្រះដែរ ក៏មិនមែនដូចដែលពួកគ្រីស្តបរិស័ទបានប្រកាសនោះទេ។ វិញ្ញាណបរិសុទ្ធរបស់ព្រះ គឺជាអំណាចព្រះចេស្តាដែលព្រះវរបិតា នឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទប្រើ ដើម្បីសំរេចគ្រប់ការទាំងអស់តាមព្រះហឫទ័យទ្រង់។ ព្រះវរបិតាប្រទានវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ ដល់អស់អ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទម្នាក់ៗដោយឥតគិតថ្លៃ តាមរយៈការប្រែចិត្តពីអំពើបាបដោយស្មោះត្រង់ ទទួលបុណ្យជ្រមុជទឹក គឺជ្រមុជខ្លួនទៅក្នុងទឹកទាំងស្រុង បន្ទាប់មកដោយការដាក់ដៃលើអធិស្ឋាន វិញ្ញាណបរិសុទ្ធរបស់ព្រះក៏មកសណ្ឋិតនៅក្នុងអ្នកនោះ នឹងសន្យាពីជីវិតអស់កល្បជានិច្ចតាមរយៈព្រះយេស៊ូវគ្រីស្ទ។ វិញ្ញាណបរិសុទ្ធរបស់ព្រះ គឺជាអំណាចរបស់ព្រះអង្គ ដែលទ្រង់ប្រទានដល់កូនរបស់ព្រះអង្គម្នាក់ៗ ដើម្បីឲ្យមានចំណែកជាមួយនឹងព្រះគ្រីស្ទ នឹងបានចំរើនសេចក្តីស្រឡាញ់របស់ព្រះ មានអំណរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត ហើយដឹងខ្នាត...។ វត្តមាននៃវិញ្ញាណបរិសុទ្ធរបស់ព្រះ នឹងផ្តល់អំណាចឲ្យកូនរបស់ព្រះអង្គម្នាក់ៗ អាចរស់នៅទៅតាមព្រះហឫទ័យរបស់ព្រះអង្គ នឹងយកជ័យជំនះលើសេចក្តីល្បួង ដែលកើតមកពីនិស្ស័យជាមនុស្ស គឺជានិស្ស័យបាបពីកំណើតរបស់លោកីយ នឹងអារក្សសាតាំង។ អស់អ្នកដែលមានវិញ្ញាណបរិសុទ្ធរបស់ព្រះសណ្ឋិតនៅ តែងតែស្តាប់បង្គាប់ព្រះដ៏ជាព្រះវរបិតា នឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដើម្បីបំរើព្រះដោយវិញ្ញាណ នឹងដឹកនាំកូនប្រុស-ស្រីរបស់ព្រះអម្ចាស់ទៅក្នុងគ្រប់ទាំងសេចក្តីពិត ដែលបានសរសេរទុកក្នុងព្រះគម្ពីរទាំងមូល សំរាប់ឲ្យទទួលបានសេចក្តីសង្គ្រោះពិតប្រាកដ។

គម្ពីរយោង:

១. លោកុប្បត្តិ១:២
២. យ៉ូហាន១៤:១៦, ២៦
៣. ១កូរិនថូស២:៩-១០
៤. កិច្ចការ១៩:៦
៥. ២ធីម៉ូថេ១:៦-៧
៦. ២កូរិនថូស១:២១-២២
៧. យ៉ូហាន៧:៣៧-៣៩
៨. ១យ៉ូហាន៤:៤-៨
៩. កិច្ចការ២:៣៨
១០. រ៉ូម៨:៩-១៤
១១. កិច្ចការ៨:១៥-១៧
១២. កាឡាទី៥:២២-២៣
១៣. អេភេសូរ១:១៣-១៤
១៤. អេសាយ៥៥:១-៣
១៥. ១យ៉ូហាន៣:៩-១១
១៦. ២ពេត្រុស១:១-១១

## ៨. ព្រះគុណរបស់ព្រះអម្ចាស់

ព្រះគុណគឺជាអំណោយទានដោយឥតគិតថ្លៃរបស់ព្រះវរបិតា តាមរយៈព្រះយេស៊ូវគ្រីស្ទ មិនមែនកើតមកពីយើងរាល់គ្នានោះទេ។ ព្រះគុណរបស់ព្រះអម្ចាស់បានបង្ហាញពីសេចក្តីស្រឡាញ់ដ៏អស្ចារ្យ នឹងសេចក្តីមេត្តាករុណាដ៏លើសលប់របស់ផងព្រះដ៏ជាព្រះវរបិតា។ ព្រះគុណរបស់ព្រះ ធំជាងការអត់ទោសបាប។ នៅក្រោមព្រះគុណ គឺបន្តទទួលនូវសេចក្តីស្រឡាញ់ ព្រះពរ ការយកព្រះហឫទ័យទុកដាក់របស់ព្រះអង្គ ការពារ សប្បុរស ផលប្រយោជន៍ អំណោយទាន ទាំងអស់នោះ គឺមកតែពីព្រះអម្ចាស់ប៉ុណ្ណោះ។ ព្រះដ៏ជាព្រះវរបិតា ទ្រង់គឺជាប្រភពនៃព្រះគុណដែលផ្តល់ដល់អស់អ្នកជឿទ្រង់ នេះមានន័យថា ព្រះគុណត្រូវបានផ្តល់ដល់អស់អ្នកជឿទ្រង់ តាមរយៈការប្រសូត្រ ព្រះជន្ម ការឆ្កាងលើឈើឆ្កាង សេចក្តីសុគត នឹងមានព្រះជន្មរស់ពីសុគតឡើងវិញ របស់ព្រះយេស៊ូវគ្រីស្ទ ដែលជាដង្វាយដ៏គ្រប់លក្ខណ៍របស់ព្រះវរបិតា។ អ្នកជឿចូលទៅក្នុងព្រះគុណនៃព្រះអម្ចាស់ដោយមានសេចក្តីជំនឿជឿលើសេចក្តីសុគតរបស់ព្រះយេស៊ូវគ្រីស្ទ សំរាប់ការអត់បាបរបស់មនុស្សទាំងអស់។ ព្រះវរបិតាបានប្រទានព្រះគុណដល់អ្នកជឿម្នាក់ៗ ទៅតាមការប្រែចិត្តពីអំពើបាប នឹងទទួលបុណ្យជ្រមុជទឹក ដោយជ្រមុជខ្លួនទាំងស្រុងចូលទៅក្នុងទឹក ជាការបង្ហាញពីការប្រែចិត្ត ផ្នែកខាងក្រៅ។ តាមរយៈព្រះគុណ អំពើបាបរបស់អ្នកជឿ ត្រូវបានអត់ទោសឲ្យ ហើយទទួលបាននូវសេចក្តីសុចរិតរបស់ព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់ប្រទានដល់អ្នក។

ព្រះគុណ បង្កើតឲ្យមានការប្រកបដោយវិញ្ញាណរវាងអ្នកជឿ នឹងព្រះដ៏ជាព្រះវរបិតា ហើយនឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រាស្ងួនភ្ងារបស់ទ្រង់ ហើយក៏ទទួលកំណើតថ្មីខាងវិញ្ញាណ ជាកូនប្រុស កូនស្រីរបស់ព្រះវរបិតា នឹងទទួលបានជីវិតអស់កល្បជានិច្ច។

ព្រះគុណជាអំណោយទានដល់អស់អ្នកជឿ ដែលព្រះវរបិតាត្រាស់ហៅ ជ្រើសរើស អត់ទោសបាប ហើយទទួលជឿព្រះវរបិតា ដោយសារព្រះយេស៊ូវគ្រីស្ទព្រះរាជបុត្រាទ្រង់ ហើយទទួលបានអំណោយទានជាវិញ្ញាណបរិសុទ្ធរបស់ទ្រង់ នឹងបានជាកូនប្រុស កូនស្រីរបស់ព្រះអង្គ រស់ក្នុងនគរព្រះអស់កល្ប។ ព្រះគុណមិនបានផ្តល់អាជ្ញាប័ណ្ណ ឲ្យធ្វើបាប ធ្វើព្រងើយកន្តើយ នឹងបដិសេធបញ្ញត្តិ ច្បាប់របស់ព្រះអម្ចាស់នោះទេ។ អស់អ្នកដែលរក្សាបញ្ញត្តិ ដែលនៅជាប់ក្នុងសេចក្តីស្រឡាញ់ នឹងនៅជាប់ក្នុងព្រះគុណរបស់ព្រះអម្ចាស់។ អ្នកជឿម្នាក់ៗដែលបានទទួលព្រះគុណនៃព្រះអម្ចាស់ គឺមានកាតព្វកិច្ចផ្ទាល់ខ្លួនចំពោះព្រះវរបិតា នឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដើម្បីលះបង់ចោលនិស្ស័យចាស់ នឹងគំនិតបាបចោលចេញ ហើយត្រូវរស់នៅក្នុងជីវិតបែបថ្មី មានការរីកចំរើនជាប្រចាំថ្ងៃ នៅក្នុងព្រះគុណ នឹងចំណេះដឹងរបស់ព្រះយេស៊ូវគ្រីស្ទ។ ចំពោះអ្នកជឿដែលរស់នៅក្រោមព្រះគុណ នោះមានព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះ ជាសំដេចសង្ឃ នឹងជាអ្នកការពារ។ ប្រសិនអ្នកជឿប្រព្រឹត្តិអំពើបាប នោះព្រះយេស៊ូវគ្រីស្ទទ្រង់នឹងជួយអង្វរដល់ព្រះដ៏ជាព្រះវរបិតាជំនួសគេ សូមព្រះដ៏ជាព្រះវរបិតា សូមទ្រង់មេត្តាករុណាអត់ទោសអំពើបាប ដោយព្រះគុណទ្រង់។ ព្រះគុណរបស់ព្រះដ៏ជាព្រះវរបិតា ដែលទ្រង់ប្រទានមកយើងតាមរយៈព្រះយេស៊ូវគ្រីស្ទ ដើម្បីរក្សាអ្នកជឿដែលបានប្រែចិត្ត ឲ្យស្ថិតនៅក្នុងស្ថានភាពនៃការផុតបន្ទោសបាន នឹងភាពគ្មានអំពើបាប។

គម្ពីរយោង

| | |
|---|---|
| ១. អេភេសូរ២:៤-១០ | ១០. ១យ៉ូហាន៣:៦-៨ |
| ២. អេភេសូរ៤:៧ | ១១. រ៉ូម៣:២២-២៥ |
| ៣. រ៉ូម២:៤ | ១២. រ៉ូម៤:១-១៣ |
| ៤. រ៉ូម៥:១-១១, ១៥-១៨ | ១៣. កាឡាទី១:១៥ |
| ៥. ទំនុកដំកើង១០៣:២-៤ | ១៤. អេសាយ៥៥:៦-៧ |
| ៦. កាឡាទី៥:១-៤ | ១៥. លោកុប្បត្តិ៦:៨ |
| ៧. យូដាស ២៤, ២១ | ១៦. ១កូរិនថូស១៥:១០ |
| ៨. ២ធីម៉ូថេ១:៩ | ១៧. អេភេសូរ១:៣-៩ |

៩. អេភេសូរ៣:១-២១

១៨. ១ពេត្រុស៥:១០

# ៩. ការប្រែចិត្ត

ការប្រែចិត្តពីអំពើបាប អំពើបាបគឺជាវិប្បដិសារី ជាការទុក្ខព្រួយរបស់អ្នកណាម្នាក់ ដែលជាអ្នកប្រព្រឹត្តិប្រឆាំងនឹងច្បាប់ ហើយនឹងបញ្ញត្តិរបស់ព្រះ។ ការប្រែចិត្តពីអំពើបាប គឺជាជំហានទីមួយនៃការផ្សះផ្សា រវាងអ្នកមានបាប ទៅនឹងព្រះវរបិតា នឹងព្រះយេស៊ូវគ្រីស្ទ។ ការប្រែចិត្តពិតប្រាកដ ចាប់ផ្ដើមនៅពេលដែលព្រះវរបិតា បើកចិត្ត បើកគំនិតដល់អ្នក ឲ្យបានយល់ថា អ្នកជាមនុស្សមានបាប ប្រឆាំងនឹងព្រះវរបិតា ហើយអំពើបាបរបស់អ្នកផ្ទាល់ មានចំណែកក្នុងការធ្វើគុតព្រះយេស៊ូវគ្រីស្ទដែរ។ ព្រះគុណរបស់ព្រះវរបិតា បានដឹកនាំអ្នកឲ្យប្រែចិត្តពីអំពើបាប។ ការប្រែចិត្តពីអំពើបាប គឺយើងត្រូវសារភាពពីអំពើបាបរបស់ខ្លួន ទៅព្រះវរបិតា ហើយសូមការលើកលែងទោសសំរាប់អំពើបាបទាំងអស់ ដោយសារព្រះលោហិតរបស់ព្រះយេស៊ូវគ្រីស្ទ។ ការប្រែចិត្តពិតប្រាកដ ហើយជ្រាលជ្រៅ នឹងតាមបំណងព្រះហឫទ័យនៃព្រះអម្ចាស់ នឹងបង្កើតឲ្យមានការប្រែចិត្ត នឹងអនុប្បតិកិរិយាយល់ច្បាស់ពីការប្រែចិត្តដ៏ជ្រាលជ្រៅទៅឯព្រះ ដើម្បីឲ្យបានរស់នៅដោយសារគ្រប់ទាំងព្រះបន្ទូលរបស់ព្រះអម្ចាស់។ អស់អ្នកដែលប្រែចិត្តពិតប្រាកដ គឺមានការផ្លាស់ប្ដូរពីគំនិតអាក្រក់ នឹងការប្រព្រឹត្តប្រឆាំងនឹងព្រះចេញ ហើយស្វែងរកយល់ព្រះហឫទ័យរបស់ព្រះសំរាប់ជីវិតរបស់អ្នក ដែលបានសរសេរទុកនៅក្នុងព្រះគម្ពីរទាំងមូល ដោយវិញ្ញាណបរិសុទ្ធរបស់ព្រះបាននាំ។ ការប្រែចិត្ត នឹងការលន់តួបាបនៅតែកំពង់បន្តនៅក្នុងជីវិតរបស់អ្នកគ្រីស្ទាន ដើម្បីការរីកចំរើនខាងវិញ្ញាណ ឆ្ពោះទៅកាន់ភាពគ្រប់លក្ខណ៍របស់ព្រះយេស៊ូវគ្រីស្ទ។

គម្ពីរយោង:

១. រ៉ូម២:៤

២. ២កូរិនថូស៥:១៧

៣. កិច្ចការ៣:១៩

៤. លូកា១៣:៣, ៥

៥. កិច្ចការ១១:១៨

៦. លូកា២៤:៤៧

៨. កិច្ចការ២:៣៧-៣៨

៩. រ៉ូម៨:៥-៩

១០. យេរេមា១៧:៥-៩

១១. ២ធីម៉ូថេ២:២៥

១២. ១យ៉ូហាន១:៦-២:២

១៣. ២កូរិនថូស៧:៩-១១

៧. ម៉ាកុស១:១៥

១៤. យ៉ូហាន៦:៤៤-៤៥

# ១០. ពិធីបុណ្យជ្រមុជទឹក

ការប្រែចិត្តពិតប្រាកដ នឹងទទួលព្រះយេស៊ូវគ្រីស្ទជាព្រះអង្គសង្គ្រោះផ្ទាល់ខ្លួន អ្នកជឿត្រូវតែទទួលបុណ្យជ្រមុជទឹក ដោយជ្រមុជចូលទៅក្នុងទឹកសំរាប់ការអត់ទោសបាបរបស់ខ្លួន។ ការជ្រមុជទឹកគឺជានិមិត្តរូបនៃសេចក្ដីស្លាប់ នឹងកប់ជីវិតចាស់នៃអ្នកជឿពិតទៅក្នុងទឹក ជាគំរូពីសេចក្ដីសុគតរបស់ព្រះយេស៊ូវគ្រីស្ទ ខ្ចាយព្រះលោហិត ដើម្បីសង្គ្រោះយើង។ ពេលងើបពីទឹកឡើងវិញ បុរស ឬ ស្ត្រី គឺត្រូវដើរក្នុងជីវិតបែបថ្មី។ ដើម្បីឲ្យបានត្រឡប់ជាមនុស្សថ្មី។ អ្នកជឿដែលទទួលបុណ្យជ្រមុជទឹកម្នាក់ៗ ត្រូវទទួលបានអំណោយទានជាវិញ្ញាណបរិសុទ្ធរបស់ព្រះ ដោយការអធិស្ឋានដាក់ដៃលើ។ បន្ទាប់មក អ្នកជឿម្នាក់ៗ ត្រូវបានវិញ្ញាណបរិសុទ្ធរបស់ព្រះដឹកនាំឲ្យបានដើរក្នុងសេចក្ដីស្រឡាញ់ ស្ដាប់បង្គាប់ព្រះដ៏ជាព្រះវរបិតា នឹងមានសេចក្ដិជំនឿ ជឿព្រះយេស៊ូវគ្រីស្ទ។

គម្ពីរយោង:

១. កិច្ចការ២:៣៨

២. ម៉ាថាយ២៨:១៩-២០

៣. កិច្ចការ៨:១២-១៧

៤. ម៉ាថាយ៣:១៣-១៦

៥. កូល៉ុស២:១២

៦. រ៉ូម៦:៣-១៣

# ១១. ការរាប់ជាសុចរិត

ការរាប់ជាសុចរិត គឺត្រូវបានផ្ដល់ឲ្យដល់អ្នកដែលព្រះវរបិតាបានត្រាស់ហៅ ប្រែចិត្តពីអំពើបាប ជឿព្រះជាព្រះវរបិតា តាមរយៈយញ្ញបូជារបស់ព្រះយេស៊ូវគ្រីស្ទ នោះនឹងទទួលបានសេចក្ដីសុចរិត ដោយឥតគិតថ្លៃ។ ការរាប់ជាសុចរិតកើតឡើង នៅពេលដែលបាបរបស់អ្នកជឿ ត្រូវបានសំអាតដោយសារព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ ហើយបុរស នឹង ស្ត្រី បានទទួលសិទ្ធិអាចឈរនៅចំពោះព្រះវរបិតាបាន។ សេចក្ដីសុចរិតនេះ ត្រូវបានហៅថា «អំណោយទាននៃសេចក្ដីសុចរិត» ពីព្រោះព្រះដ៏ជាព្រះវរបិតាទ្រង់ប្រទានសេចក្ដីសុចរិតរបស់ព្រះយេស៊ូវគ្រីស្ទ ដល់អ្នកជឿទ្រង់។

គម្ពីរយោង:

១. រ៉ូម២:១៣ ៤. រ៉ូម៤:៥-៨, ២៤-២៥

២. រ៉ូម៣:២៤-៣១ ៥. ១កូរិនថូស៦:១១

៣. រ៉ូម៥:១-១០, ១៧-២១ ៦. រ៉ូម៨:២៨-៣០

# ១២. ភាពសុចរិត

## ១២ក. ភាពសុចរិតនៃច្បាប់

ព្រះអម្ចាស់ទ្រង់គឺជាព្រះដែលបង្កើតរបស់សព្វសារពើ ហើយទ្រង់ក៏បង្កើតច្បាប់សំរាប់របស់សព្វសារពើផងដែរ។ ពេលព្រះអម្ចាស់បង្កើតមនុស្ស ទ្រង់ក៏បង្កើតច្បាប់ដ៏សុចរិតសំរាប់គ្រប់គ្រង នឹងទំនាក់ទំនងរវាងមនុស្សជាមួយនឹងព្រះ ហើយជាមួយមនុស្ស នឹងមនុស្សដូចគ្នា។ ច្បាប់របស់ព្រះអម្ចាស់ បានគូសបន្ទាត់យ៉ាងច្បាស់រវាងសកម្មភាពល្អ នឹងសេចក្តីសុចរិតនៅក្នុងព្រះនេត្រនៃព្រះអម្ចាស់ ទៅនឹងសកម្មភាពប្រឆាំងអំពើទុច្ចរិត នឹងអំពើបាប។ បើសិនជាគ្មានច្បាប់ នឹងក្រិត្យវិន័យរបស់ព្រះទេ នោះក៏គ្មានអំពើបាបដែរ។ ព្រះគម្ពីរបានសំដែងថា «...ដ្បិតកន្លែងណាដែលគ្មានក្រិត្យវិន័យ នោះក៏ឥតមានសេចក្តីរំលងដែរ» ដោយសារក្រិត្យវិន័យ គឺជាចំណេះដឹងនៃអំពើបាប។ អំពើបាបបន្តពីអ័ដាម នឹងអេវ៉ា ហើយមនុស្សដែលកើតមកក្នុងលោកីយនេះមានកាតព្វកិច្ចយ៉ាងច្បាស់ថា ត្រូវតែប្រព្រឹត្តតាមច្បាប់របស់ព្រះអង្គ តាំងពីដើមដំបូង។ នៅជំនាន់គម្ពីរសញ្ញាចាស់ បុរស ឬស្ត្រី ដែលបានរក្សាបញ្ញត្តិ នឹងច្បាប់របស់ទ្រង់នៅក្នុងលិខិតនៃច្បាប់ គឺត្រូវបានរាប់ជាសុចរិតនៅចំពោះព្រះអម្ចាស់។ ប្រភេទនៃភាពសុចរិតនេះ ដែលបានមកតាមរយៈការប្រព្រឹត្តតាមច្បាប់ បាននាំមកនូវព្រះពរខាងសាច់ឈាម នឹងសម្ភារៈ រួមទាំងសុខភាព នឹងភាពចំរុងចំរើន ការរំដោះឲ្យរួចពីពួកខ្មាំងសត្រូវ នឹងសេចក្តីសុខសាន្ត នឹងមានអាយុយឺនយូរ។ ព្រះអម្ចាស់ទ្រង់ស្រឡាញ់ពួកកូនចៅសាសន៍អ៊ីស្រាអែល ហើយទ្រង់ក៏មានព្រះបន្ទូលមកពួកគេតាមរយៈលោកម៉ូសេថា អស់អ្នកដែលរក្សាច្បាប់ នឹងបញ្ញត្តិរបស់ទ្រង់ នឹងរស់នៅតាមបញ្ញត្តិ នោះពួកគេនឹងរួចពីទណ្ឌកម្ម នឹងបណ្តាសា ដែលបានកំណត់ទុកសំរាប់ពួកអ្នករំលងច្បាប់ នឹងបញ្ញត្តិ រួមបញ្ចូលទាំងសេចក្តីស្លាប់ ដោយសារទណ្ឌកម្មនោះផងដែរ។ ទោះជាភាពសុចរិតនៃច្បាប់ ដោយសារការប្រព្រឹត្តតាមលិខិតនៃច្បាប់ នោះមិនអាចទទួលបានសេចក្តីសង្គ្រោះនោះទេ។ ព្រះអម្ចាស់ទ្រង់បានសន្យាប្រទានសេចក្តីសង្គ្រោះ នឹងជីវិតអស់កល្បជានិច្ច គឺជាអំណោយទានដែលប្រទានមកយើងរាល់

គ្នា ដោយឥតគិតថ្លៃ ដោយសារសេចក្តីជំនឿពិត ដែលយើងរាល់គ្នាមិនសមនឹងទទួលនោះទេ។ ភាពសុចរិតបានប្រទានមកយើងរាល់គ្នាដោយសារសេចក្តីជំនឿពិតតែប៉ុណ្ណោះ។ ភាពសុចរិតនៃច្បាប់ ទាមទារឲ្យយើងរៀន ឬបង្ហាត់បង្រៀនយើងឲ្យស្គាល់អំពើបាប ហើយនឹងសេចក្តីកំសោយរបស់យើង ដែលជាលក្ខណ៍របស់មនុស្ស យើងត្រូវការសេចក្តីសុចរិតនៃជំនឿ។

គម្ពីរយោង:

១. លោកុប្បត្តិ៣:១១-១៣
២. លោកុប្បត្តិ៦:៥-១៣
៣. លេវីវិន័យ១៨:៥
៤. អេសេគាល២០:១១, ១៣, ២១
៥. ចោទិយកថា២៨:១-១៣
៦. ចោទយកថា៦:១-៤
៧. រ៉ូម១០:៥
៨. រ៉ូម៤:១៣-១៦
៩. លោកុប្បត្តិ៤:៧-១១
១០. លោកុប្បត្តិ១៥:១៦
១១. យេរេមា១៨:៧-១០
១២. សុភាសិត៤:៤
១៣. ចោទិយកថា៤:១-១៣
១៤. កាឡាទី៣:១១
១៥. រ៉ូម៣:៩-២២
១៦. រ៉ូម២:១១-១៣

## ១២ខ. ភាពសុចរិតនៃជំនឿ

ភាពសុចរិតនៃសេចក្តីជំនឿ គឺជាអំណោយទាននៃភាពសុចរិតរបស់ព្រះអម្ចាស់ ដែលអ្នកជឿទទួលបានបានតាមរយៈព្រះគុណយ៉ាងបរិបូរណ៍របស់ព្រះវរបិតា ដែលត្រូវបានហៅថា « ភាពសុចរិតនៃជំនឿ» ពីព្រោះតាមរយៈសេចក្តីជំនឿជឿលើព្រះយេស៊ូវគ្រីស្ទ ទើបអាចរួមចំណែកនៃភាពសុចរិតនេះបាន។ ពេលអ្នកជឿបានរាប់ជាសុចរិតដោយសារសេចក្តីជំនឿ ជឿលើព្រះយេស៊ូវគ្រីស្ទ នឹងទទួលបានអំណោយទានជាវិញ្ញាណបរិសុទ្ធពីព្រះវរបិតា ដែលទ្រង់ប្រទានភាពសុចរិតនៃព្រះយេស៊ូវគ្រីស្ទដល់អ្នកជឿ « ភាពសុចរិតនៃព្រះគុណ

ដែលអាចទទួលបានជីវិតអស់កល្ប តាមរយៈសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ» ការប្រទានភាពសុចរិតនេះ

គឺជាអំណោយទានរបស់ព្រះអម្ចាស់ដល់អស់អ្នកជឿព្រះយេស៊ូវគ្រីស្ទ មិនមែនមកពីការប្រព្រឹត្តតាមក្រិត្យវិន័យនោះទេ។ សេចក្ដីសុចរិតនៃព្រះយេស៊ូវគ្រីស្ទ ដែលប្រទានដល់អស់អ្នកជឿទ្រង់ គឺមកអំពីព្រះដ៏ជាព្រះវរបិតា ពិសេសជាងសេចក្ដីសុចរិតរបស់លិខិតនៃច្បាប់។ នៅក្នុងសេចក្ដីសុចរិតដ៏គ្រប់លក្ខណ៍នេះ ព្រះយេស៊ូវគ្រីស្ទ ទ្រង់បានរក្សាគ្រប់អស់ទាំងលិខិតនៃច្បាប់ ហើយទ្រង់ក៏បានបំពេញគ្រប់ទាំងបទបញ្ញត្តិរបស់ព្រះវរបិតា នៅក្នុងវិញ្ញាណនៃច្បាប់ផងដែរ។ ការស្ដាប់បង្គាប់ខាងវិញ្ញាណរបស់ព្រះយេស៊ូវគ្រីស្ទ គឺគ្រប់លក្ខណ៍ បរិសុទ្ធ នឹងអស់អំពីព្រះហឫទ័យរបស់ព្រះអង្គ ដែលទ្រង់តែងតែធ្វើកិច្ចការទាំងដែលគាប់ដល់ព្រះហឫទ័យនៃព្រះវរបិតាទ្រង់។ ភាពសុចរិតដ៏គ្រប់លក្ខណ៍ខាងឯវិញ្ញាណដែលមិនអាចរាប់បាននេះ គឺត្រូវបានបំពេញដោយអំណាចនៃវិញ្ញាណបរិសុទ្ធ ដែលទ្រង់បានទទួលមកពីព្រះវរបិតានៃទ្រង់។ តាមរយៈគំរូរបស់ទ្រង់ផ្ទាល់ ហើយនឹងការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ បានបង្ហាញពីច្បាប់ នឹងបញ្ញត្តិរបស់ព្រះអម្ចាស់ នឹងការបើកសំដែងពីភាពពេញនៃគោលបំណងនឹងអត្ថន័យរបស់ច្បាប់ទាំងអស់នោះ។ ព្រះអម្ចាស់ទ្រង់បង្រៀនថា វិញ្ញាណនៃច្បាប់មិនអាចធ្វើឲ្យលិខិតនៃច្បាប់ទៅជាមោឃៈបានទេ ប៉ុន្តែ ទាមទារឲ្យប្រព្រឹត្តឲ្យបានពេញលេញឡើង គឺការស្ដាប់បង្គាប់ដោយវិញ្ញាណ។ ការស្ដាប់បង្គាប់ដោយវិញ្ញាណ គឺហួសពីសមត្ថភាពនៃចិត្ត គំនិត នឹងឆន្ទៈរបស់មនុស្ស ប៉ុន្តែ អាចសំរេចបានដោយមានសេចក្ដីជំនឿជឿព្រះយេស៊ូវតែប៉ុណ្ណោះ។ ព្រះគម្ពីរបានសម្ដែងថា ពេលអ្នកជឿបានទទួលវិញ្ញាណបរិសុទ្ធរបស់ព្រះវរបិតា នោះអ្នកជឿចាប់ផ្ដើមមានចិត្ត គំនិតរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងចិត្ត ក្នុងគំនិត អ្នកជឿត្រូវបានចំរើនសេចក្ដីជំនឿ ដើម្បីអាចរស់នៅតាមគ្រប់ទាំងព្រះបន្ទូល នៃព្រះអម្ចាស់ នៅក្នុងវិញ្ញាណនៃច្បាប់ មិនត្រឹមតែក្នុងលិខិតនៃច្បាប់ប៉ុណ្ណោះទេ។ ជាមួយនឹងព្រះគ្រីស្ទគង់ក្នុងចិត្ត គឺអ្នកមានសេចក្ដីសង្ឃឹមនៃសិរីរុងរឿង អ្នកជឿចាប់ផ្ដើមមានច្បាប់ នឹងបញ្ញត្តិនៃព្រះអម្ចាស់ ដាក់នៅក្នុងចិត្ត នឹងកត់ទុកនៅក្នុងគំនិត ហេតុដូច្នេះហើយ ច្បាប់ នឹងបញ្ញត្តិរបស់ព្រះអម្ចាស់ ត្រូវបានសំរេចដោយភាពពេញលេញ។ អត្ថន័យផ្នែកវិញ្ញាណបរិសុទ្ធរបស់ព្រះ តាមរយៈព្រះគុណនឹងអំណោយទាននៃភាពសុចរិតនៃសេចក្ដីជំនឿ ភាពសុចរិតខាងវិញ្ញាណ ដែលព្រះអម្ចាស់បានប្រទានដល់អ្នកជឿ បានផ្ដល់ឲ្យនូវអំណាច ដើម្បីបង្កើតផលផ្លែខាងវិញ្ញាណ ដែលអាចទទួលជីវិតអស់កល្បជានិច្ចបាន តាមរយៈភាពសុចរិតនៃជំនឿ អ្នកជឿត្រូវបានបំពេញតាមព្រះគម្ពីរយ៉ាងពិតប្រាកដ «មនុស្សសុចរិតនឹងរស់ ដោយអាងសេចក្ដីជំនឿ»

គម្ពីរយោង:

១. រ៉ូម៤:៣-៨, ១៣-២៤

២. រ៉ូម៣:២០-៣១

៧. រ៉ូម៥:១៧-២១

៨. កាឡាទី២:២០-២១

៣. កាឡាទី៥:១៦, ១៨, ២២-២៥
៤. រ៉ូម៧:៦
៥. ហេព្រើរ១០:១៦
៦. កាឡាទី៣:១១
៩. កូល៉ុស១:២៧-២៨
១០. ហេព្រើរ៨:១០
១១. ក៏លីព២:៥, ១៣

## ១៣. ការញែកចេញជាបរិសុទ្ធ

ការញែកចេញជាបរិសុទ្ធ គឺជាសកម្មភាពនៃការញែកចេញអ្នកណាម្នាក់ ឬជារបស់អ្វីមួយចេញដោយឡែក សំរាប់ប្រើប្រាស់ នឹងសំរាប់គោលបំណងបរិសុទ្ធ។ គ្រីស្ទានកំពុងស្ថិតនៅក្នុងស្ថានភាពនៃការញែកចេញជាបរិសុទ្ធ បន្ទាប់ពីការប្រែចិត្ត ទទួលបុណ្យជ្រមុជចូលទៅក្នុងទឹក ពេលងើបពីទឹកឡើងវិញ ដោយការអធិស្ឋានដាក់ដៃលើ នោះនឹងទទួលបានវិញ្ញាណបរិសុទ្ធរបស់ព្រះវរបិតា មកសណ្ឋិតនៅក្នុងជីវិតថ្មីរបស់អ្នក។ នៅក្នុងព្រះគម្ពីរ អស់អ្នកជឿ ដែលបានទទួលបុណ្យជ្រមុជទឹក បានត្រូវញែកចេញជាបរិសុទ្ធ ដោយសារព្រះដ៏ជាព្រះវរបិតា។

គម្ពីរយោង:

១. ១កូរិនថូស១:២
២. ២ថែស្សាឡូនីច២:១៣-១៤
៣. និក្ខមនំ៣១:១៣
៤. លេវីវិន័យ២១:១, ៨
៥. យេរេមា១:៥
៦. អេភេសូរ៥:២៥-២៧
៧. ១កូរិនថូស៦:១១
៨. និក្ខមនំ៤០:៩-១៣
៩. អេភេសូរ១:៣-៤
១០. យ៉ូហាន១៧:១៥-១៩

## ១៤. ការជ្រមុជដោយវិញ្ញាណ

ការជ្រមុជដោយវិញ្ញាណ គឺជាសកម្មភាពនៃការទទួលវិញ្ញាណបរិសុទ្ធរបស់ព្រះវរបិតា មកក្នុងជីវិត។ វិញ្ញាណបរិសុទ្ធរបស់ព្រះ បានប្រទានដល់អ្នកជឿម្នាក់ៗ តាមរយៈការអធិស្ឋានដាក់ដៃលើ បន្ទាប់ពីជ្រមុជទឹករួច។ តាមការទទួលអំណោយទាននៃវិញ្ញាណបរិសុទ្ធរបស់ព្រះអម្ចាស់ អ្នកជឿបានជាកូនប្រុស កូនស្រីរបស់ព្រះវរបិតា។ ការជ្រមុជដោយវិញ្ញាណ អ្នកជឿបានត្រូវរាប់បញ្ចូលទៅក្នុងពួកជំនុំខាងវិញ្ញាណនៃព្រះអម្ចាស់

ជាកូនប្រុស កូនស្រីខាងវិញ្ញាណរបស់ទ្រង់។

គម្ពីរយោង:

១. ម៉ាថាយ៣:១១
២. កិច្ចការ៨:១៥
៣. ១កូរិនថូស២:១
៤. ១ពេត្រុស១:៣
៥. កិច្ចការ២:៣៨
៦. កិច្ចការ១៩:៦
៧. រ៉ូម៨:៩-១៦
៨. ១យ៉ូហាន៣:៩, ២៤

## ១៥. សេចក្តីជំនឿ

សេចក្តីជំនឿ គឺជាចំណេះដឹង និងជឿលើសកម្ម នៅក្នុងវត្តមាន និងអំណាចនៃព្រះដ៏ជាព្រះវរបិតាទ្រង់មានព្រះជន្មគង់នៅ ហើយនឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រាទ្រង់ គង់នៅអស់កល្បៗ សេចក្តីជំនឿគឺជាអំណោយទានដែលមកពីព្រះអម្ចាស់ និងជាផលផ្លែនៃវិញ្ញាណបរិសុទ្ធរបស់ទ្រង់ តាមរយៈអំណោយទាននៃវិញ្ញាណបរិសុទ្ធដែលបានទទួលពីព្រះវរបិតាមក។ វត្តមាននៃព្រះយេស៊ូវគ្រីស្ទ និងសេចក្តីជំនឿរបស់ទ្រង់ ត្រូវបានប្រទានដល់អ្នកជឿទ្រង់ពិត។ សេចក្តីជំនឿ គឺជឿជាក់ដោយវិញ្ញាណ លើសេចក្តីសន្យារបស់ព្រះអម្ចាស់ ថាទ្រង់នឹងធ្វើឲ្យសំរេចបាន។ ផលផ្លែនៃសេចក្តីសុចរិតនៅក្នុងជីវិតរបស់អ្នកជឿពិត នឹងបន្តនៅក្នុងសេចក្តីជំនឿរបស់ព្រះយេស៊ូវគ្រីស្ទ ដែលបានប្រទានមកយើងរាល់គ្នា ដោយព្រះអង្គទ្រង់។ ដោយសារសេចក្តីជំនឿ យើងបានធ្វើការល្អ ដែលព្រះវរបិតាទ្រង់បានអនុម័តតាមរយៈព្រះយេស៊ូវគ្រីស្ទ។ ជំនឿដ៏សកម្ម នឹងជំនឿរស់ នោះមានសារៈសំខាន់ណាស់សំរាប់ទទួលសេចក្តីសង្គ្រោះតាមរយៈព្រះគុណ។ ជំនឿ បើមិនបានធ្វើការល្អទេ នោះគឺជាជំនឿស្លាប់។ បើគ្មានសេចក្តីជំនឿទេ នោះការល្អដែលយើងធ្វើ ក៏គ្មានតម្លៃនៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់ដែរ។ កិច្ចការ និងអំពើល្អ មិនអាចឲ្យយើងទទួលបានសេចក្តីសង្គ្រោះ និងជីវិតអស់កល្បជានិច្ចបាននោះទេ ប៉ុន្តែសេចក្តីជំនឿពិតនឹងបង្កើតឲ្យធ្វើការល្អនៅក្នុងជីវិតរបស់យើង។ ទង្វើល្អ ដែលបានធ្វើដោយសេចក្តីជំនឿ មិនមែនជាបុព្វហេតុសំរាប់សេចក្តីសង្គ្រោះទេ សេចក្តីសង្គ្រោះគឺជាអំណោយទានរបស់ព្រះអម្ចាស់ប្រទានដល់អ្នកជឿពិតវិញ។

គម្ពីរយោង:

១. ហេព្រើរ១១:១-៦
២. កាឡាទី២:២០
៣. រ៉ូម៤:២០-២១
៤. ១ពេត្រុស១:១-៩
៥. ភីលីព១:៦
៦. ទីតុស១:១៦
៧. វិវរណៈ១៤:១២
៨. លូកា៧:៥០
៩. កាឡាទី៥:២២
១០. អេភេសូរ២:៤-១០
១១. យ៉ាកុប២:១៤-២២
១២. រ៉ូម១:១៧
១៣. ភីលីព៣:៣-១៩
១៤. ១កូរិនថូស១៣:២
១៥. ម៉ាថាយ៨:១៣
១៦. យ៉ាកុប៥:១៤-១៥

## ១៦. សេចក្តីសង្គ្រោះ

សេចក្តីសង្គ្រោះគឺជាអំណោយទានរបស់ព្រះវរបិតា តាមរយៈព្រះគុណទ្រង់ ដែលបានប្រទានដល់អ្នកជឿព្រះយេស៊ូវគ្រីស្ទ។ សេចក្តីសង្គ្រោះមិនអាចទទួលបានតាមរយការប្រព្រឹត្តិតាមបញ្ញត្តិនោះទេ ប៉ុន្តែត្រូវតែរក្សាច្បាប់ នឹងបញ្ញត្តិ ដើម្បីទទួលបានអំណោយទាននៃសេចក្តីសង្គ្រោះ។ ព្រះអម្ចាស់តម្រូវឲ្យមានការប្រែចិត្តពីអំពើបាប ព្រះគម្ពីរបានចែងថា អំពើបាប «គឺជាការរំលងក្រិត្យវិន័យ» ហើយជឿព្រះយេស៊ូវគ្រីស្ទ ទទួលព្រះលោហិតរបស់ព្រះរាជបុត្រានៃព្រះអម្ចាស់ សំរាប់សងថ្លៃលោះអំពើបាបរបស់មនុស្ស។ ព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃព្រះ ទ្រង់ជាមេនៃសេចក្តីសង្គ្រោះដ៏នៅអស់កល្បជានិច្ច ដល់អស់អ្នកដែលជឿទ្រង់។ តាមរយៈការលះបង់ដ៏ធំធេង នឹងព្រះលោហិតរបស់ទ្រង់ អ្នកជឿទ្រង់ពិត នឹងបានផ្សះផ្សាជាមួយព្រះដ៏ជាព្រះវរបិតាវិញ ហើយអំពើបាបរបស់អ្នកនោះបានត្រូវអត់ទោសឲ្យ ដោយសារព្រះគុណរបស់ព្រះអម្ចាស់។ អ្នកជឿពិតបានទទួលសេចក្តីសង្គ្រោះឲ្យរួចពីទោសនៃអំពើបាប ដែលជាសេចក្តីស្លាប់អស់កល្បជានិច្ច។ សេចក្តីសង្គ្រោះចាប់ផ្តើម ពេលព្រះវរបិតា បើកគំនិតអ្នក ឲ្យយល់ដោយវិញ្ញាណ ដែលអាចនាំទៅដល់ការប្រែចិត្ត ទៅឯព្រះ មានសេចក្តីជំនឿជឿព្រះយេស៊ូវគ្រីស្ទ ទទួលទ្រង់ជាព្រះអង្គសង្គ្រោះផ្ទាល់ខ្លួន។ បន្ទាប់ពីទទួលជ្រមុជចូលទៅក្នុងទឹក ពេលងើបឡើងពីទឹកវិញ ដោយការអធិស្ឋានដាក់ដៃលើ ដើម្បីឲ្យបានទទួលអំណោយទានជាវិញ្ញាណ

បរិសុទ្ធ មកពីព្រះដ៏ជាព្រះវរបិតា។ អ្នកនឹងចាប់ផ្តើមដើរក្នុងជីវិតបែបថ្មី ដោយស្តាប់បង្គាប់តាមព្រះគ្រប់ពេលវេលា។ ហើយត្រូវបង្ហើយសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នា ដោយអំណាចនៃវិញ្ញាណបរិសុទ្ធ នឹងព្រះបន្ទូលដែលទ្រង់ប្រទានមកយើងរាល់គ្នាផង។ ព្រះគម្ពីរបានសំដែងថា សេចក្តីសង្គ្រោះ មានដំណាក់កាលបី(៣) ផ្សេងៗគ្នា ក្នុងដំណើរនៃសេចក្តីសង្គ្រោះ៖

១) អ្នកជឿត្រូវបានសង្គ្រោះរួចពីអំពើបាបពីអតិតកាល នឹងពីអារក្សសាតាំងដែលជាវិញ្ញាណអាក្រក់ គ្រប់គ្រងលើអាកាស (អេភេសូរ២:១-១០)

២) អ្នកជឿកំពុងត្រូវបានសង្គ្រោះ ដោយបន្តនៅក្នុងព្រះបន្ទូលរបស់ព្រះ គឺជាដំណឹងល្អ សេចក្តីស្រឡាញ់ ស្តាប់បង្គាប់ នឹងសេចក្តីជំនឿ (១កូរិនថូស១:១៨; ១៥:២)

៣) អ្នកជឿត្រូវបានសង្គ្រោះដោយប្រោសឲ្យរស់ពីស្លាប់ឡើងវិញ នៅថ្ងៃចុងក្រោយបំផុត (រ៉ូម៧:២៤-២៥; ១កូរិនថូស១៥:១២-៥៧; ១ធីម៉ូថេ៣:១៤-១៦)

សេចក្តីសង្គ្រោះរបស់អ្នកជឿព្រះអម្ចាស់មិនទាន់បានពេញលេញនៅឡើយទេ រហូតដល់ថ្ងៃបានត្រូវប្រោសឲ្យរស់ពីស្លាប់ឡើងវិញ គឺកើតជាថ្មី កើតជាវិញ្ញាណដោយអំណាចនៃព្រះអម្ចាស់។ រស់ពីស្លាប់ឡើងវិញជាវិញ្ញាណ ដែលយើងអាចទៅជាគ្រួសារនៃព្រះអម្ចាស់បាន។ ក្នុងពេលវេលារបស់ព្រះអម្ចាស់ នឹងផែនការនៃសេចក្តីសង្គ្រោះរបស់ទ្រង់ដល់មនុស្សទាំងអស់ នោះមនុស្សម្នាក់ៗនឹងមានឱកាសទទួលសេចក្តីសង្គ្រោះ។

គម្ពីរយោង:

១. អេភេសូរ២:៤-១០
២. ២កូរិនថូស៧:១០
៣. រ៉ូម២:៤
៤. ១ថែស្សាឡូនីច៤:១៤-១៧
៥. ១កូរិនថូស១៥:៤២-៥២
៦. កិច្ចការ១១:១៨
៧. ម៉ាកុស១៦:១៦
៨. រ៉ូម៤:២១-២៥
៩. ហេព្រើរ១២:១-៤
១០. រ៉ូម៦:២៣
១១. យ៉ូហាន៦:៤៤-៤៥
១២. រ៉ូម៦:៤-៦
១៣. ហេព្រើរ១:១-៦
១៤. កិច្ចការ៨:១២, ១៥-១៧
១៥. ១ធីម៉ូថេ២:៤
១៦. រ៉ូម៥:៦-១០
១៧. កិច្ចការ១៩:៥-៦
១៨. វិវរណៈ២០:៦

## ១៧. ការអធិស្ឋានដាក់ដៃលើ

ការអធិស្ឋានដាក់ដៃលើ គឺជាភារៈកិច្ចដ៏ពិសេសដែលធ្វើដោយចាស់ទុំ បន្ទាប់ពីឡើងពីទឹកមកវិញ (លើកលែងតែពិធីជ្រមុជទឹក ដែលធ្វើទៅដោយអ្នកដែលបានចាក់ប្រេងតាំងដោយចាស់ទុំ ដើម្បីជ្រមុជទឹក។ នៅក្នុងពួកជំនុំរបស់ព្រះអម្ចាស់ តែងតែអធិស្ឋានដាក់ដៃលើអ្នកទទួលជ្រមុជទឹក ទូលសូមដល់ព្រះដ៏ជាព្រះវរបិតា សូមទ្រង់ប្រទានវិញ្ញាណបរិសុទ្ធរបស់ទ្រង់មកសណ្ឋិតនៅក្នុងជីវិតអស់អ្នកដែលទទួលជ្រមុជទឹក ដើម្បីមានអំណាចអាចប្រោសជម្ងឺ ជាមួយនឹងប្រេងនឹងសំរាប់ប្រោសឲ្យជា សំរាប់ប្រទានពរដល់ពួកក្មេងៗ សំរាប់ប្រទានពរដ៏ពិសេសក្នុងពិធីមង្គលការ នឹងសំរាប់ព្រះពរដ៏ពិសេសផ្សេងៗទៀត។

គម្ពីរយោង:

១. កិច្ចការ៨:១៥-១៧ ២. កិច្ចការ១៩:៥-៦ ៣. យ៉ាកុប៥:១៤-១៥
៤. ម៉ាកុស១៦:១៧-១៨ ៥. ម៉ាថាយ១៩:១៣-១៥ ៦. កិច្ចការ៦:៦; ១៣:៣

## ១៨. ការប្រោសឲ្យជា

ព្រះគម្ពីរសម្តែងថា ពេលខ្លះព្រះអម្ចាស់អនុញ្ញាតិឲ្យមានជម្ងឺដល់អ្នកណាម្នាក់ សំរាប់គោលបំណងពិសេសណាមួយ។ ជម្ងឺដែលយើងមាន គឺជាលទ្ធផលនៃអំពើបាបខាងសាច់ឈាម ក៏អាចជាអំពើបាបខាងវិញ្ញាណផងដែរ។ ការប្រោសឲ្យជា គឺជាការដ៏អស្ចារ្យ ដែលព្រះអម្ចាស់បានអត់ទោសបាបទាំងអស់របស់យើង ទាំងប្រោសជម្ងឺឲ្យជាផង។ ព្រះដ៏ជាព្រះវរបិតាទ្រង់ធ្វើអន្តរាគមន៍ផ្ទាល់ព្រះអង្គទ្រង់ ដោយព្យាបាលដល់អស់អ្នកដែលអំពាវនាវដល់ទ្រង់ សូមទ្រង់ប្រោសនៅពេលមានជម្ងឺ ឬ នៅពេលមានរបួស។ អន្តរាគមន៍ដ៏អស្ចារ្យដោយព្រះចេស្តារបស់ព្រះអម្ចាស់ នឹងកើតមានដល់អ្នកណាម្នាក់ ទៅតាមបំណងព្រះហឫទ័យរបស់ព្រះអង្គ ពីព្រោះព្រះយេស៊ូវគ្រីស្ទ បានបង់ថ្លៃលោះសំរាប់ការប្រោសឲ្យជាពីគ្រប់ជម្ងឺ ដោយស្នាមរំពាត់នៅលើអង្គទ្រង់មុនពេលគេឆ្កាងព្រះអង្គ។ ពេលព្រះអម្ចាស់ទ្រង់ប្រោសឲ្យយើងជា ទ្រង់ក៏បានអត់ទោសបាបរបស់យើងរាល់គ្នា ដោយសារស្នាមរបួសនៃព្រះយេស៊ូវគ្រីស្ទដែរ។ ការអស្ចារ្យនៃការប្រោសឲ្យជាពីជម្ងឺ ត្រូវបានប្រទានមកជាញឹកញាប់។ ព្រះគម្ពីរបានបង្រៀនយើងថា បើអ្នកចង់ទទួលបានការប្រោសឲ្យជាពីជម្ងឺ នោះអ្នកត្រូវហៅពួកចាស់ទុំក្នុងពួកជំនុំមកអធិស្ឋានឲ្យ ព្រមទាំងលាបប្រេងឲ្យផង ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ នឹងអធិស្ឋានដោយជំនឿ សូមព្រះអម្ចាស់ធ្វើអន្តរាគមន៍ នឹងប្រោសឲ្យជា។ ការទុកចិត្តព្រះអម្ចាស់ដោយជំនឿសំរាប់ការប្រោសឲ្យជា គឺជាបញ្ហាផ្ទាល់ខ្លួនរវាងអ្នកជឿ នឹងព្រះអម្ចាស់។

គម្ពីរយោង:

១. និក្ខមនំ១៥:២៦
២. ម៉ាថាយ៩:២៧-៣០
៣. ១កូរិនថូស១១:២៣-៣០
៤. យ៉ាកុប៥:១៤-១៦
៥. ម៉ាកុស១៦:១៥-១៨
៦. យ៉ូហាន៩:១-១១
៧. ទំនុកដំកើង១០៣:២-៣
៨. ១ពេត្រុស២:២៤
៩. ម៉ាថាយ៨:១-១៧
១០. អេសាយ៥៣:៤-៥
១១. ២កូរិនថូស១២:៧-១០

# ១៩. ពួកជំនុំរបស់ព្រះអម្ចាស់

## ១៩ក. រូបអង្គជាវិញ្ញាណរបស់ព្រះយេស៊ូវ

ពួកជំនុំនៃព្រះអម្ចាស់ បានចែងទុកនៅក្នុងព្រះគម្ពីរបរិសុទ្ធ គឺជារូបអង្គនៃព្រះយេស៊ូវគ្រីស្ទ ខាងវិញ្ញាណ។ ព្រះដ៏ជាព្រះវរបិតាបានតាំងព្រះយេស៊ូវជាសិរសាលើគ្រប់ទាំងពួកជំនុំរបស់ទ្រង់។ ពួកជំនុំពិតរបស់ព្រះអម្ចាស់ ត្រូវបានបង្កើតឡើងដោយអស់អ្នកដែលព្រះវរបិតាបានត្រាស់ហៅ គឺជាអស់អ្នកដែលទទួលព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រាទ្រង់ ធ្វើជាព្រះអង្គសង្គ្រោះផ្ទាល់ខ្លួន នឹងអស់អ្នកដែលប្រែចិត្តពីអំពើបាប ទទួលបុណ្យជ្រមុជទឹក ហើយទទួលបានវិញ្ញាណបរិសុទ្ធរបស់ព្រះដ៏ជាព្រះវរបិតា អ្នកទាំងអស់នោះជាបងប្អូនស្ងួនភ្ងាខាងវិញ្ញាណ នឹងជាសមាជិកនៃពួកជំនុំរបស់ព្រះយេស៊ូវគ្រីស្ទ ជាវិញ្ញាណ។ ទោះជាពួកគេបានបែកខ្ញែកគ្នាទៅពាសពេញក្នុងពិភពលោកក៏ដោយ ក៏ជាវិញ្ញាណបរិសុទ្ធនៃព្រះវរបិតា តែមួយដែលបានប្រទានដល់អស់អ្នកដែលបានទទួលបុណ្យជ្រមុជទឹក គឺបានទទួលជ្រមុជចូលទៅក្នុងសេចក្តីសុគតរបស់ព្រះយេស៊ូវគ្រីស្ទ។ ការទំនាក់ទំនងខាងវិញ្ញាណជាមួយនឹងព្រះយេស៊ូវគ្រីស្ទ នឹងជាមួយព្រះដ៏ជាព្រះវរបិតា គឺជាមូលដ្ឋានគ្រឹះនៃការប្រកបដ៏ពិតនៃពួកជំនុំរបស់ព្រះអង្គ ព្រះយេស៊ូវគ្រីស្ទមានបន្ទូលថា «ខ្ញុំជាដើមទំពាំងបាយជូរដ៏ពិត ហើយព្រះវរបិតាខ្ញុំជាអ្នកដាំ» ពួកជំនុំពិតទាំងអស់គ្នាជាខ្នែងនៃដើមទំពាំងបាយជូរពិត ហើយត្រូវនៅជាប់នឹងដើម ដើម្បីបានរីកចំរើនខាងឯវិញ្ញាណ។

នៅពេលយើងមានរូបអង្គនៃព្រះយេស៊ូវគ្រីស្ទជាវិញ្ញាណ សមាជិកជាវិញ្ញាណរបស់រូបអង្គព្រះយេស៊ូវគ្រីស្ទ ត្រូវបានចល័តទៅកន្លែងផ្សេងៗ នៅលើពិភពលោក ទៅតាមព័ន្ធកិច្ចនីមួយៗ ដោយព្រោះយើងជារូបអង្គរបស់ព្រះគ្រីស្ទ មានវិញ្ញាណបរិសុទ្ធដែលព្រះវរបិតាប្រទាន។ ព្រះអម្ចាស់មិនបានកំណត់អង្គទ្រង់ ដើម្បីធ្វើការតាមរយៈអង្គការណាមួយនោះទេ។ អ្នកបំរើព្រះគ្រប់រូប ឬ អ្នកបំរើព័ន្ធកិច្ចណាមួយ ដែលជាផ្នែកនៃរូបអង្គរបស់ព្រះគ្រីស្ទ នឹងបង្កើតផលផ្លែខាងវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ ឲ្យព្រះនាមរបស់ព្រះអម្ចាស់បានពុទ្ធខ្ចរខ្ចាយឡើង ហើយនឹងឲ្យមនុស្សបានរក្សាបញ្ញត្តិរបស់ព្រះអង្គ ដូចដែលព្រះយេស៊ូវគ្រីស្ទបានបង្រៀន។ តួនាទីសំខាន់របស់ពួកជំនុំពិតរបស់ព្រះអម្ចាស់ គឺត្រូវថែរក្សាបងប្អូនស្ងួនភ្ងារបស់ព្រះយេស៊ូវគ្រីស្ទ ជាមួយនឹងការចែកចាយអាហារខាងវិញ្ញាណ គឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ដើម្បីឲ្យបងប្អូនបានចំរើនធំឡើង រហូតដល់ភាពពោរពេញ នឹងមានគំនិត គិតដូចជាព្រះគ្រីស្ទយេស៊ូវផង។ ពួកជំនុំពិតក៏មានបេសកកម្មពីព្រះអម្ចាស់ដែរ គឺផ្សាយដំណឹងល្អពិត ពីនគរព្រះ នឹងពីរដ្ឋាភិបាលរបស់ព្រះអង្គ ទៅជុំវិញពិភពលោក បង្រៀនពីការប្រែចិត្ត ពីអំពើបាប នឹងវិលទៅឯព្រះយេស៊ូវគ្រីស្ទវិញ ដើម្បីទទួលបានសេចក្ដីសង្គ្រោះ។ រដ្ឋាភិបាលរបស់ព្រះអម្ចាស់នឹងត្រូវតាំងឡើងនៅផែនដីនេះ នៅពេលព្រះយេស៊ូវគ្រីស្ទយាងត្រឡប់មកផែនដីនេះវិញ។

គម្ពីរយោង:

១. អេភេសូរ១:២២-២៣
២. អេភេសូរ៤:៤-៦, ១១-១៦
៣. ១កូរិនថូស១២:៦-១៣
៤. ម៉ាថាយ២៤:១៤
៥. យ៉ូហាន១៥:១៨
៦. វិវរណៈ១:១២-២០
៧. យ៉ូហាន២១:១៥-១៧
៨. ម៉ាថាយ២៨:១៨-២០
៩. កិច្ចការ២:៤៧
១០. រ៉ូម៨:៩, ២៨-២៩
១១. ហេព្រើរ២:៩-១៨

## ១៩១. ព័ន្ធកិច្ចរបស់ពួកជំនុំសញ្ញាថ្មីនៃព្រះអម្ចាស់

ពួកជំនុំសញ្ញាថ្មីរបស់ព្រះអម្ចាស់មានព័ន្ធកិច្ច គឺចូលរួមបង្ហាត់បង្រៀនព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ ដូចដែលបានសរសេរទុកក្នុងព្រះគម្ពីរសញ្ញាថ្មី។ អស់អ្នកដែលបំរើក្នុងព័ន្ធកិច្ចនេះ មិនលើកដំកើងខ្លួនឯងឲ្យខ្ពស់ជាងបងប្អូនស្ងួនភ្ងា ដោយប្រើអំណាច ឬ ឋានៈរបស់ខ្លួននោះទេ ប៉ុន្តែ ត្រូវព្យាយាមបំរើបងប្អូនស្ងួន

គ្នា ដោយមានចិត្តសុភាព និងដោយសេចក្តីស្រឡាញ់វិញ។ ពួកចាស់ទុំនៃពួកជំនុំសញ្ញាថ្មី ដែលបានចាក់ប្រេងតាំង យល់ថាការត្រាស់ហៅដោយព្រះអម្ចាស់ ដើម្បីឲ្យបំរើផ្នែកខាងវិញ្ញាណ ដោយបំពេញសេចក្តីត្រូវការរបស់បងប្អូនស្ងួនភ្ងាខាងឯវិញ្ញាណ។ អ្នកចាស់ទុំ អាចជាគ្រូគង្វាល ជាគ្រូបង្រៀន ជាអ្នកផ្សាយដំណឹងល្អ ឬនៅក្នុងផ្នែកផ្សេងៗ តាមសេចក្តីត្រូវការ។ ភារៈកិច្ចដែលចាស់ទុំត្រូវបំពេញ យោងទៅតាមអំណោយទានដែលព្រះគ្រីស្ទប្រទាន គុណសម្បត្តិរបស់ចាស់ទុំ បានសរសេរទុកនៅក្នុងគម្ពីរ១ធីម៉ូថេ៣ និងទីតុស១។ សេចក្តីស្រឡាញ់ចំពោះបងប្អូនស្ងួនភ្ងារបស់ព្រះវរបិតា និងព្រះអម្ចាស់យេស៊ូវគ្រីស្ទ គឺជាកស្តុតាងដែលព្រះអម្ចាស់ទ្រង់បានត្រាស់ហៅអ្នក ហើយចាក់ប្រេងតាំងជាចាស់ទុំ។ ចាស់ទុំដែលបានចាក់ប្រេងតាំង ត្រូវតែរក្សាអកប្បកិរិយា នៃការផ្លាស់ប្រែពិត និងការប្តេជ្ញាចិត្តចំពោះព្រះដ៏ជាព្រះវរបិតា ,និងព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ចាស់ទុំមានភារៈកិច្ចស្អាងពួកជំនុំនៃព្រះដែលជារូបអង្គនៃព្រះគ្រីស្ទ។ ភារៈកិច្ចរបស់ចាស់ទុំ គឺទទួលខុសត្រូវក្នុងការបង្រៀនគោលលទ្ធិត្រឹមត្រូវដែលគម្ពីរបានសរសេរទុក ដើម្បីបំរើសេចក្តីត្រូវការខាងឯវិញ្ញាណរបស់បងប្អូនស្ងួនភ្ងា ហើយក៏ជាអ្នកដឹកនាំពួកជំនុំនៅក្នុងដំបន់ផងៗ គោលបំណងរបស់ព័ន្ធកិច្ចនេះ គឺចាស់ទុំទទួលការខុសត្រូវក្នុងការប្រកាសដំណឹងល្អពិត របស់ព្រះយេស៊ូវគ្រីស្ទ ដល់អស់អ្នកដែលមិនទាន់ជឿព្រះយេស៊ូវ និងបង្រៀនពួកគេនឹងធ្វើបុណ្យជ្រមុជទឹកឲ្យ ដល់គ្រប់អស់ទាំងសាសន៍។

គម្ពីរយោង:

១. យ៉ូហាន១៥:១៦
២. ម៉ាថាយ២៨:១៩-២០
៣. ១ធីម៉ូថេ៣:១-៧
៤. យ៉ូហាន២១:១៥-១៧
៥. អេភេសូរ៤:១១-១៣
៦. ហេព្រើរ១៣:៧-១៧
៧. កិច្ចការ១៣:៣
៨. កិច្ចការ១៤:២៣
៩. ២ធីម៉ូថេ៣:១៤
១០. យេរេមា២៣:២៨
១១. ម៉ាថាយ២០:២០-២៨
១២. ទីតុស១:៥-៩
១៣. ១ពេត្រុស៥:១-១០
១៤. ម៉ាថាយ២៤:១៤
១៥. យ៉ូហាន១៣:១៤-១៦
១៦. លូកា២២:២៤-២៦
១៧. ១ធីម៉ូថេ៥:២២
១៨. ២ធីម៉ូថេ២:១-៤, ១៤-២៦
១៩. ២ធីម៉ូថេ៤:៤

# ២០. គ្រីស្ទានទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ

## ២០ក. ទទួលខុសត្រូវចំពោះគ្រួសារ

ព្រះគម្ពីរបានបង្រៀនថា គ្រីស្ទានត្រូវតែផ្គត់ផ្គង់សំរាប់គ្រួសាររបស់ខ្លួន។ គ្រីស្ទានណាដែលអាចធ្វើការងារបាន ប៉ុន្តែមិនខិតខំជួយផ្គត់ផ្គង់ដល់គ្រួសាររបស់ខ្លួន គឺអ្នកនោះអាក្រក់ជាងអ្នកមិនជឿសាសនាទៅទៀត ព្រះយេស៊ូវគ្រីស្ទផ្ទាល់បង្រៀនថា គ្រីស្ទានត្រូវតែផ្គត់ផ្គង់ដល់គ្រួសាររបស់ខ្លួន ជាមុនសិន មិនត្រូវប្រើបរិការនោះ សំរាប់គោលបំណងណាផ្សេងទៀត រួមបញ្ចូលទាំងដង្វាយថ្វាយទៅព្រះផង។ ព្រះយេស៊ូវទ្រង់បន្ទោសដល់ពួកអាចារ្យ នឹងពួកផារីស៊ី ពីព្រោះពួកគេបោះបង់ចោលការផ្គត់ផ្គង់ដល់ឪពុក ម្តាយ ដោយនិយាយថា «...របស់អ្វីដែលនឹងជួយដល់ឪពុក ម្តាយ នោះបានថ្វាយទៅព្រះហើយ» ព្រះអម្ចាស់ទ្រង់មិនសព្វព្រះហឫទ័យឲ្យអ្នកគ្រីស្ទានបោះបង់ការផ្គត់ផ្គង់ជាចាំបាច់សំរាប់គ្រួសារ ដើម្បីដាក់ដង្វាយ១ភាគ ក្នុង១០ នឹងដង្វាយស្ម័គ្រចិត្តថ្វាយដល់ព្រះនោះទេ។ គ្រីស្ទានដែលប្រាក់ចំណូលមានកំណត់ ត្រូវផ្គត់ផ្គង់សេចក្តីត្រូវការក្នុងគ្រួសារជាមុន។ ព្រះអម្ចាស់ទ្រង់មានព្រះហឫទ័យមេត្តាករុណាណាស់ ទ្រង់នឹងមិនសព្វព្រះហឫទ័យចង់បានដង្វាយនោះទេ។

គម្ពីរយោង

១. ១ធីម៉ូថេ៥:៤, ៨, ១៦
២. សុភាសិត៣១:១០-២៨
៣. សុភាសិត២៨:១៩
៤. ម៉ាកុស៧:១០-១៣
៥. សុភាសិត២៧:២៣-២៧

## ២០ខ. ទទួលខុសត្រូវចំពោះជនក្រីក្រ

ព្រះយេស៊ូវគ្រីស្ទបានបង្គាប់ឲ្យអ្នកគ្រីស្ទានជួយផ្គត់ផ្គង់ដល់អ្នកក្រីក្រ នឹងអ្នកដែលត្រូវការក្នុងចំណោមពួកបងប្អូន ដោយសេចក្តីក្តួលអាណិត នឹងដោយការយល់ដឹង។ អកប្បកិរិយានៃសេចក្តីស្រឡាញ់ពិត នឹងការបំរើរបស់អ្នកគ្រីស្ទាន គឺជាមូលដ្ឋានគ្រឹះសំរាប់គ្រប់ការទាំងអស់។ ព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យនឹងប្រទានពរបានចំរើនឡើង ដល់អស់អ្នកដែលផ្តល់ជំនួយដោយឆន្ទៈស្មោះត្រង់ ដែលអាចនឹងធ្វើទៅបានដោយសេចក្តីស្រឡាញ់។ ចំពោះអស់អ្នកដែលមានសមបត្តិបរិបូរណ៍ ប៉ុន្តែមិនចេះផ្គត់ផ្គង់ មិនចេះជួយដល់អ្នកក្រីក្រ ពីព្រោះតែមានចិត្តកំណាញ់ នឹងសេចក្តីលោភលន់ ជាអំពើបាបនៅចំពោះព្រះអម្ចាស់។

គម្ពីរយោង:

១. កិច្ចការ២:៤៤-៤៥
២. ទំនុកដំកើង៤១:១-៣
៣. សុភាសិត១៩:១៧
៤. ២កូរិនថូស៩:១-៩
៥. យ៉ាកុប២:១៤-១៧
៦. កិច្ចការ៤:៣៤-៤៥
៧. សុភាសិត២៨:២៧
៨. ម៉ាថាយ២៦:១១
៩. កាឡាទី២:១០

## ២០គ. ទទួលខុសត្រូវចំពោះពួកជំនុំ

នៅលើពិភពលោកបច្ចុប្បន្ននេះ ត្រូវការលុយ ដើម្បីធ្វើការផ្សាយដំណឹងល្អ ឲ្យចំណីដល់កូនចៀម និងផ្គត់ផ្គង់ដល់ពួកជំនុំនៃព្រះអម្ចាស់ តាមបញ្ជារបស់ព្រះយេស៊ូវគ្រីស្ទ។ ហេតុដូច្នេះហើយ គ្រីស្ទានដែលដឹកនាំដោយព្រះយេស៊ូវគ្រីស្ទ ឲ្យចែករំលែកហិរញ្ញវត្ថុរបស់ខ្លួន ជាមួយនឹងអស់អ្នកដែលបំរើក្នុងដំណឹងល្អនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ លោកសាវកប៉ុលបានសរសេរថា «តើមិនដឹងទេ ឬអី ថាពួកអ្នកដែលធ្វើការព្រះ បរិភោគដោយសារព្រះវិហារ ហើយពួកអ្នកដែលបំរើអាសនា ក៏បានចំណែកពីអាសនាដែរ?» តាមឯកសារដើមជា [ភាសាក្រិក houtoos ក្នុងលក្ខណៈដូចជាគ្នា ព្រះអម្ចាស់បានបញ្ញត្តិ [ភាសាក្រិក diatassoo បញ្ជា] «ព្រះអម្ចាស់ទ្រង់ក៏បង្គាប់ ឲ្យពួកអ្នកដែលផ្សាយដំណឹងល្អ បានរស់ដោយសារដំណឹងល្អដូច្នោះដែរ» (១កូរិនថូ៩:១៣-១៤) អស់អ្នកដែលទទួលការផ្គត់ផ្គង់ពីបងប្អូនសួនភ្ញា គឺមានការទទួលខុសត្រូវចំពោះព្រះអម្ចាស់ និងចំពោះបងប្អូនសួនភ្ញា ពីការប្រើប្រាស់ប្រាក់ដង្វាយ ១ភាគ ក្នុង១០ និងដង្វាយស្ម័គ្រពីចិត្ត។ អស់អ្នកបំរើព័ន្ធកិច្ច មិនអាចគំរាមកំហែង ឬបង្ខិតបង្ខំ ឬបំភិតបំភ័យ បងប្អូនសួនភ្ញា ឲ្យភ័យខ្លាច ដើម្បីថ្វាយដង្វាយ ១ភាគក្នុង ១០ នឹងដង្វាយស្ម័គ្រពីចិត្តពីពួកបងប្អូននោះទេ អស់អ្នកបំរើព័ន្ធកិច្ចរបស់ព្រះអម្ចាស់នឹងទទួលការផ្តន្ទាទោសដ៏ធ្ងន់ពីព្រះអម្ចាស់។

ព្រះអម្ចាស់ទ្រង់ព្រមានដល់ពួកអ្នកបំរើរបស់ទ្រង់ ប្រឆាំងនឹងការកេងប្រវ័ញ្ចផលប្រយោជន៍ពីពស្ត្រីក្រីក្ររបស់ព្រះអង្គ ហើយនឹងដកយកការផ្គត់ផ្គង់របស់អ្នកត្រូវការចេញ។ ទោះបីជាយ៉ាងណាក៏ដោយ ព្រះ

អម្ចាស់ទ្រង់ស្មោះត្រង់ នឹងប្រទានពរដល់អ្នកក្រីក្រ ដែលចេះថ្វាយដោយស្ម័គ្រអស់អំពីចិត្ត ដែលអាចធ្វើទៅបាន ទោះជាមានចំនួនតិចតួចយ៉ាងណាក៏ដោយ។ ព្រះអម្ចាស់យេស៊ូវទ្រង់មានបន្ទូលពី «...ស្ត្រីមេម៉ាយម្នាក់ដែលថ្វាយតែ២ស្លឹងគត់ ខ្ញុំប្រាប់អ្នកពល់គ្នាជាប្រាកដថា ស្រីមេម៉ាយទ័លក្រនេះបានដាក់ដង្វាយលើសជាងគេទាំងអស់ តែឯស្ត្រីនេះ នាងបានយកពីសេចក្តីកំសត់របស់ខ្លួនមកថ្វាយវិញ...»

គម្ពីរយោង:

១. ១កូរិនថូស៩:១-១៤
២. លូកា១៩:១២-១៧
៣. សាការី៧:៧-១៣
៤. លូកា១០:១៧
៥. លូកា២១:១-៤
៦. លូកា១៦:១០-១៣
៧. ១ធីម៉ូថេ៥:១៧-១៨
៨. ម៉ាថាយ១៤:៤៥-៥១

## ២០ឃ. គោលការនៃការថ្វាយដង្វាយ ១ភាគក្នុង១០ តាមបទគម្ពីរ

ព្រះអម្ចាស់ទ្រង់បានបង្កើតផ្ទៃមេឃ ផែនដី និងអស់ទាំងធន់ធានផ្សេងៗពីផែនដី គឺជាទ្រព្យសម្បត្តិ សំរាប់សេចក្តីត្រូវការខាងសាច់ឈាម។ ព្រះអម្ចាស់បានបង្កើតរបស់សព្វសារពើនៅលើផែនដី និងត្រីនៅក្នុងសមុទ្រ ព្រះទ្រង់ក៏ប្រទានរបស់ទាំងអស់នោះមកមនុស្ស ដើម្បីប្រើប្រាស់ដោយរីករាយពីរបស់ទាំងអស់នោះ។ តាមរយៈការប្រើប្រាស់អ្វីៗដែលព្រះអម្ចាស់បានបង្កើត មនុស្សអាចដាំដំណាំ ចិញ្ចឹមសត្វ កាប់ឈើ និងអាចរកត្រីពីសមុទ្របាន ពីព្រោះព្រះអម្ចាស់បានប្រទានឲ្យរបស់អស់ទាំងនោះដល់មនុស្ស ទ្រង់បានទាមទារឲ្យមនុស្សទទួលស្គាល់ទ្រង់ថា ជាអង្គបង្កបង្កើត និងជាអង្គទ្រទ្រង់ដ៏ពេញអំណាចលើរបស់ទាំងអស់នោះផង។ ព្រះគម្ពីរបានសំដែងថា ព្រះអម្ចាស់បានអនុវត្តន៍តាមគោលការនៃការថ្វាយដង្វាយ១ភាគ ក្នុង១០ បន្ថែមពីលើដង្វាយស្ម័គ្រពីចិត្ត ដែលត្រូវថ្វាយជាការលើកដំកើងទ្រង់។ ព្រះគម្ពីរសញ្ញាចាស់បានបញ្ជាក់ប្រាប់ថា ដង្វាយ១ភាគ ក្នុង១០ និងដង្វាយស្ម័គ្រពីចិត្តជារបស់ផងព្រះអម្ចាស់ និងជា «ចំណែកបរិសុទ្ធដល់ព្រះ»។

ព្រះយេស៊ូវបានបញ្ជាក់សេចក្តីពិតនេះ ពេលទ្រង់មានបន្ទូលថា «...ចូរថ្វាយរបស់សេសារ ទៅសេសារទៅ ឯរបស់ព្រះ ចូរថ្វាយទៅព្រះវិញ»។ អំពីដង្វាយរបស់អេបិល នៅគម្ពីរលោកុប្បត្តិបានបង្ហាញយ៉ាងច្បាស់ថា ការថ្វាយដង្វាយបានត្រូវអនុវត្តន៍តាំងពីដើមដំបូងនៃមនុស្សលោក ហើយក៏មិនមែនសំរាប់តែសាសន៍អ៊ីស្រាអែលជាសាសន៍ដែលមានសេចក្តីសញ្ញារបស់ព្រះអម្ចាស់នៅភ្នំស៊ីណាយតែប៉ុណ្ណោះទេ។ មុនពេលទ្រង់បង្កើត

សេចក្តីសន្យាចាស់ ពីដង្វាយ១ភាគ ក្នុង១០ និងដង្វាយស្ម័គ្រពីចិត្ត ព្រះអម្ចាស់បានប្រទានពរដល់លោកមិលគីស្សាដែក គឺជាសង្ឃនៃព្រះដ៏ខ្ពស់បំផុត។ គម្ពីរលោកុប្បត្តិបានកត់ត្រាថាលោកអ័ប្រាហាំបានថ្វាយដង្វាយ១ភាគ ក្នុង១០ ទៅស្តេចមិលគីស្សាដែក។ លោកអ៊ីសាក់ និងយ៉ាកុបក៏បានថ្វាយដង្វាយ ១ភាគ ក្នុង១០និងដង្វាយស្ម័គ្រពីចិត្តទៅស្តេចមិលគីស្សាដែក ដោយឥតសង្ស័យដែរ។ គម្ពីរសញ្ញាថ្មី ព្រះអម្ចាស់យេស៊ូវគ្រីស្ទទ្រង់ មានបន្ទូលទៅសាសន៍អ៊ីស្រាអែលថា ដង្វាយ១ភាគ ក្នុង១០ និងដង្វាយស្ម័គ្រពីចិត្ត ត្រូវបានប្រទានទៅពួកសង្ឃលេវីវិញ។

ព្រះអម្ចាស់ទ្រង់មានបន្ទូលថា ហើយមើលចុះ អញបានប្រទានដង្វាយ១ភាគ ក្នុង១០ដល់ពួកលេវីពីគ្រប់ដង្វាយក្នុងពួកសាសន៍អ៊ីស្រាអែល។ នៅក្នុងគម្ពីរសញ្ញាចាស់ ព្រះអម្ចាស់ទាមទារឲ្យរាស្ត្ររបស់ទ្រង់ឲ្យថ្វាយផលដំបូងពីការប្រមូលកាត់របស់ពួកគេ និងកូនដំបូងពីក្នុងហ្វូងសត្វរបស់គេ ដែលល្អ និងការរីកចំរើនដែលគេបានទទួល ទោះមកពីដំណាំ ពីហ្វូងសត្វ ពីការជីករ៉ែ មានតម្លៃពីផែនដី និងប្រាក់កម្រៃពីការលក់ដូរ។ ព្រះអម្ចាស់ទ្រង់មានបន្ទូលតាមរយៈហោរាម៉ាឡាគី ទៅដល់ពួកសង្ឃដែលប្រមាថលើបទបញ្ញារបស់ព្រះអង្គ ដោយថ្វាយដង្វាយជារបស់មិនស្អាត ព្រមទាំងលួចប្លន់ព្រះអម្ចាស់ ក៏ដូចអ្នករាល់គ្នា ដែលមិនថ្វាយដង្វាយ ១ភាគក្នុង ១០ និងដង្វាយស្ម័គ្រពីចិត្ត ទៅពួកលេវីដូចដែលព្រះអម្ចាស់បង្គាប់ គឺជាពួកអ្នកលួចប្លន់ព្រះ។

នៅក្រោមសេចក្តីសន្យាថ្មី សង្ឃមិលគីស្សាដែក ជាសង្ឃជំនួសពួកលេវី និងអំណាចពីព្រះ ដើម្បីទទួលដង្វាយ១ភាគ ក្នុង១០ និងដង្វាយស្ម័គ្រពីចិត្តនៃព្រះអម្ចាស់ ត្រូវបានផ្ទេរ តាមការបញ្ជារបស់សង្ឃមិលគីស្សាដែក។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទទ្រង់គង់នៅខាងស្តាំនៃព្រះដ៏ជាព្រះវរបិតា ជាសង្ឃដ៏ខ្ពស់បំផុត នៃស្តេចមិលគីស្សាដែក។ បច្ចុប្បន្ននេះ គ្រីស្ទានត្រូវថ្វាយដង្វាយ១ភាគ ក្នុង១០ និងដង្វាយស្ម័គ្រពីចិត្ត ដើម្បីផ្គត់ផ្គង់ដល់ព័ន្ធកិច្ចរបស់ព្រះយេស៊ូវគ្រីស្ទ តាមរយៈពួកជំនុំរបស់ទ្រង់ ឬក៏ពួកគេកំពុងតែលួចដង្វាយរបស់ព្រះអម្ចាស់។

នៅខាងក្រោមនេះ ជាគោលការថ្វាយដង្វាយតាមបទគម្ពីរ ពីដង្វាយ១ភាគ ក្នុង១០ របស់គ្រីស្ទានម្នាក់ៗ គឺមានការទទួលខុសត្រូវរៀងៗខ្លួន ពីការរីកចំរើនពិតរបស់ពួកគេ។ ព្រះយេស៊ូវគ្រីស្ទទ្រង់មានបន្ទូលថា «...ចូរថ្វាយរបស់សេសារ ទៅសេសារទៅ...» នេះបង្ហាញថាពន្ធដារ ទាំងនោះគួរតែបង់ទៅ សេសារ (រដ្ឋាភិបាលស៊ីវិល) អស់ទាំងពន្ធដារមិនត្រូវរាប់បញ្ចូលនៅក្នុងកំណត់ពីការរីកចំរើនរបស់អ្នកណាម្នាក់នោះទេ ហើយក៏មិនរាប់បញ្ចូលទាំងការចំណាយដែលទាក់ទងនឹងជំនួញ ឬការដែលបានកាត់បន្ថយប្រាក់ចំណូលជាក់ស្តែងរបស់អ្នកណាម្នាក់នោះឡើយ។ គ្រីស្ទានមានប្រាក់ចំណូល ដែលមានដែនកំណត់ប្រាក់ជាក់ស្តែងរបស់ពួកគេ ដែលត្រូវការចំណាយក្នុងការរស់នៅ គឺមិនមានការរីកចំរើននៅក្នុងព្រះនេត្រនៃព្រះអម្ចាស់ ដើម្បីថ្វាយដង្វាយ១ភាគ ក្នុង១០បានទេ។ ការថ្វាយដង្វាយមិនអាចទទួលបានសេចក្តីសង្គ្រោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើព្រះអម្ចាស់បានប្រទានពរផ្នែកហិរញ្ញវត្ថុដល់ពួកអ្នកជឿ ពួកគេត្រូវតែថ្វាយដង្វាយដោយស្ម័គ្រពីចិត្ត

ទៅតាមការដឹកនាំរបស់វិញ្ញាណបរិសុទ្ធនៃព្រះ។ គ្រីស្ទានម្នាក់ៗ ត្រូវតែថ្វាយដង្វាយចេញពីក្នុងចិត្ត និងមានអកប្បកិរិយាដោយសេចក្តីស្រឡាញ់ និងបំរើ យោងទៅតាមការប្រទានពរដែលព្រះអម្ចាស់បានប្រទាន ទាំងទាំងផ្នែកវិញ្ញាណបរិសុទ្ធ និងផ្នែកខាងសាច់ឈាមដែរ។ ព្រះអម្ចាស់បានសន្យាប្រទានពរដល់អស់អ្នកដែលថ្វាយ ១ភាគក្នុង១០ និងដង្វាយស្ម័គ្រពីចិត្ត ដោយស្មោះត្រង់ក្នុងគ្រប់ការទាំងអស់។

គម្ពីរយោង:

| | |
|---|---|
| ១. លោកុប្បត្តិ១:២៦-២៧ | ៧. ចោទិយកថា៨:១-១៨ |
| ២. ជនគណនា១៨:១-២ | ៨. ម៉ាឡាគី៣:៧-១១ |
| ៣. ១សាំយ៉ូអែល២:១២-១៧ | ៩. ម៉ាឡាគី១:៦-១៤ |
| ៤. ម៉ាថាយ២២:២១ | ១០. ម៉ាថាយ៥:១៧-២០ |
| ៥. លោកុប្បត្តិ៤:៣-៧ | ១១. ហេព្រើរ៧:១-១០ |
| ៦. ម៉ាឡាគី២:១-១០ | ១២. ម៉ាថាយ៦:១៩-២១ |

## ២១. ដំណឹងល្អ

ពាក្យ Gospel មានន័យថា «ដំណឹងល្អ» ដំណឹងល្អ គឺជាព្រះរាជសារដ៏អស្ចារ្យ ពីផែនការនៃសេចក្តីសង្គ្រោះរបស់ព្រះអម្ចាស់សំរាប់មនុស្សទាំងអស់ តាមរយៈព្រះជន្ម សេចក្តីសុគត និងការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រាតែមួយរបស់ព្រះវរបិតា។ ព្រះគម្ពីរសញ្ញាថ្មី ហៅព្រះរាជសារនេះ ថាជាដំណឹងល្អនៃព្រះគុណ។ ដំណឹងល្អនៃព្រះគុណ គឺជាដំណឹងល្អដែលព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃពិភពលោក ដោយសារព្រះលោហិតរបស់ទ្រង់ដល់អស់អ្នកដែលប្រែចិត្តពីអំពើបាប ហើយជឿព្រះយេស៊ូវគ្រីស្ទ នោះអំពើបាបរបស់គេទាំងប៉ុន្មាននឹងត្រូវបានអត់ទោសឲ្យ ហើយគេនឹងអាចចូលទៅក្នុងគ្រួសារនៃព្រះអម្ចាស់បានផង។ ដំណឹងល្អក៏ជាព្រះរាជសារអំពីនគរនៃព្រះអម្ចាស់ ដែលនឹងត្រូវមកដល់ ហើយនឹងតាំងឡើងនៅលើផែនដីនេះ។ ដំណឹងល្អ ក៏ជាដំណឹងនៃយាងត្រឡប់មកផែនដីនេះវិញ របស់ព្រះយេស៊ូវគ្រីស្ទ ទ្រង់នឹងរៀបចំនគរ នឹងរដ្ឋាភិបាលនៃទ្រង់នៅលើផែនដីនេះ។ ព្រះយេស៊ូវគ្រីស្ទទ្រង់នឹងសោយរាជ្យលើប្រជាជាតិទាំងអស់ ដ្បិតទ្រង់ជាស្តេច លើអស់ទាំងស្តេច ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់។ ពួកបរិសុទ្ធ ដែលទ្រង់បានប្រោសឲ្យរស់ពីស្លាប់ឡើងវិញ ក៏ប្រទានជីវិតអស់កល្បជានិច្ច នឹងសោយរាជ្យជាមួយនឹងព្រះយេស៊ូវគ្រីស្ទ ជាស្តេច នឹង

ជាសង្សនៅលើផែនដីនេះ។ ដំណឹងល្អនេះ ត្រូវតែបង្រៀនទៅដល់គ្រប់ទាំងសាសន៍ គ្រប់ទាំងភាសា ទុកជាទីបន្ទាល់ មុនពេលព្រះយេស៊ូវគ្រីស្ទយាងត្រឡប់មករៀបចំនគររបស់ទ្រង់ឡើងវិញ។ តាមរយៈការបង្រៀនពីដំណឹងល្អ ព្រះអម្ចាស់ទ្រង់នឹងរៀបចំពួកបរិសុទ្ធសំរាប់នគររបស់ទ្រង់ ដោយការត្រាស់ហៅអស់អ្នកដែលទ្រង់បានជ្រើសរើស ឲ្យបានប្រែចិត្ត ជឿដំណឹងល្អ។

គម្ពីរយោង:

| | |
|---|---|
| ១. កិច្ចការ២០:២៤ | ៧. យ៉ូហាន៣:១៦ |
| ២. ម៉ាកុស១:១៤-១៥ | ៨. ម៉ាថាយ២៤:១៤ |
| ៣. ម៉ាកុស១៦:១៥-១៦ | ៩. ម៉ាថាយ២៨:១៩-២០ |
| ៤. កិច្ចការ១១:១៩-២១ | ១០. រ៉ូម៨:១៦-១៧ |
| ៥. ១យ៉ូហាន២:១-២ | ១១. រ៉ូម១០:៨-១៨ |
| ៦. អេសាយ៩:៦-៧ | ១២. ១កូរិនថូស១៥ |

## ២២. នគរនៃព្រះអម្ចាស់

នគរព្រះ គឺជារដ្ឋាភិបាលនៃគ្រួសាររបស់ព្រះអម្ចាស់។ បច្ចុប្បន្ននេះ នគររបស់ព្រះអម្ចាស់កំពុងគ្រប់គ្រងពិភពលោក ទោះបីនគរនៃព្រះអម្ចាស់មិនទាន់បានគ្រប់គ្រងផែនដីនេះពេញលេញក៏ដោយ អស់អ្នកដែលមានវិញ្ញាណបរិសុទ្ធរបស់ព្រះអម្ចាស់ គឺនៅក្រោមការគ្រប់គ្រងរបស់ព្រះដ៏ជាព្រះវរបិតា នឹងនៅក្រោមការដឹកនាំរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ នគររបស់ព្រះអម្ចាស់ នឹងត្រូវតាំងឡើងនៅផែនដីនេះ នៅពេលដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទទ្រង់យាងមកផែនដីនេះវិញ។ នៅពេលនោះ រាជ្យ១ពាន់ឆ្នាំ នឹងចាប់ផ្ដើមហើយពួកបរិសុទ្ធ ដែលជាកូនរបស់ព្រះអម្ចាស់ នឹងសោយរាជ្យ ជាស្ដេច នឹងជាសង្ឃ ជាមួយនឹងព្រះយេស៊ូវគ្រីស្ទ នៅក្នុងនគរនៃទ្រង់។ បន្ទាប់ពីព្រះវរបិតានាំយកទីក្រុងយេរូសាឡឹមថ្មី ពីស្ថានសួគ៌មកផែនដីថ្មីនេះវិញ នោះព្រះអម្ចាស់ទ្រង់នឹងគ្រប់គ្រងពិភពលោកទាំងមូលចាប់តាំងពីទីក្រុងយេរូសាឡឹមថ្មីរហូតអស់កល្ប។

---

គម្ពីរយោង:

| | |
|---|---|
| ១. វិវរណៈ២:២៦ | ៨. វិវរណៈ៣:១២, ២១ |
| ២. មីកា៤:១-៤ | ៩. វិវរណៈ៣:១-២១ |
| ៣. ហេព្រើរ១១:១៣-១៦ | ១០. ១កូរិនថូស១៥:៥០-៥៤ |
| ៤. វិវរណៈ៥:១០ | ១១. អេសាយ១១:១-១០ |
| ៥. រ៉ូម៨:១៦-១៧ | ១២. កូល៉ុស១:១៣ |
| ៦. អេសាយ៦៦:២២-២៣ | ១៣. វិវរណៈ២១ |
| ៧. ដានីយ៉ែល២:៤ | ១៤. យ៉ូហាន៣:៣-៧ |

## ២៣. ការរស់ពីស្លាប់ឡើងវិញ

ព្រះគម្ពីរបានសំដែងថា មានពីរប្រភេទខុសពីគ្នា នៃការរស់ពីសេចក្តីស្លាប់ឡើងវិញ –

១) ការរស់ពីស្លាប់ឡើងវិញ នូវជីវិត ផ្នែករូបកាយជាមនុស្សខាងសាច់ឈាម

២) ការរស់ពីស្លាប់ឡើងវិញ ជាវិញ្ញាណ ដើម្បីឲ្យបានជីវិតអស់កល្បជានិច្ច

ព្រះគម្ពីរបានកត់ត្រាពីការរស់ពីស្លាប់ឡើងវិញជាសាច់ឈាមរបស់មនុស្សម្នាក់ៗ ទៅតាមពេលវេលាដែលព្រះអម្ចាស់បានកំណត់ទុក។ នៅគម្ពីរសញ្ញាចាស់ មានកូនប្រុសរបស់ស្ត្រីមេម៉ាយម្នាក់ បានស្លាប់ ដោយសារសេចក្តីអធិស្ឋានរបស់ហោរាអេលីយ៉ា កូនប្រុសនោះបានមានជីវិតរស់ពីស្លាប់ឡើងវិញ។ ព្រះយេស៊ូវគ្រីស្ទបានប្រោសឡាសារឲ្យរស់ពីស្លាប់ឡើងវិញ ជាគំរូនៅជំនាន់គម្ពីរសញ្ញាថ្មី។ ដោយសារសេចក្តីមេត្តាករុណាដ៏ពិសេសរបស់ព្រះអម្ចាស់ ទ្រង់នឹងប្រោសមនុស្សទាំងអស់ឲ្យរស់ពីស្លាប់ មានជីវិតខាងសាច់ឈាមឡើងវិញ។ អ្នកទាំងអស់នោះ ដែលព្រះអម្ចាស់បានប្រោសឲ្យរស់ពីស្លាប់ឡើងវិញ ជាសាច់ឈាម មិនបានប្រទាននូវភាពអមតៈ [ជីវិតអស់កល្ប] ទេ គេទាំងអស់គ្នានឹងត្រូវស្លាប់ម្តងទៀត។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទទ្រង់មានព្រះជន្មរស់ពីសុគតឡើងវិញ ដោយសារព្រះដ៏ជាព្រះវរបិតា ពីព្រោះព្រះវរបិតាទ្រង់ជាព្រះ [អមតៈភាព] ទ្រង់នឹងមិនសុគតទៀតឡើយ។ ដើម្បីឲ្យបានទៅជាកូនមនុស្ស [ព្រះយេស៊ូវគ្រីស្ទ] ទ្រង់បានលះបង់សិរីរុងរឿង អំណាច

នឹងកិត្តិយសជាព្រះ មកយកនិស្ស័យជាមនុស្ស។ ដ្បិតព្រះយេស៊ូវគ្រីស្ទទ្រង់ជាផលដំបូង ដែលបានរស់ពីស្លាប់ មុនគេ ទៅកាន់ភាពអមតៈ។ ពេលព្រះយេស៊ូវគ្រីស្ទយាងត្រឡប់មកផែនដីនេះវិញ នោះពួកអ្នកគ្រីស្ទានពិត ដែលបានស្លាប់នោះនឹងត្រូវប្រោសឲ្យមានជីវិតរស់អស់កល្ប ជាវិញ្ញាណ ហើយអស់អ្នកដែលនៅរស់ ពេលព្រះ យេស៊ូវគ្រីស្ទយាងមកវិញ អ្នកទាំងនោះនឹងបានផ្លាស់ប្រែទៅក្នុង១ប៉ប្រិចភ្នែក ពីសាច់ឈាម ទៅជាវិញ្ញាណ។ ការផ្លាស់ប្រែទៅជាវិញ្ញាណនេះ គឺជាកំណើតថ្មី ពួកបរិសុទ្ធរបស់ព្រះអម្ចាស់ ទាំងអ្នកស្លាប់ នឹងអស់អ្នកដែល កំពុងរស់នៅ«នឹងបានកើតជាថ្មី» ជាពិតប្រាកដ នឹងបានចូលទៅក្នុងសមាជិកនៃគ្រួសាររបស់ព្រះអម្ចាស់។ ពួក បរិសុទ្ធទាំងអស់នឹងត្រូវបង្កើតឡើងជាវិញ្ញាណ ដូចព្រះអង្គទ្រង់ជាវិញ្ញាណ ពួកគេនឹងបានពេញលក្ខណៈជា គ្រួសាររបស់ព្រះអម្ចាស់ ខាងឯវិញ្ញាណ ពួកអ្នកទាំងអស់នោះនឹងសោយរាជ្យជាមួយនឹងព្រះគ្រីស្ទនៅផែនដី នេះ។ សេចក្តីរស់ពីស្លាប់ឡើងវិញនេះ បទគម្ពីរហៅថា សេចក្តីរស់ពីស្លាប់ឡើងវិញ ជាលើកទី១។

បន្ទាប់ពីរាជ្យ ១ពាន់ឆ្នាំ នៃព្រះយេស៊ូវគ្រីស្ទ នឹងពួកបរិសុទ្ធ នឹងមានការប្រោសឲ្យរស់ពីស្លាប់ឡើងវិញ ជាលើកទី២ គឺរស់ឡើងវិញជាសាច់ឈាម នៃអស់អ្នកដែលស្លាប់ទៅ ដោយមិនបានទទួលសេចក្តីសង្គ្រោះ កុំឡុងកាលនៃការរស់ពីស្លាប់ឡើងវិញ ជាសាច់ឈាម លើកទី២នេះ មនុស្សទាំងប្រុស ទាំងស្រី មានឱកាសជា លើកដំបូង នឹងជាឱកាសតែមួយគត់ សំរាប់ទទួលសេចក្តីសង្គ្រោះ ដោយសារព្រះយេស៊ូវគ្រីស្ទ។ អស់អ្នក ដែលបានទទួលសេចក្តីសង្គ្រោះពេញលេញរបស់ព្រះអម្ចាស់ នោះនឹងបានចូលទៅក្នុងគ្រួសារនៃព្រះអម្ចាស់ ជាវិញ្ញាណ។ ចំណែកអស់អ្នកដែលបដិសេធសេចក្តីសង្គ្រោះនៃព្រះយេស៊ូវគ្រីស្ទ នឹងត្រូវទទួលទោសជា សេចក្តីស្លាប់អស់កល្បជានិច្ច។ គឺជាពួកអ្នកដែលបានចូលរួមជាមួយមនុស្សអាក្រក់ ដែលមិនប្រែចិត្ត ដែល បានស្លាប់កន្លងទៅហើយ ពួកគេនឹងត្រូវប្រោសឲ្យរស់ឡើងវិញ ជាសាច់ឈាម ជាអស់អ្នកដែលបដិសេធ សេចក្តីសង្គ្រោះ នឹងមានចិត្តធ្វើអំពើបាបដោយចេតនា ប្រមាថប្រឆាំងនឹងវិញ្ញាណបរិសុទ្ធរបស់ព្រះវរបិតា ដោយមិនព្រមប្រែចិត្តពីអំពើបាប គេនឹងត្រូវប្រោសឲ្យរស់ឡើងវិញ ដើម្បីទទួលទោសចុងក្រោយរបស់ព្រះ អម្ចាស់។ ទោសរបស់ពួកគេ គឺត្រូវស្លាប់នៅក្នុងបឹងភ្លើង សេចក្តីស្លាប់នេះ គឺជាសេចក្តីស្លាប់ទី២ នឹងជា សេចក្តីស្លាប់ចុងក្រោយ គឺគ្មានសេចក្តីរស់ពីស្លាប់ឡើងវិញទេ។

គម្ពីរយោង:

| | |
|---|---|
| ១. ១ពង្សាវតាក្សត្រ១៧:១៧-២៤ | ៩. យ៉ូហាន១១:២០-៤៤ |
| ២. ម៉ាកុស៥:៣៥-៤២ | ១០. ១កូរិនថូស១៥:៣-៤, ២០-២៣ |

៣. រ៉ូម១:៤

៤. យ៉ូហាន៥:២៨-២៩

៥. វិវរណៈ២០:៤-៥

៦. វិវរណៈ២០:១១-១២

៧. វិវរណៈ២០:១១-១៥

៨. ម៉ាថាយ២៥:៤១-៤៦

១១. ហេព្រើរ២:៩-១០

១២. ១កូរិនថូស១៥:២៣, ៣៥-៥៥

១៣. ម៉ាថាយ២៧:៥២-៥៣

១៤. អេសេគាល៣៧:១-១៤

១៥. ២ពេត្រុស៣:១០-១២

## ២៤. ការជំនុំជំរះអស់កល្ប

បច្ចុប្បន្ននេះ ព្រះអម្ចាស់កំពុងជំនុំជំរះដល់អស់អ្នកដែលទ្រង់បានត្រាស់ហៅ។ ការជំនុំជំរះរបស់ព្រះអម្ចាស់សំរាប់មនុស្សប្រុស ស្រី ពេលដែលព្រះអង្គបើកចិត្ត បើកគំនិតរបស់គេ ឲ្យយល់ពីផ្លូវនៃជីវិតរបស់ព្រះអង្គ ជាមួយនឹងសេចក្តីស្រឡាញ់ ព្រះគុណ នឹងសេចក្តីមេត្តាករុណា ហើយព្រះអង្គក៏ប្រទានដល់អស់អ្នកដែលតាមព្រះ នូវវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ ដើម្បីជាកំឡាំង នឹងអំណាច ក្នុងការចំរើនសេចក្តីស្រឡាញ់ ជំនឿ នឹងព្រះគុណ ដែលអាចយកជ័យជំនះលើលក្ខណៈធម្មជាតិរបស់មនុស្ស លោកីយ នឹងអារក្សសាតាំងជាបីសាចបាន។ ព្រះដ៏ជាព្រះវរបិតាជំរូវឲ្យអ្នកជឿម្នាក់ៗទទួលខុសត្រូវផ្ទាល់ខ្លួន ក្នុងការរីកចំរើន ចំណេះដឹងព្រះបន្ទូលនៅក្នុងសេចក្តីពោរពេញនៃព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ។ ប្រសិនបើ អ្នកជឿស្រឡាញ់ព្រះអម្ចាស់អស់ពីចិត្ត នឹងរស់នៅដោយស្តាប់បង្គាប់ដ៏ស្មោះត្រង់ចំពោះព្រះបន្ទូល បុរស ឬ ស្ត្រី នឹងទទួលបានសេចក្តីសុចរិតនៃព្រះយេស៊ូវគ្រីស្ទ ជាអំណោយទានដែលមកពីព្រះ។ អ្នកជឿបានរាប់ជាសុចរិត នឹងឥតកន្ទែងបន្ទោសបាន នៅចំព្រះដ៏ជាព្រះវរបិតា។ អស់អ្នកដែលនៅក្នុងសេចក្តីសុចរិត នៃសេចក្តីជំនឿ នឹងត្រូវបានប្រោសឲ្យរស់ពីស្លាប់ឡើងវិញ លើកទី១ នឹងទទួលបានជីវិតអស់កល្ប នៅពេលព្រះយេស៊ូវគ្រីស្ទយាងត្រឡប់មកកាន់ផែនដីនេះវិញ។

អស់អ្នកដែលស្លាប់ទៅ ដោយមិនបានទទួលសេចក្តីសង្គ្រោះ នឹងត្រូវប្រោសឲ្យរស់ឡើងវិញ ជាសាច់ឈាម ជាសេចក្តីរស់ពីស្លាប់ឡើងវិញលើកទី២ បន្ទាប់ពីរាជ្យ១ពាន់ឆ្នាំ នៃព្រះយេស៊ូវគ្រីស្ទ នឹងពួកបរិសុទ្ធ។ អ្នកអ្នកដែលបានប្រោសឲ្យរស់ឡើងវិញ លើកទី២ អ្នកទាំងនោះ នឹងមានឱកាសទទួលបានសេចក្តីសង្គ្រោះ ដូចអស់អ្នកដែលបានប្រោសឲ្យរស់ឡើងវិញ លើកទី១ដែរ។ គេម្នាក់ៗ នឹងត្រូវបានបង្រៀនពីផ្លូវនៃសេចក្តីសង្គ្រោះ

ហើយនឹងមានឱកាសប្រែចិត្ត នឹងទទួលយញ្ញបូជានៃព្រះយេស៊ូវគ្រីស្ទជាជង្វាយសំរាប់ការអត់ទោសបាបរបស់គេ។ មនុស្សម្នាក់ៗនឹងមានឱកាសជ្រើសរើសផ្លូវនៃសេចក្ដីសង្គ្រោះដូចគ្នា។ នៅពេលជំនុំជំរះបល្ល័ង្កស១យ៉ាងធំ (The Great White Throne Judgment) រយៈពេល១០០ឆ្នាំ នៅពេលនោះអស់អ្នកដែលរៀនរស់នៅដឹងតាមគោលបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ អ្នកទាំងនោះនឹងបានរីកចំរើនក្នុងព្រះគុណ នឹងចំណេះដឹង ហើយមានលក្ខណៈនៃព្រះអម្ចាស់ នឹងទទួលបានជីវិតអស់កល្បជានិច្ច។

ពេលចុងបញ្ចប់នៃការជំនុំជំរះដ៏ធំនោះ អស់អ្នកដែលបានជ្រើសរើសផ្លូវនៃសេចក្ដីសង្គ្រោះ នឹងបានចូលទៅក្នុងនគរនៃព្រះអម្ចាស់ ជាកូនរបស់ព្រះអម្ចាស់អស់កល្ប។ ចំណែកអស់អ្នកដែលបដិសេធសេចក្ដីសង្គ្រោះ នឹងត្រូវជំនុំជំរះទៅក្នុងសេចក្ដីស្លាប់ទី២ ជាសេចក្ដីជំនុំជំរះដ៏អស់កល្បរបស់ពួកគេ។ មនុស្សអាក្រក់ដែលមិនព្រមប្រែចិត្តពីអំពើបាប តាំងពីសម័យកាលមុន,ដោយតាំងចិត្តទាស់ទទឹង នឹងបន្តធ្វើអំពើបាបដែលកែមិនបាន ទាំងបដិសេធសេចក្ដីសង្គ្រោះរបស់ព្រះអម្ចាស់ នោះពួកគេនឹងត្រូវប្រោសឲ្យរស់ឡើងវិញជាជីវិតខាងសាច់ឈាម នឹងរួមជាមនុស្សមានបាប នោះគេនឹងត្រូវទទួលសេចក្ដីជំនុំជំរះ ឲ្យត្រូវស្លាប់ ជាសេចក្ដីស្លាប់ទី២ គឺជាសេចក្ដីស្លាប់អស់កល្ប។ ព្រះអម្ចាស់ទ្រង់នឹងបោះពួកមនុស្សមានបាបដែលមិនព្រមប្រែចិត្តទៅក្នុងបឹងភ្លើង គឺជាសេចក្ដីស្លាប់ទី២ គ្មានការរស់ឡើងវិញទេ។

គម្ពីរយោង:

១. ១ពេត្រុស៤:១៧
២. ហេព្រើរ១០:២៦-២៧
៣. កិច្ចការ១០:៤២
៤. រ៉ូម១៤:១០-១២
៥. វិវរណៈ២០:៥-៦
៦. ២ធីម៉ូថេ៤:៨
៧. មីកា៤:១-៤
៨. រ៉ូម២:១៦
៩. វិវរណៈ២០:១១-១៤
១០. ២ពេត្រុស២:៩
១១. ១សាំយ៉ូអែល១៦:៧
១២. អេសេគាល៣៧:១២-១៤

## ២៥. ការជ្រមុជដោយភ្លើង

ការជ្រមុជដោយភ្លើងមិនមែនជាពិធីជ្រមុជទឹក ដែលពួកអ្នកជឿស្វែងរក ជាការជ្រមុជដោយវិញ្ញាណ

បរិសុទ្ធ ដូចដែលគេធ្លាប់បានបង្រៀននោះទេ។ ប៉ុន្តែវាជាពិធីជ្រមុជសំរាប់ពួកមនុស្សអាក្រក់ដែលមិនប្រែចិត្តពីអំពើបាប។ ព្រះគម្ពីរបានសំដែងថា ការជ្រមុជដោយភ្លើង គឺជាការហិនវិនាសដ៏អស់កល្បជានិច្ចរបស់ពួកមនុស្សអាក្រក់ ដែលត្រូវជ្រមុជចូលទៅក្នុងភ្លើង នឹងស្ពាន់ធ័រ ដល់អស់អ្នកដែលត្រូវបោះទៅក្នុងបឹងភ្លើង នឹងមិនគង់នៅយូរប៉ុន្មានទេ នឹងត្រូវឆេះអស់ទៅ គឺជាសេចក្ដីស្លាប់ទី២។ សេចក្ដីជំនុំជំរះចុងក្រោយសំរាប់ពួកអ្នកមិនប្រែចិត្តពីអំពើបាប មានចិត្តរឹងទទឹង ប្រព្រឹត្តអំពើទុច្ចរិតនៅក្នុងចិត្ត ប្រឆាំងនឹងព្រះអម្ចាស់ ចេះតែបន្តប្រព្រឹត្តអំពើបាបដោយស្ម័គ្រពីចិត្ត ប្រឆាំងនឹងវិញ្ញាណបរិសុទ្ធរបស់ព្រះ ហើយបង្ខាំងសេចក្ដីពិត ដោយសេចក្ដីទុច្ចរិតមិនឲ្យអ្នកណាទទួលការប្រែចិត្តពីអំពើបាបបាន គឺជាមនុស្សអាក្រក់ដែលត្រូវបោះទៅក្នុងបឹងភ្លើង។

គម្ពីរយោង:

១. ម៉ាថាយ៣:១១-១២
២. ម៉ាឡាគី៤:១-៣
៣. វិវរណៈ២១:៨
៤. វិវរណៈ២០:១៤-១៥
៥. ម៉ាថាយ១២:៣១-៣២

## ២៦. សត្វស្អាត (សាច់) នឹងសត្វមិនស្អាត

ព្រះដែលបង្កបង្កើតរបស់សព្វសារពើ ទ្រង់មិនបានប្រទានត្រឹមតែរុក្ខជាតិប៉ុណ្ណោះទេ ទ្រង់ក៏ប្រទានសត្វ ដើម្បីជាអាហារសំរាប់មនុស្សផងដែរ។ ព្រះអម្ចាស់ទ្រង់មិនបានបង្កើតសត្វទាំងអស់ឲ្យមនុស្សអាចបរិភោគបានទាំងអស់នោះទេ ពីព្រោះព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យចង់ឲ្យមនុស្សមានសុខភាពល្អ ដោយហេតុនោះ បានជាព្រះអម្ចាស់ទ្រង់បានបើកសំដែងដល់មនុស្សពីសត្វណាដែលទ្រង់បានបង្កើតឡើង ជាពិសេសសំរាប់ជាអាហារ។ ចំណេះដឹងនេះ ត្រូវបានឲ្យស្គាល់ ចាប់តាំងពីការបង្កបង្កើតដំបូងមកម្ល៉េះ ដូចដែលបានបង្ហាញក្នុងរឿងលោកណូអេ នឹងទឹកជំនន់។ នៅក្នុងគម្ពីរលេវីវិន័យជំពូក១១ នឹង ចោទិយកថា ជំពូក១៤ ព្រះអម្ចាស់បានបញ្ជាក់យ៉ាងច្បាស់ថា សាច់សត្វណាមួយដែលមនុស្សត្រូវបរិភោគបាន នឹងសាច់សត្វមួយណាដែលមិនត្រូវបរិភោគ។ កំណត់សំគាល់របស់សត្វដែលស្អាត នឹងសត្វដែលមិនស្អាត គឺងាយនឹងសំគាល់ដោយចារិកលក្ខណៈដែលព្រះបានបង្កើតវាឡើងនៅក្នុងសត្វនោះឯង សត្វណាដែលមានក្រចកផែកជា២ ហើយដែលទំពាអៀង នោះត្រូវបរិភោគបាន។ សត្វណាផ្សេងៗទៀត ដែលមានក្រចកផែក តែឥតទំពាអៀងនោះជាសត្វមិនស្អាតដល់ឯង កុំបរិភោគ។ ចំពោះត្រីដែលរស់នៅក្នុងទឹក ត្រីណាដែលមានព្រុយនឹងស្រ

កា គឺជាត្រីស្អាតដែលអាចបរិភោគបាន ចំណែកត្រីផ្សេងៗទៀត គឺមិនស្អាតដល់ឯង កុំបរិភោគ។ ចំពោះសត្វស្លាប ព្រះអម្ចាស់បានហាមមិនឲ្យបរិភោគ សត្វណាដែលស្វែងរកអាហារដោយខ្លួនឯង សត្វទាំងអស់នោះ គឺជាសត្វមិនស្អាត ដូចនឹងសត្វល្អិតៗ ឯទៀតទាំងអស់ផងដែរ។ ក្នុងពួកសត្វមានស្លាបដែលវារតោង ឬដើរដោយជើងនោះឯងរាល់គ្នាត្រូវបរិភោគបានតែសត្វណា ដែលមានជើងសំរាប់ផ្លាត់នៅដី ដូចជាកណ្តូបតាមពូជវា កន្រ្ទុលតាមពូជវា ចង្រិតដែកតាមពូជ នឹងចង្រិតដូងតាមពូជវា។ អ្នកកាន់សាសនាគ្រីស្ទជាច្រើននាក់ បានប្រឆាំងនឹងគម្ពីរសញ្ញាថ្មី នឹងច្បាប់របស់ព្រះអម្ចាស់ អំពីសត្វស្អាត នឹងសត្វមិនស្អាត។ ការតតាំងរវាងព្រះយេស៊ូវគ្រីស្ទ នឹងពួកអាចារ្យ នឹងផារីស៊ី នៅគម្ពីរម៉ាកុសជំពូក៧ មិនមែនពីការបរិភោគសត្វស្អាត ឬសត្វមិនស្អាតនោះទេ។ ផ្ទុយទៅវិញ មានជាប់ទាក់ទងនឹងពួកសាវករបស់ទ្រង់ដែលបរិភោគដោយមិនលាងដៃ។ ព្រះអម្ចាស់យេស៊ូវបានបើកសំដែងឲ្យសាវកពេត្រុសបានឃើញ ហើយបានកត់ត្រាទុកនៅក្នុងគម្ពីរកិច្ចការជំពូក១០ គឺថាគ្មានមនុស្សណាម្នាក់ហៅថាមិនស្អាតនោះទេ។ គ្មានអ្នកណាមានអំណាចអាចនឹងផ្លាស់ប្តូរច្បាប់របស់ព្រះអម្ចាស់អំពីសត្វស្អាត នឹងសត្វមិនស្អាតបានឡើយ។ សាវកប៉ុលបានយល់ព្រមអំពីច្បាប់នៃសត្វស្អាត នឹងសត្វមិនស្អាត ហើយបានទាមទារឲ្យអ្នកគ្រីស្ទានប្រព្រឹត្តតាមផង។ សាវកប៉ុលបានសរសេរប្រាប់ពីសាច់សត្វ ដែលគ្រីស្ទានអាចបរិភោគបាន ជាសត្វដែលព្រះអម្ចាស់បានបង្កើតមកសំរាប់ជាអាហារ ដោយទទួលដោយអរព្រះគុណព្រះ ដោយស្មោះត្រង់ (១ធីម៉ូថេ៤:៣) ទាំងអស់អ្នកដែលស្គាល់សេចក្តីពិត «...ឯសេចក្តីពិត គឺជាព្រះបន្ទូលរបស់ទ្រង់» (យ៉ូហាន១៧:១៧) សាវកប៉ុលបានបន្តថា ដ្បិតសត្វទាំងអស់ដែលព្រះទ្រង់បង្កើតមកនោះសុទ្ធតែល្អ ហើយមិនត្រូវចោល១ឡើយ ឲ្យគ្រាន់តែទទួលដោយអរព្រះគុណប៉ុណ្ណោះ (៦៤)។

គម្ពីរយោង:

១. លេវីវិន័យ១១:១-៣១
២. ម៉ាកុស៧:១-១៦
៣. ១ធីម៉ូថេ៤:៣-៥
៤. លោកុប្បត្តិ៧:២
៥. ចោទិយកថា១៤:៣-២១
៦. កិច្ចការ១០:១-២៨
៧. អេសាយ៦៦:១៧
៨. លោកុប្បត្តិ៨:២០

# ថ្ងៃបុណ្យបរិសុទ្ធរបស់ព្រះ ពីឆ្នាំ២០២៣ ដល់ ឆ្នាំ២០៣៩

| ឆ្នាំ | បុណ្យរំលង | នំបុ័ងឥតដំបែ | ថ្ងៃទី៥០ | ផ្លុំត្រែ | ធួននឹងបាប(តម) | បុណ្យបារាំ. | ថ្ងៃធំដ៏អស្ចារ្យ |
|---|---|---|---|---|---|---|---|
| ២០២៣ | ៥ មេសា (ពុធ) | ៦-១២មេសា (ព្រហស្បត្តិ-ពុធ) | ២៨ ឧសភា (អាទិត្យ) | ១៦ កញ្ញា (សៅរ៍) | ២៥ កញ្ញា (ច័ន្ទ) | ៣០ កញ្ញា- ៦ តុលា (សៅរ៍-សុក្រ) | ៧ តុលា (សៅរ៍) |
| ២០២៤ | ២២ មេសា (ច័ន្ទ) | ២៣-២៩ មេសា (អង្គារ-ច័ន្ទ) | ១៦ មិថុនា (អាទិត្យ) | ៣ តុលា (ព្រហស្បត្តិ) | ១២ តុលា (សៅរ៍) | ១៧-២៣ តុលា (ព្រហស្បត្តិ-ពុធ) | ២៤ តុលា (ព្រហស្បត្តិ) |
| ២០២៥ | ១២ មេសា (សៅរ៍) | ១៣-១៩ មេសា (អាទិត្យ-សៅរ៍) | ១ មិថុនា (អាទិត្យ) | ២៣ កញ្ញា (អង្គារ) | ២ តុលា (ព្រហស្បត្តិ) | ៧-១៣ តុលា (អង្គារ-ច័ន្ទ) | ១៤ តុលា (អង្គារ) |
| ២០២៦ | ១ មេសា (ពុធ) | ២.៨មេសា (ព្រហស្បត្តិ-ពុធ) | ២៤ ឧសភា (អាទិត្យ) | ១២ កញ្ញា (សៅរ៍) | ២១ កញ្ញា (ច័ន្ទ) | ២៦ កញ្ញា-២តុលា (សៅរ៍- សុក្រ) | ៣ តុលា (សៅរ៍) |
| ២០២៧ | ២១ មេសា (ពធ) | ២២-២៨ មេសា (ព្រហសប្បត្តិ-ពុធ | ១៣ ឧសភា (អាទិត្យ) | ២ តុលា (សៅរ៍) | ១១ តុលា (ច័ន្ទ) | ១៦-២២ តុលា (សៅរ៍-សុក្រ) | ២៣ តុលា (សៅរ៍) |
| ២០២៨ | ១០ មិនា (ច័ន្ទ) | ១១-១៧ មេសា (អង្គារ- ច័ន្ទ) | ៤ មិនា (អាទិត្យ) | ២១ កញ្ញា (ព្រហស្បត្តិ) | ៣០ កញ្ញា (សៅរ៍) | ៥-១១ តុលា (ព្រហស្បត្តិ-ពុធ) | ១២ តុលា (ព្រហស្បត្តិ) |
| ២០២៩ | ៣០ មិនា (សុក្រ) | ៣១ មិនា-៦ មេសា (សៅរ៍-សុក្រ) | ២០ ឧសភា (អាទិត្យ) | ១០ កញ្ញា (ច័ន្ទ) | ១៩ កញ្ញា (ពុធ) | ២៤-៣០ កញ្ញា (ច័ន្ទ -អាទិត្យ) | ១ តុលា (ច័ន្ទ) |
| ២០៣០ | ១៧ មេសា (ពុធ) | ១៨- ២៤ មេសា (ព្រហស្បត្តិ-ពុធ) | ៩ មិថុនា (អាទិត្យ) | ២៨ កញ្ញា (សៅរ៍) | ៧ តុលា (ច័ន្ទ) | ១២-១៨ តុលា (សៅរ៍-សុក្រ) | ១៩ តុលា (សៅរ៍) |
| ២០៣១ | ៧ មេសា (ច័ន្ទ) | ៨-១៤ មេសា (អង្គារ -ច័ន្ទ) | ១ មិថុនា (អាទិត្យ) | ១៨ កញ្ញា (ព្រហស្បត្តិ) | ២៧ កញ្ញា (សៅរ៍) | ២- ៨ តុលា (ព្រហស្បត្តិ-ពុធ) | ៩ តុលា (ព្រហស្បត្តិ) |
| ២០៣២ | ២៦ មិនា (សុក្រ) | ២៧ មិនា ២មេសា (សៅរ៍- សុក្រ) | ១៦ ឧសភា (អាទិត្យ) | ៦ កញ្ញា (ច័ន្ទ) | ១៥ កញ្ញា (ពុធ) | ២០- ២៦ កញ្ញា (ច័ន្ទ- អាទិត្យ) | ២៧ កញ្ញា (ច័ន្ទ) |
| ២០៣៣ | ១៣ មេសា (ពុធ) | ១៤- ២០ មេសា (ព្រហស្បត្តិ-ពុធ) | ៦ ឧសភា (អាទិត្យ) | ២៤ កញ្ញា (សៅរ៍) | ៣ តុលា (ច័ន្ទ) | ៨-១៤ តុលា (សៅរ៍-សុក្រ) | ១៥ តុលា (សៅរ៍) |
| ២០៣៤ | ៣ មេសា (ច័ន្ទ) | ៤-១០ មេសា (អង្គារ-ច័ន្ទ) | ២៨ ឧសភា (អាទិត្យ) | ១៤ កញ្ញា (ព្រហស្បត្តិ) | ២៣ កញ្ញា (សៅរ៍) | ២៨ កញ្ញា-៤តុលា (ព្រះស្បត្តិ- ពុធ) | ៥ តុលា (ព្រហស្បត្តិ) |
| ២០៣៥ | ២៣ មេសា (ច័ន្ទ) | ២៤-៣០ មេសា (អង្គារ- ច័ន្ទ) | ១៧មិថុនា (អាទិត្យ) | ២២ កញ្ញា (ព្រហស្បត្តិ) | ១៣ តុលា (សៅរ៍) | ១៨-២៤ តុលា (ព្រហស្បត្តិ-ពុធ) | ២៥ តុលា (ព្រហស្បត្តិ) |
| ២០៣៦ | ១១ មេសា (សុក្រ) | ១២-១៨ មេសា (សៅរ៍-សុក្រ) | ១ មិថុនា (អាទិត្យ) | ២២ កញ្ញា (ច័ន្ទ) | ១ តុលា (ពុធ) | ៦-១២តុលា (ច័ន្ទ-អាទិត្យ) | ១៣ តុលា (ច័ន្ទ) |
| ២០៣៧ | ៣០ មិនា (ច័ន្ទ) | ៣១មិនា-៦មេសា (អង្គារ-ច័ន្ទ) | ២៤ ឧសភា (អាទិត្យ) | ១០ កញ្ញា (ព្រហស្បត្តិ) | ១៩ កញ្ញា (សៅរ៍) | ២៤-៣០ កញ្ញា (ព្រហស្បត្តិ-ពុធ) | ១ តុលា (ព្រហស្បត្តិ) |
| ២០៣៨ | ១៩ មេសា (ច័ន្ទ) | ២០-២៦ មេសា (អង្គារ- ច័ន្ទ) | ១៣ ឧសភា (អាទិត្យ) | ៣០ កញ្ញា (ព្រហស្បត្តិ) | ៩ តុលា (សៅរ៍) | ១៤-២០ តុលា (ព្រហស្បត្តិ-ពុធ) | ២១ តុលា (ព្រហស្បត្តិ) |
| ២០៣៩ | ៨ មេសា (សុក្រ) | ៩-១៥ មេសា (សៅរ៍ -សុក្រ) | ២៩ មេសា (អាទិត្យ) | ១៩ កញ្ញា (ច័ន្ទ) | ២៨ កញ្ញា (ព្រហស្បត្តិ) | ៣ -៩ តុលា (ច័ន្ទ- អាទិត្យ) | ១០ តុលា (ច័ន្ទ) |

**Sabbath Reflections** ថ្ងៃបុណ្យនិមួយៗ ចាប់ផ្តើម ពីថ្ងៃលិច មុនថ្ងៃបុណ្យ

# សេចក្ដីពន្យល់ ពីបុណ្យបរិសុទ្ធរបស់ព្រះ

| | | |
|---|---|---|
| បុណ្យរំលង<br>សញ្ញាចាស់: ព្រះតាំងសញ្ញានឹងអ័ប្រាហាំថា ទ្រង់នឹងទុកកូនច្បង ហើយជំនុំជំរះព្រះស្រុកអេស៊ីព្ទ (លោកុ. ១៥:១៨, និក្ខមនំ១១:៤-៧)<br>សញ្ញាថ្មី: ព្រះសំដែងសេចក្ដីស្រឡាញ់ ដោយប្រទានព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រាតែមួយ ឲ្យមកសុគតសំរាប់លោះបាបមនុស្ស យើងបានសង្គ្រោះរួចពីបាប ដោយសារព្រះលោហិត ទ្រង់សុគតជំនួសបាបរបស់យើង ដើម្បីនឹងតាំងសញ្ញាថ្មីតាមរយៈរូបអង្គទ្រង់ នឹងលោហិតព្រះគ្រីស្ទ សំរាប់ជីវិតអស់កល្ប (២កូរិនថូស៥:២១, យ៉ូហាន១០:២៨) | បុណ្យផ្លុំត្រែ<br>សញ្ញាចាស់: ត្រែផ្លុំរំលឹកអំពីព្រះអម្ចាស់ ទ្រង់មានវត្តមាននៅឯព្រះវិហារ ត្រែផ្លុំដើម្បីទទួលជ័យជំនះ លើខ្មាំងសត្រូវ (១របាក្សត្រ ១៥:១៦-២៤, យ៉ូស្វេ៦:១-១៧)<br>សញ្ញាថ្មី: ព្រះទ្រង់មានជ័យជំនះលើអារក្សសាតាំង ត្រែត្រូវផ្លុំដាស់ពួកបរិសុទ្ធ ពីស្លាប់ឡើងវិញ ព្រះគ្រីស្ទ នឹងពួកបរិសុទ្ធ ចុះពីសមុទ្រកែវ មកផែនដីវិញ (១ថែស្សាឡូនីច៤:១៤-១៧, វិវរណៈ១៥:២-៤) | បុណ្យបារាំ (ត)<br>ជាសាច់ឈាម គង់ជាមនុស្ស ដោយវិញ្ញាណបរិសុទ្ធរបស់ព្រះវរបិតា នឹងព្រះយេស៊ូវគ្រីស្ទ ស្ថិតនៅក្នុងពួកបរិសុទ្ធ ពួកបរិសុទ្ធផ្លាស់រូបកាយជាវិញ្ញាណ ពួកបរិសុទ្ធសោយរាជ្យលើផែនដី ជាមួយនឹងព្រះគ្រីស្ទ១ពាន់ឆ្នាំ (ម៉ាថាយ១:១៨-២៥, យ៉ូហាន១៤:២៣, ១កូរិនថូស១៥:៤២-៥៨, វិវរណៈ៥:១០, ២០:៤) |
| បុណ្យនំបុ័ងឥតដំបែ<br>សញ្ញាចាស់: ព្រះតាំងសញ្ញានឹងអ័ប្រាហាំថា ទ្រង់នឹងការពារកូនច្បងរបស់សាសន៍អ៊ីស្រាអែល ហើយជំនុំជំរះព្រះស្រុកអេស៊ីព្ទ (និក្ខមនំ១១:៤-៧)<br>សញ្ញាថ្មី: គ្រីស្ទានឥតដំបែក្នុងព្រះគ្រីស្ទ មានជ័យជំនះលើអំពើបាបដោយអំណាចនៃវិញ្ញាណបរិសុទ្ធរបស់ព្រះ ហើយដើរក្នុងជីវិតបែបថ្មី ដោយកាន់តាមបញ្ញត្តិទាំងប៉ុន្មានរបស់ព្រះ ហើយយើងជាពូជអ័ប្រាហាំ ដោយវិញ្ញាណ (១កូរិនថូស៥:៧, កាឡាទី៣:២៩) | ថ្ងៃឲ្យធួននឹងបាប<br>សញ្ញាចាស់: ពួកសង្ឃថ្វាយដង្វាយដល់ព្រះយេហូវ៉ា ឲ្យធួននឹងបាបរបស់ពួកកូនចៅសាសន៍អ៊ីស្រាអែល (លេវីវិន័យ២៣:២៦-៣២)<br>សញ្ញាថ្មី: អារក្សសាតាំងត្រូវចាប់ចងបោះទៅក្នុងជង្ហុកធំ១០០០ឆ្នាំ ព្រះយេស៊ូវថ្វាយអង្គទ្រង់ជាដង្វាយលោះបាបមនុស្សលោក ពួកបរិសុទ្ធជាវិញ្ញាណ នៅជាមួយព្រះវរបិតា នឹងព្រះយេស៊ូវគ្រីស្ទ (វិវរណៈ២០:១-៣, ១៥:២-៤ | ថ្ងៃជំនុំអស្ចារ្យចុងក្រោយ<br>សញ្ញាចាស់: ព្រះអម្ចាស់ទ្រង់ប្រទានពរដល់ពួកកូនចៅអ៊ីស្រាអែល (១ពង្សាវតាក្សត្រ ១០:២៣)<br>សញ្ញាថ្មី: ១) សេចក្ដីរស់ពីស្លាប់ឡើងវិញ មាន២ដំណាក់កាល ដំណាក់កាលទី១ មានឱកាសទទួលសេចក្ដីសង្គ្រោះ ដំណាក់កាលទី២ ទទួលសេចក្ដីជំនុំជំរះចុងក្រោយ ពួកទុច្ចរិតបោះទៅក្នុងបឹងភ្លើង<br>២) ស្ថានសួគ៌ថ្មី នឹងផែនដីថ្មី<br>៣) ក្រុងយេរូសាឡិមថ្មី ចុះពីស្ថានសួគ៌<br>៤) ព្រះទ្រង់ចាប់ផ្ដើមផែនការជីវិតអស់កល្ប |
| ថ្ងៃទី៥០<br>សញ្ញាចាស់: សាសន៍អ៊ីស្រាអែលទទួលបញ្ញត្តិនៅភ្នំស៊ីណាយ ផលដំបូងពីស្រូវសាលី នឹងស្រូវឱក (លេវី.២៣:៩-១១, ចោទិ.៨:៧-៨)<br>សញ្ញាថ្មី: ពួកជំនុំទទួលវិញ្ញាណបរិសុទ្ធរបស់ព្រះ ជាផលដំបូង (រ៉ូម១៦:៥) | បុណ្យបារាំ<br>សញ្ញាចាស់: ជាសេចក្ដីរំលឹកពីពួកកូនចៅសាសន៍អ៊ីស្រាអែល នៅទីរហោស្ថាន (និក្ខមនំ លេវីវិន័យ, ជនគណនា, ចោទិយកថា)<br>សញ្ញាថ្មី: ព្រះយេស៊ូវគ្រីស្ទ យកនិស្ស័យជា | កំណត់ចំណាំ |

*ព្រះយេស៊ូវមានបន្ទូលថា «...មនុស្សមិនមែនរស់ ដោយសារតែនំប៉័ង...[ឬបាយ]...ប៉ុណ្ណោះទេ*
*គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមកដែរ»*
*ម៉ាថាយ៤:៤*

"It is written, 'Man shall not live by bread alone, but by every word that proceeds out of the mouth of God."

**Matthew 4:4, AFV.**

*«ចូរខំប្រឹងសិក្សា ទុកជាមនុស្សដែលល្បងលជាប់ ជាអ្នកធ្វើការ ដែលមិនត្រូវខ្មាសឡើយ*
*ដោយកាត់ស្រាយ ព្រះបន្ទូលនៃសេចក្ដីពិតយ៉ាងត្រឹមត្រូវ»*
*២ធីម៉ូថេ២:១៥*

"Diligently *study* to show yourself approved unto God, a workman who does not *need to be* ashamed, rightly dividing the Word of the truth;"

2 Timothy 2:15, AFV.

*«គឺជាវិញ្ញាណដែលឲ្យមានជីវិត រូបសាច់គ្មានប្រយោជន៍អ្វីទេ ឯពាក្យដែលខ្ញុំនិយាយនឹងអ្នក*
*រាល់គ្នា នោះត្រូវខាងវិញ្ញាណ នឹងជីវិតវិញ»*
*យ៉ូហាន៦:៦៣*

"It is the Spirit that gives life; the flesh profits nothing. The words that I speak to you, *they* are spirit and *they* are life."

**John 6:63, AFV.**

# ក្រិត្យវិន័យ១០ប្រការ

នោះព្រះទ្រង់មានបន្ទូលនូវពាក្យទាំងនេះថា អញនេះគឺយេហូវ៉ា ជាព្រះនៃឯង ដែលបាននាំឯងចេញពីផ្ទះពួកបាវបំរើនៅស្រុកអេស៊ីព្ទមក

១. កុំឲ្យមានព្រះឯណាទៀតនៅចំពោះអញឲ្យសោះ

២. កុំឲ្យឆ្លាក់រូបណាសំរាប់ឯងឲ្យសោះ ក៏កុំឲ្យធ្វើរូបណាឲ្យដូចជាអ្វីនៅស្ថានសួគ៌ខាងលើ ឬនៅផែនដីខាងក្រោម ឬនៅក្នុងទឹកដែលទាបជាងដីផង ក៏កុំឲ្យក្រាបសំពះនៅចំពោះរបស់ទាំងនោះ ឬគោរពប្រតិបត្តិតាមនោះឡើយ ដ្បិតអញដែលជាយេហូវ៉ា ជាព្រះនៃឯង អញមានសេចក្ដីប្រចណ្ឌ ក៏ទំលាក់ការទុច្ចរិតរបស់ឪពុកទៅលើកូនចៅរហូតដល់ ៣ ហើយ៤ដំណផង ចំពោះអស់អ្នកណាដែលស្អប់អញ តែអញផ្តល់សេចក្ដីសប្បុរស ដល់ទាំងពាន់ដំណ នៃពួកអ្នកដែលស្រឡាញ់ ហើយកាន់តាមបញ្ញត្តិរបស់អញទាំងប៉ុន្មានវិញ

៣. កុំឲ្យចេញព្រះនាមរបស់ព្រះយេហូវ៉ា ជាព្រះនៃឯង ជាអសារឥតការឡើយ ដ្បិតព្រះយេហូវ៉ាទ្រង់នឹងមិនរាប់ជាឥតទោសដល់អ្នកណា ដែលចេញព្រះនាមទ្រង់ ជាអសារឥតការនោះទេ

៤. ចូរឲ្យនឹកចាំពីថ្ងៃឈប់សំរាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ ក្នុងរវាង៦ថ្ងៃ នោះត្រូវឲ្យឯងធ្វើអស់ទាំងការរបស់ឯងចុះ តែឯថ្ងៃទី៧ នោះគឺជាថ្ងៃឈប់សំរាកថ្វាយព្រះយេហូវ៉ាជាព្រះនៃឯងវិញ នៅថ្ងៃនោះមិនត្រូវធ្វើអ្វីឲ្យសោះ ទោះខ្លួនឯងឬកូនប្រុសកូនស្រីឯងក្តី ទោះបាវប្រុស ឬបាវស្រីឯងក្តី ទោះសត្វរបស់ឯង ឬអ្នកដទៃ ដែលនៅផ្ទះឯងក្តី ដ្បិតក្នុង៦ថ្ងៃព្រះយេហូវ៉ាទ្រង់បានធ្វើផ្ទៃមេឃ ផែនដី ហើយនឹងសមុទ្រ ព្រមទាំងរបស់សព្វសារពើនៅស្ថានទាំងនោះដែរ រួចដល់ថ្ងៃទី៧ ទ្រង់ឈប់សំរាក ហេតុនោះបានជាព្រះយេហូវ៉ាទ្រង់បានប្រទានពរដល់ថ្ងៃឈប់សំរាក ហើយក៏ញែកចេញជាបរិសុទ្ធ

៥. ចូរឲ្យគោរពប្រតិបត្តិដល់ឪពុកម្តាយ ដើម្បីឲ្យបានអាយុវែងនៅក្នុងស្រុក ដែលព្រះយេហូវ៉ា ជាព្រះនៃឯងទ្រង់ប្រទានឲ្យ

៦. កុំឲ្យសំឡាប់មនុស្សឲ្យសោះ

៧. កុំឲ្យផិតគ្នាឲ្យសោះ

៨. កុំឲ្យលួចប្លន់ឲ្យសោះ

៩. កុំឲ្យធ្វើជាទីបន្ទាល់ក្លែង ទាស់នឹងអ្នកជិតខាងខ្លួនឲ្យសោះ

១០. កុំឲ្យលោភចង់បានផ្ទះអ្នកជិតខាងខ្លួនឲ្យសោះ ក៏កុំឲ្យលោភចង់បានប្រពន្ធកូនគេ ឬបាវប្រុសបាវស្រីគេក្តី ឬគោ លា ឬរបស់អ្វីផងអ្នកជិតខាងខ្លួនឲ្យសោះ